**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការវិភាគពីកំណើនសេដ្ឋកិច្ចកម្ពុជា
# ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ២០១៧

ស្រាវជ្រាវពីថ្ងៃទី០២ ខែ មេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហាក់ ម៉ុនលី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ខ៊ាន់ ស៊ុនដេត**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ២

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិត ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំទី៤ ក្រុម$D_4C_1$ ឆ្នាំសិក្សា២០១៧-២០១៨ សូមសំដែងនូវការដឹងគុណចំពោះ លោកអ្នកមានគុណទាំងអស់ ដែលបានជ្រោមជ្រែងដល់រូបខ្ញុំឲ្យសម្រេចបាននូវកិច្ចការស្រាវជ្រាវនេះ។

ជាដំបូង ខ្ញុំបាទសូមលំឱនកាយគោរពប្រណិបត្តិ និងសូមសម្ដែងនូវកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក **ឡាយ សេងហាក់** និងអ្នកម្ដាយ **ភីន គន្ធា** ដែលលោកទាំងពីរជាអ្នកមានគុណដ៏ធំដែលពុំអាចគណនាបាន។ លោកបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយក្ដីស្រឡាញ់យ៉ាងកក់ក្ដៅ ជាពិសេសលោកទាំងពីរបានទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងកម្លាំងកាយចិត្ត សម្ភារៈ ព្រមទាំងហិរញ្ញវត្ថុដល់កូនឲ្យទទួលបានការសិក្សាអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្ដមសិក្សា។ កូនសូមគោរពដឹងគុណចំពោះលោកទាំងពីរ ដែលបានលះបង់គ្រប់បែបយ៉ាងដើម្បីរូបកូនដោយមិននឿយណាយ ហើយកូនសូមបួងសួងដល់ទេវតា និងវត្ថុស័ក្ដិសិទ្ធទាំងឡាយក្នុងលោកតាមថែរក្សា និងប្រសិទ្ធពរជ័យសិរីបវរជូនលោកទាំងពីរឲ្យជួបតែសេចក្ដីសុខ សេចក្ដីចម្រើន មានកម្លាំងមាំមួន និងសម្រេចបាននូវរាល់ភារកិច្ចទាំងឡាយ។
- **ឯកឧត្ដមសាកលវិទ្យាធិការ** ដែលបានអនុញ្ញាតិឲ្យរូបខ្ញុំបាទបានចុះឈ្មោះបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ព្រមទាំងលោកសាស្រ្តាចារ្យ និងលោកស្រីសាស្រ្តាចារ្យ ដែលបានលោកបានបង្ហាត់បង្រៀន ចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗដល់រូបខ្ញុំបាទតាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។
- លោកសាស្រ្តាចារ្យ **បណ្ឌិត ង៉ាន់ ស៊ុនដេត** ដែលបានដឹកនាំក្នុងការសរសេរសារណា និងបានខិតខំណែនាំ ផ្ដល់នូវយោបល់ល្អៗ និងចំណាយពេលវេលាដ៏មមារញឹក និងមានតម្លៃរបស់លោកក្នុងការផ្ដល់ជាគំនិតយោបល់ លើកទឹកចិត្ត និងផ្ដួចផ្ដើមក្នុងការសរសេរសារណាឲ្យទទួលបានជោគជ័យជាស្ថាពរ។
- លោកស្រីសាស្រ្តាចារ្យ **សំណាង ផលដេត** ដែលបានជួយសម្រួលរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការចុះស្រាវជ្រាវឯកសារ និងជួយពិនិត្យរចនាបថនៃសារណារបស់ខ្ញុំបាទ។
- លោក **ឯកឧត្ដម ទេព ភិរ្យោរិទ្ធ** ជាអគ្គនាយក នៃនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានអនុញ្ញាតិឲ្យរូបខ្ញុំបាទចុះធ្វើការស្រាវជ្រាវឯកសារនានា

ដែលពាក់ព័ន្ធ រួមទាំងបុគ្គលិកនៃនាយកដ្ឋានគោលនយោបាយទាំងអស់ដែលបានជួយណែនាំ និងផ្តល់ជាឯកសារ។

– កញ្ញា **តឹម ស្រីស្រស់** ដែលបានឧបត្ថម្ភកុំព្យូទ័រដល់រូបខ្ញុំបាទ ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវ និងវាយអត្ថបទសារណានេះ ព្រមទាំងមិត្តភក្តិទាំងអស់ដែលមានជួយលើកទឹកចិត្តដល់រូបខ្ញុំជានិច្ច។

ជាចុងបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យមហាបវរ ដ៏ថ្លៃថ្លាជូនចំពោះលោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ លោក និងលោកស្រីសាស្ត្រាចារ្យ រួមទាំងបុគ្គលិកសិក្សាទាំងអស់ មិត្តរួមជំនាន់ និងអ្នកដែលបានរៀបរាប់ខាងលើទាំងអស់ ឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

តាមរយៈការសិក្សាលើ ផ្នែកទ្រឹស្តីអស់រយៈពេលជិតបួនឆ្នាំកន្លងមកដែលខ្ញុំបាទបានសិក្សា ចំពោះជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទបានចាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងការកើនឡើងកំណើនជាមធ្យមប្រចាំឆ្នាំនៃសេដ្ឋកិច្ចកម្ពុជា ដែលមានកំណើនជាវិជ្ជមានជារៀងរាល់ឆ្នាំនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ស្របពេលជាមួយគ្នានេះដែរ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ **"ការវិភាគពីកំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៥-២០១៧"** ដើម្បីធ្វើជាប្រធានបទសារណា និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

ក្នុងអត្ថបទស្រាវជ្រាវនេះ មានគោលបំណងបង្ហាញពីវឌ្ឍនភាពនៃកំណើនសេដ្ឋកិច្ច ចាប់តាំងពីប្រទេសកម្ពុជាបានផ្លាស់ប្តូរការគ្រប់គ្រងសេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំ មកជាសេដ្ឋកិច្ចទីផ្សារ។ម្យ៉ាងទៀត ចង់ធ្វើការបង្ហាញពីវិបត្តិសេដ្ឋកិច្ចទាំងក្នុងតំបន់ និងសកលលោក ដែលបានជះឥទ្ធិពលដល់សកម្មភាពសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ព្រមទាំងធ្វើការបកស្រាយពីចកលករសំខាន់ៗទាំងបួននៃសេដ្ឋកិច្ច ដែលមានឥទ្ធិពលក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ ទាំងខ្លឹមសារ និងពាក្យពេជន៍ ដោយវាជាស្នាដៃបឋមដែលរូបខ្ញុំបាទបានសម្រិតសម្រាំង និងចងក្រងជាឯកសារ។

អាស្រ័យហេតុនេះ សូមមេត្តាខន្តីអភ័យទោសនូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយចេតនាក្តី និងអចេតនាក្តីដែលរូបខ្ញុំបាទបានបង្កើតឡើងនៅក្នុងអត្ថមួយនេះ។ ជាចុងក្រោយខ្ញុំបាទរង់ចាំការផ្តល់មតិយោបល់ និងការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអានទាំងអស់ដោយក្តីសោមនស្ស។

# មាតិកា

បញ្ជីអក្សរកាត់ .......... iv
បញ្ជីក្រាហ្វិក .......... v
បញ្ជីតារាង .......... vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា និងកម្មវត្ថុ .......... ១
២. ចំណោទបញ្ហា .......... ២
៣. សារៈសំខាន់នៃការស្រាវជ្រាវ .......... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......... ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ .......... ៣
    ក. ប្រភេទទិន្នន័យ .......... ៣
    ខ. ការវិភាគទិន្នន័យ .......... ៣
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៣

## ជំពូកទី១
## រំលឹកទ្រឹស្តីពាក់ព័ន្ធ

១.១. កំណើនសេដ្ឋកិច្ច .......... ៤
    ១.១.១. និយមន័យ .......... ៤
    ១.១.២. ទស្សនៈក្លាស៊ីក (Classic) ទៅលើកំណើនសេដ្ឋកិច្ច .......... ៦
        ១.១.២.១. ទស្សនៈរបស់ Adam Smith ទៅលើកំណើនសេដ្ឋកិច្ច .......... ៦
        ១.១.២.២. ទស្សនៈរបស់ David Ricardo ទៅលើកំណើនសេដ្ឋកិច្ច .......... ៧
        ១.១.២.៣. ទស្សនៈរបស់ Thomas Mathus ទៅលើកំណើនសេដ្ឋកិច្ច .......... ៧
    ១.១.៣. ទស្សនៈណេអូក្លាស៊ីកទៅលើកំណើនសេដ្ឋកិច្ច .......... ៨
    ១.១.៤. ទស្សនៈ Schumpeterian Growth ទៅលើកំណើនសេដ្ឋកិច្ច .......... ៨
១.២. ការវាស់វែងពីកំណើនសេដ្ឋកិច្ច .......... ៩
    ១.២.១. ផលិតផលក្នុងស្រុកសរុប(GDP) .......... ៩
        ១.២.១.១. ការវាស់តាមផលិតកម្ម (Production Approach) .......... ៩
        ១.២.១.២. ការវាស់តាមប្រាក់ចំណូល (Income Approach) .......... ៩

១.២.១.៣. វិធីសាស្ត្រប្រាក់ចំណាយ (Expenditure Approach) ............................ ៩
១.២.២. ភាពខុសគ្នានៃ ផ.ស.ស (GDP) និងកំណើនសេដ្ឋកិច្ច ....................................១១
១.២.៣. ផលិតផលជាតិសរុប (GNP)............................................................................. ១២
១.២.២.១. ការកំណត់ពីអត្ថន័យ (GNP) .......................................................... ១២
១.២.២.២. ភាពខុសគ្នារវាង GDP និង GNP .................................................... ១២
១.២.៣. ភាពមិនសុក្រិតក្នុងការវាស់វែងពីកំណើនសេដ្ឋកិច្ចនៃ GDP ...........................១៣
១.២.៤. សមាសភាគនៃកំណើនសេដ្ឋកិច្ច ...................................................................១៣
១.២.៤.១. ការកើនឡើងនៃដើមទុន .................................................................១៣
១.២.៤.២. កំណើនប្រជាជន.............................................................................១៤
១.២.៤.៣. ការរីកចម្រើននៃបច្ចេកវិទ្យា............................................................១៤
១.៣. តួនាទីរបស់រដ្ឋាភិបាលនៅក្នុងកំណើនសេដ្ឋកិច្ច ..........................................................១៥

## ជំពូកទី២

## ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ១៩៩៥ ដល់ ឆ្នាំ២០១៧

២.១. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច (១៩៩៥-២០១៧).................................................................១៨
២.១.១. ដំណាក់កាលនៃកំណើនសេដ្ឋកិច្ច...................................................................១៨
២.១.២. ការប្រាស្រ័យទាក់ទងនៃសេដ្ឋកិច្ចកម្ពុជា និងសេដ្ឋកិច្ចសកល......................... ២២
២.១.៣. កំណើនផលិតផលក្នុងស្រុកសរុប (GDP) ..................................................... ២៤
២.១.៤. កំណើន ផ.ស.ស ជាមធ្យមសម្រាប់មនុស្សម្នាក់............................................. ២៦
២.២. ចលករនៃកំណើនសេដ្ឋកិច្ច.......................................................................................២៧
២.២.១. ការចំណាយប្រើប្រាស់របស់គ្រួសារ (C)..........................................................២៧
២.២.២. ការវិនិយោគ (I)........................................................................................ ២៩
២.២.២.១. ការវិនិយោគផ្ទាល់ពីបរទេស (FDI)....................................................៣០
២.២.២.២. ទស្សនៈពាក់ព័ន្ធនឹងការវិនិយោគ.......................................................៣១
២.២.៣. ការចំណាយសាធារណៈ (G)........................................................................ ៣៣
២.២.៤. ការនាំចេញសុទ្ធ (NX)...............................................................................៣៥
២.២.៤.១. ការនាំចេញ (Exports) ...................................................................៣៥
២.២.៤.២. ការនាំចូល (Imports)................................................................... ៣៧

២.៣. វិបត្តិសេដ្ឋកិច្ចក្នុងការរាំងស្ទះដល់កំណើនសេដ្ឋកិច្ចកម្ពុជា........................................... ៣៩
២.៣.១. វិបត្តិហិរញ្ញវត្ថុអាស៊ី (១៩៩៧-១៩៩៨)............................................................ ៣៩
២.៣.២. វិបត្តិហិរញ្ញវត្ថុពិភពលោក (២០០៨)................................................................ ៤១
២.៤. គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការជម្រុញកំណើនសេដ្ឋកិច្ច .............................. ៤២
២.៤.១. វិធានការផ្នែកចំណូល ..................................................................................... ៤៤
២.៤.១.១. ចំណូលពន្ធដារ ........................................................................................ ៤៤
២.៤.១.២. ចំណូលគយ និងរដ្ឋាករ ............................................................................ ៤៦
២.៤.១.៣. ចំណូលមិនមែនសារពើពន្ធ ........................................................................ ៤៨
២.៤.២. វិធានការផ្នែកចំណាយ ..................................................................................... ៥០
២.៣. ទស្សនៈវិស័យទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា ........................................................... ៥៣

## ជំពូកទី៣

## ការវិភាគពីកំណើនសេដ្ឋកិច្ចកម្ពុជា

៣.១. លទ្ធផលនៃការស្រាវជ្រាវ...................................................................................... ៥៧
៣.២. ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ ................................................................... ៥៨

## សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន ....................................................................................................... ៦១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ផ.ស.ស. | : ផលិតផលក្នុងស្រុកសរុប |
| C | : Consumption |
| FDI | : Foreign Direct Investment |
| G | : Government Expenditure |
| GDP | : Gross Domestic Product |
| GNP | : Gross National Product |
| I | : Investment |
| NX | : Net Export |
| SMEs | : Small and Medium Enterprises |

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១៖ ផ.ស.ស ប្រចាំឆ្នាំតាមថ្លៃបច្ចុប្បន្ន គិតជាលានដុល្លារ ........................................ ២៥

ក្រាហ្វិកទី២៖ កំណើន ផ.ស.ស ប្រចាំឆ្នាំ គិតជាភាគរយ ........................................................ ២៦

ក្រាហ្វិកទី៣៖ កំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារ) ..........................................២៧

ក្រាហ្វិកទី៤៖ ការចំណាយប្រើប្រាស់របស់គ្រួសារ (C) គិតជាដុល្លារ ........................................ ២៨

ក្រាហ្វិកទី៥៖ អត្រាបម្រែបម្រួលនៃការចំណាយប្រើប្រាស់របស់គ្រួសារ (គិតជា%) ................. ២៨

ក្រាហ្វិកទី៦៖ ការវិនិយោគសរុប (គិតជាដុល្លារ) ..................................................................... ២៩

ក្រាហ្វិកទី៧៖ អត្រាបម្រែបម្រួលនៃការវិនិយោគសរុប (គិតជា%) ............................................ ៣០

ក្រាហ្វិកទី៨៖ **Value and Growth of FDI Inflow as of Q3-2017 (US million)** .......................... ៣១

ក្រាហ្វិកទី៩៖ ការចំណាយសាធារណៈ (G) គិតជាដុល្លារ ........................................................ ៣៣

ក្រាហ្វិកទី១០៖ អត្រាបម្រែបម្រួលនៃការចំណាយសាធាណៈ (គិតជា%)................................ ៣៤

ក្រាហ្វិកទី១១៖ ការនាំចេញ (Export) គិតជាដុល្លារ ............................................................... ៣៥

ក្រាហ្វិកទី១២៖ អត្រាបម្រែបម្រួលនៃការនាំចេញ (គិតជា%) ................................................... ៣៥

ក្រាហ្វិកទី១៣៖ ការនាំចូល (Import) គិតជាដុល្លារ................................................................. ៣៧

ក្រាហ្វិកទី១៤៖ អត្រាបម្រែបម្រួលនៃការនាំចូល (គិតជា%)..................................................... ៣៨

ក្រាហ្វិកទី១៥៖ ការនាំចេញសុទ្ធរបស់កម្ពុជា (NX) គិតជាដុល្លារ ............................................. ៣៩

# បញ្ជីតារាង

តារាងទី១៖ **Share of FDI Inflow as of Q3-2017** ............................................................ ៣១
តារាងទី២៖ **Growth of Export Compositions and Garment Export Destinations** .................. ៣៦
តារាងទី៣៖ **Value of Import and its Compositions (Annual Growth, percent)** ...................... ៣៨
តារាងទី៤៖ កំណើនសេដ្ឋកិច្ចតាមវិស័យ ........................................................................ ៥៥
តារាងទី៥៖ ទិន្នន័យសម្រាប់វិភាគពីឆ្នាំ១៩៩៥ -២០១៦ គិតជាដុល្លារ..................................... ៥៧

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា និងកម្មវត្ថុ

សេដ្ឋកិច្ចកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស ចាប់តាំងពីមានការកែទម្រង់ការគ្រប់គ្រងសេដ្ឋកិច្ច ពីសេដ្ឋកិច្ចបែបផែនការប្រមូលផ្តុំ មកសេដ្ឋកិច្ចទីផ្សារ ដែលត្រូវបានផ្តួចផ្តើមគំនិតរៀបចំឡើងចាប់ពីពាក់កណ្តាលទសវត្សទី៨០។ ប៉ុន្តែ ការរីកចម្រើននេះបានចាប់ផ្តើមចេញពីមូលដ្ឋានមួយ ដែលមានកម្រិតទាបបំផុត ហើយកម្រិតផលិតកម្មនៅក្នុងបណ្តាផ្នែកសំខាន់ៗពុំទាន់សម្រេចបានស្មើនឹងកម្រិតនៃចុងទសវត្សទី៦០ នៅឡើយ។ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ១៩៩១ ត្រូវបានប៉ាន់ស្មានស្មើ១៨០ដុល្លារអាមេរិក។ តួលេខនេះ អាចមានកម្រិតប្រហាក់ប្រហែលពាក់កណ្តាលនៃកម្រិតនាពេលមុនសង្គ្រាម។ ផលិតផលក្នុងស្រុកសរុប "គិតតាមថ្លៃថេរឆ្នាំ១៩៨៩" កើនឡើង៧.៦% នៅក្នុងឆ្នាំ១៩៩១ កើនឡើង៧% នៅក្នុងឆ្នាំ១៩៩២ និងអាចកើន ៥.៥% នៅក្នុងឆ្នាំ១៩៩៣។[1]

ចំណេរតមកទៀតសេដ្ឋកិច្ចនៃប្រទេសកម្ពុជា បានទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចពិភពលោក ហើយមានកំណើនតិចតួចគឺ០.១%(តាមថ្លៃថេរឆ្នាំ២០០០) នៅឆ្នាំ២០០៩ បើធៀបទៅនឹងកំណើន៦.៧% នៅឆ្នាំ២០០៨ និង១០.២% នៅឆ្នាំ២០០៧។ យោងតាមគណនេយ្យជាតិកម្ពុជាឆ្នាំ១៩៩៣-២០០៩ (ព្រឹត្តលេខ ១៤) បានបង្ហាញថា ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់មានការធ្លាក់ចុះប្រចាំឆ្នាំ -៣.៣% នៅឆ្នាំ២០០៩ និងបានធ្លាក់ចុះដល់ ៥០២ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧ និង២០០៨ ដែលមានចំនួន ៥១៩ និង៥០៣ ដុល្លារអាមេរិក រៀងគ្នា។ គិតតាមថ្លៃបច្ចុប្បន្ន ផលិតផលក្នុងស្រុកក្នុងមនុស្សម្នាក់បានធ្លាក់ចុះពី ៧៦០ ដុល្លារអាមេរិក ឆ្នាំ២០០៨ ដល់ ៧៥៣ ដុល្លារអាមេរិក នៅឆ្នាំ២០០៩[2]។ បន្ទាប់ពីសេដ្ឋកិច្ចពិភពលោកបានងើបឡើងវិញ ឃើញថាកំណើនសេដ្ឋកិច្ចកម្ពុជាមានសន្ទុះកើនឡើងខ្លាំងគួរឲ្យគត់សម្គាល់។ រហូតមកដល់ពេលបច្ចុប្បន្ននេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ៦.៩% ដូចឆ្នាំ២០១៧ ដែលធ្វើឲ្យ ផសស តាមថ្លៃបច្ចុប្បន្នកើនឡើងដល់ប្រមាណជា២៤,៥៥២លានដុល្លារអាមេរិក ខណៈដែលផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងទុកថាកើនឡើងដល់ ១,៥៦៨ ដុល្លារអាមេរិក[3]។

---

[1] ផែនការស្តារសេដ្ឋកិច្ច សង្គមកិច្ច ១៩៩៤-១៩៩៥ ទំព័រ២៣

[2] គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៩, វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

[3] ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពី សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៨, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដោយយល់ឃើញថា កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាសព្វថ្ងៃមានការរីកចម្រើនគួរឲ្យគត់សម្គាល់ និងមានកំណើនខ្ពស់នៅក្នុងចំណោមបណ្តាប្រទេសនៅអាស៊ី ចាប់តាំងពីកម្ពុជាទទួលបានសន្តិភាពពេញលេញ បន្ទាប់ពីឆ្លងកាត់សង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំ។ ដូច្នេះ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ មានបំណងចង់សិក្សាឲ្យកាន់តែច្បាស់ពីកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជាដែលមានលក្ខណៈដូចខាងក្រោម៖

- ស្វែងយល់ពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ចាប់ពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០១៧
- គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ច
- ធ្វើការវិភាគពីកំណើនសេដ្ឋកិច្ច ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុបជាក់ស្តែងរបស់ប្រទេសកម្ពុជា
- ដើម្បីបានដឹងពីអថេរណាមួយ ដែលមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាខ្លាំងជាងគេ។

## ២. ចំណោទបញ្ហា

ដោយសង្កេតឃើញថា ប៉ុន្មានក្នុងកំឡុងពេល១០ឆ្នាំចុងក្រោយនេះសេដ្ឋកិច្ចប្រទេសកម្ពុជាមាន សន្ទុះកំណើនខ្លាំងគួរឲ្យគត់សម្គាល់។ កម្ពុជាបានរក្សានូវកំណើនសេដ្ឋកិច្ចឲ្យស្ថិតនៅក្នុងរង្វង់៧.០%ក្នុងមួយឆ្នាំ ដែលការសម្រេចបាននូវសមិទ្ធផលដ៏ល្អនេះ គឺដោយសារកម្ពុជារក្សាបាននូវស្ថេរភាពនយោបាយ នឹងបានទាក់ទាញការវិនិយោគទាំងក្នុង និងក្រៅប្រទេស។ ដើម្បីបន្តនិរន្តរភាពកំណើនសេដ្ឋកិច្ចបន្តទៅទៀត តើគោលនយោបាយសេដ្ឋកិច្ចកម្ពុជាមានដំណើរការដូចម្តេចខ្លះ?

## ៣. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បុគ្គលម្នាក់ៗ ជាពិសេសគឺវាពិតជាមានអត្ថប្រយោជន៍ច្រើនចំពោះនិស្សិត និងអ្នកដែលចង់ស្វែងយល់ពីសង្គម ឬដំណើរការនៃព្រឹត្តិការណ៍អ្វីមួយ។ ការស្រាវជ្រាវទៅលើប្រធានបទនេះ គឺដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលប្រកាន់យករបបសេដ្ឋកិច្ចបែបផែនការ និងដំណើរនៃការផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចបែបទីផ្សារសេរីមានកំណើនប្រែប្រួលខុសគ្នាដូចម្តេចខ្លះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងសារណាបញ្ចប់ការសិក្សានេះ បានសិក្សាជាសំខាន់ទៅលើកំណើនសេដ្ឋកិច្ចកម្ពុជាផ្តោតលើ GDP ដោយគិតត្រឹមឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៦ និងធ្វើការវិភាគផ្អែកលើធាតុសំខាន់នៃចលករសេដ្ឋកិច្ចកម្ពុជាដែលមានដូចជា៖ ការចំណាយរបស់គ្រួសារ ការវិនិយោគ ការចំណាយសាធារណៈ និងការនាំចេញសុទ្ធ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក. ប្រភពទិន្នន័យ

ដើម្បីចងក្រងនូវឯកសារនេះឡើង គឺត្រូវបានប្រើប្រាស់នូវប្រភពទិន្នន័យកម្រិតទី២ (Secondary Data) យកមកធ្វើការបកស្រាយ ដោយខ្ញុំបាទបានចុះទៅធ្វើការស្រាវជ្រាវដោយផ្ទាល់នៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្វែងរកទិន្នន័យ និងប្រមូលយកទិន្នន័យសំខាន់ៗដែលពាក់ព័ន្ធមកធ្វើការរៀបចំជាឯកសារសារណានេះ។

### ខ. ការវិភាគទិន្នន័យ

កិច្ចការស្រាវជ្រាវនេះ បានជ្រើសរើសវិធីសាស្ត្រមួយដែលជាវិធីសាស្ត្របរិមាណវិស័យ និងទិន្នន័យដែលទទួលបានគឺត្រូវបានយកទៅវិភាគនៅក្នុងកម្មវិធី SPSS។ ទាក់ទងនឹង GDP ធ្វើការប្រមូលទិន្នន័យចាប់ពីឆ្នាំ១៩៩៥-២០១៦ និងធ្វើការបកស្រាយទៅលើចលករសំខាន់ៗទាំងបួនគិតជាភាគរយនៃសេដ្ឋកិច្ចដូចខាងក្រោម៖

- ការចំណាយរបស់គ្រួសារ(C) ពីឆ្នាំ២០០៥-២០១៦
- ការវិនិយោគ(I) ធ្វើការបកស្រាយគិតត្រឹមចន្លោះឆ្នាំ២០០៥-១២០១៦
- រីឯ ការចំណាយសាធារណៈ(G) និងការនាំចេញសុទ្ធ(NX) ក៏ត្រូវបានលើកយកមកបង្ហាញក្នុងចន្លោះឆ្នាំដូចគ្នានឹងចលករនៃសេដ្ឋកិច្ចទាំងពីរខាងលើដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានចែកចេញជាបីជំពូកធំៗដូចជា៖

- ជំពូកទី១ ការរំលឹកទ្រឹស្តីពាក់ព័ន្ធ៖ បង្ហាញពីនិយមនៃកំណើនសេដ្ឋកិច្ច ការលើកឡើងពីទស្សនៈរបស់សេដ្ឋកិច្ចវិទូមួយចំនួនស្តីពីកំណើនសេដ្ឋកិច្ច។ ធ្វើការពន្យល់ពីរបៀបនៃការគណ-នារកផលិតផលក្នុងស្រុកសរុបតាមរយៈវិធីបីយ៉ាង និងធ្វើការបង្ហាញពីសមាសភាគដែលចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ច។

- ជំពូកទី២ ស្ថានភាពកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាពីឆ្នាំ១៩៩៥-២០១៧៖ ជំពូកនេះ ធ្វើការបង្ហាញពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពីឆ្នាំ១៩៩៥-២០១៧ និងដំណាក់កាលនៃកំណើនសេដ្ឋកិច្ច។ រៀបរាប់អំពីផលិតផលក្នុងស្រុកសរុបដុល និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ ព្រមទាំងមានបង្ហាញពីអត្រាកំណើនផងដែរ។ លើកឡើងពីចលករនៃសេដ្ឋកិច្ចសំខាន់ៗ ដែលមានឥទ្ធិពលដល់កំណើនសេដ្ឋកិច្ច។ បញ្ហាប្រឈមដែលធ្វើឲ្យរាំងស្ទះដល់កំណើនសេដ្ឋកិច្ច និងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។
- ជំពូកទី៣ ការវិភាគពីកំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៥-២០១៧៖ បង្ហាញពីការវិភាគទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ។ ការសិក្សាពីមេគុណនៃអថេរ និងធ្វើការបកស្រាយពីអថេរនីមួយៗ។

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១. កំណើនសេដ្ឋកិច្ច

### ១.១.១. និយមន័យ

ពាក្យថាកំណើនសេដ្ឋកិច្ចជាទូទៅ ត្រូវបានគេកំណត់អត្ថន័យខុសៗគ្នាទៅតាមលក្ខខណ្ឌស្ថានភាពផ្សេងៗគ្នានៅក្នុងប្រទេសនីមួយៗ[4]។ កំណើនសេដ្ឋកិច្ច (Economic Growth) គឺជាលទ្ធភាពនៃប្រព័ន្ធសេដ្ឋកិច្ច ក្នុងការបង្កើននូវផលិតផលជាតិសរុប (Gross National Product-GNP) ឬផលិតផលក្នុងស្រុកសរុប (Gross Domestic Product-GDP) ដោយយកអត្រាកំណើន GNP ឬ GDP សម្រាប់ប្រជាជនម្នាក់ៗ ជាខ្នាតទូទៅសម្រាប់វាស់ស្ទង់កម្រិតជីវភាពរបស់នៅរបស់ប្រជាជន។ កំណើនសេដ្ឋកិច្ច ជាភាពល្អប្រសើរនូវសូចនាករសេដ្ឋកិច្ច រួមជាមួយសូចនាករសង្គម មានដូចជាអត្រាអនក្ខរជនអត្រាក្មេងចូលរៀនចំនួនប្រជាជនសម្រាប់គ្រូពេទ្យម្នាក់ អត្រាកំណើត អត្រាមរណៈ និងអត្រានៃលទ្ធភាពប្រើប្រាស់ទឹកស្អាតជាដើម[5]។ យោងទៅតាមរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅឆ្នាំ១៩៩៦ ដែលបានបង្កើតកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិស្តីអំពី "ការអភិវឌ្ឍធនធានមនុស្ស ដែលជាមធ្យោបាយអភិវឌ្ឍសេដ្ឋកិច្ចចុងក្រោយ" ក៏បង្ហាញថា កំណើនសេដ្ឋកិច្ចកើតមានឡើងនៅពេលដែលមានការកើនឡើងនៃកម្រិតមូលធនជាតិសរុបទាំងមូល និងសមត្ថភាពនៃការគ្រប់គ្រង ការកាត់បន្ថយភាពក្រីក្រ និងការដោះស្រាយបញ្ហាសង្គម។

មានទ្រឹស្តីមួយចំនួនទៀត ដែលត្រូវបានគេលើកឡើងស្តីពីការយល់ដឹង និងសញ្ញាណនៃកំណើនសេដ្ឋកិច្ចដូចខាងក្រោម[6]៖

– កំណើនសេដ្ឋកិច្ច គឺជាដំណើរការដែលនាំឲ្យមានការកើនឡើងនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយ។ ដូច្នេះ ខឿនសេដ្ឋកិច្ចអាចនិយាយបានថា រីកចម្រើន ឬមានកំណើនទាល់តែមានការកើនឡើងនៃទិន្នផលសរុប។ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយអាចថេរ ឬថយចុះ ក្នុងរយៈពេលមួយ។ ការថយចុះ គឺជាការប្រែប្រួលអវិជ្ជមាន ចំណែកឯការកើនឡើងជាការប្រែប្រួលវិជ្ជមាន។

[4] Cause of Economic Growth, 2015

[5] ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច, ភ្នំពេញ ២០០៤ ទំព័រ ២៣៥

[6] ពោ ប៊ុណ្ណា, ម៉ាក្រូសេដ្ឋកិច្ចវិទ្យា ទ្រឹស្តី និងគោលនយោបាយ ឆ្នាំ២០០២ ទំព័រ១៧៦, វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា

– និយមន័យកំណើនសេដ្ឋកិច្ចផ្សេងទៀត គឺថាកំណើនសេដ្ឋកិច្ចនឹងកើតមាននៅពេលដែលមានការកើនឡើងនៃផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ៗ។ កំណើនសេដ្ឋកិច្ចតាមនិយមន័យនេះ បានបង្ហាញពីការកើនឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន(standard of living) ដែលវាស់ដោយផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ៗ(GDP per Capita)។ ដូច្នេះ កំណើនសេដ្ឋកិច្ចកើតមានឡើងនៅពេលដែលកម្រិតនៃកំណើនផលិតផលសរុបរបស់ប្រទេស ធំជាងកម្រិតនៃកំណើប្រជាជន។ ផ្ទុយទៅវិញ ការធ្លាក់ចុះនៃសេដ្ឋកិច្ច ឬការធ្លាក់ចុះនៃកម្រិតជីវភាពរស់នៅជាក់ស្តែងកើតមានឡើង នៅពេលដែលអត្រាកំណើនប្រជាជន ធំជាងកំណើនទិន្នផលសរុបរបស់ប្រទេសនោះ។

**១.១.២. ទស្សនៈក្លាស៊ីក** ( Classic ) **ទៅលើកំណើនសេដ្ឋកិច្ច**

ក្នុងដំណើរការវិភាគកំណើនសេដ្ឋកិច្ច តាមរយៈទស្សនៈក្លាស៊ីកនេះ ត្រូវបានចូលរួមដោយសេដ្ឋកិច្ចវិទូដូចជា លោក Adam Smith លោក David Ricardo លោក Thomas Malthus[7]។ល។ ទស្សនៈក្លាស៊ីកជាទស្សនៈ ដែលកើតឡើងក្នុងកំឡុងពេលសតវត្សទី១៨ហើយទស្សនៈនេះបានបង្ហាញថាកំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយគឺ អាស្រ័យទៅលើការកើនឡើងចម្បងនៃចំនួនប្រជាជននៅក្នុងប្រទេសនោះ និងកម្រិតបច្ចេកវិទ្យា[8]។ ទស្សនៈនេះក៏បានពន្យល់ទៀតថា កំណើននៃការរីលូតលាស់នៃបច្ចេកវិទ្យា ដែលជម្រុញកំណើនសេដ្ឋកិច្ច អាស្រ័យនឹងបរិមាណមូលធនដែលបានចំណាយទៅលើដំណើរការធ្វើឲ្យបច្ចេកវិទ្យារីកចម្រើន ក៏ប៉ុន្តែប្រសិនបើមានការធ្លាក់ចុះនូវបរិមាណមូលធនចំណាយលើបច្ចេកវិទ្យានោះ ក៏ធ្វើឲ្យមានការធ្លាក់ចុះនូវកំណើនសេដ្ឋកិច្ចដែរ។ ក្រៅពីមូលហេតុចម្បងសំខាន់ខាងលើដែលបានចូលរួមក្នុងកំណើនសេដ្ឋកិច្ចហើយនោះ ក៏បានកំណត់នូវកត្តាមួយចំនួនផ្សេងទៀតដែលចូលរួមធ្វើឲ្យសេដ្ឋកិច្ចមានភាពរីកចម្រើនដូចជា កំណើននៃការវិនិយោគ តួនាទីផលិតកម្ម និងទំហំកម្លាំងពលកម្មជាដើម។

**១.១.២.១. ទស្សនៈរបស់** Adam Smith **ទៅលើកំណើនសេដ្ឋកិច្ច**

លោក Adam Smith ត្រូវបានចាត់ទុកថាជាសេដ្ឋកិច្ចវិទូក្លាស៊ីកដ៏ល្បីល្បាញមួយរូប ដែលបានសរសេរអត្ថបទមួយក្នុងឆ្នាំ១៧៧៦ មានចំណងជើងថា "The Wealth of Nation" ដែលគោលបំណងរបស់អត្ថបទនេះគឺបង្ហាញពីភាពមានបានរបស់ប្រទេស។ លោកបានយល់ឃើញថាកំណើនកើតមានឡើងអាស្រ័យទៅតាមជំនាញក្នុងដំណើរការផលិតកម្ម និងការរួមបញ្ចូលមូល

[7] http://www.investopedia.com/terms/c/classicaleconomics.asp

[8] htt://www.wisegeek.com/what-are-the-different-theories-of-economic-growth.htm, n.d

ធនក្នុងដំណើរការទាំងនោះ (Donald.J, nd)។ ចំណែកឯរដ្ឋាភិបាលវិញគឺគួរតែប្រកាន់ឥរិយាបថមួយ ដែលអនុញ្ញាតឲ្យទីផ្សារមានដំណើរការផលិតកម្មទំនិញ និងសេវាព្រមទាំងបែងចែកផលិតផលទាំងនោះក្នុងទីផ្សារដោយខ្លួនឯង ព្រោះដំណើរការបែបនេះផ្តល់នូវសេរីភាពពេញលេញដល់ដំណើរការសកម្មភាពដែលជំរុញចលនាសេដ្ឋកិច្ចក្នុងប្រទេស[9]។

**១.១.២.២. ទស្សនៈ David Ricardo ទៅលើកំណើនសេដ្ឋកិច្ច**

ទស្សនៈរបស់លោក David Ricardo ជាទស្សនៈដែលស្ថិតនៅក្នុងសម័យបដិវត្តន៍ឧស្សាហកម្ម ដោយនៅក្នុងឆ្នាំ១៨១៧ លើបានបោះផ្សាយសៀវភៅដែលនិយាយអំពី "ទ្រឹស្តីមូលដ្ឋាននៃគោលនយោបាយសេដ្ឋកិច្ច និងពន្ធ"[10]។ នៅក្នុងដំណើរការធ្វើឲ្យសេដ្ឋកិច្ចរីកលូតលាស់ លោកបានបង្ហាញពីកត្តាមួយចំនួនដែលអាចសម្រួលដល់កំណើន ហើយកត្តាទាំងនោះមានដូចជា សារៈសំខាន់នៃវិស័យកសិកម្ម តម្លៃនៃពលកម្ម ការបែងចែកចំណូលជាតិដែលបានមកពីម្ចាស់ដី ពួកមូលធន និងកម្មករ និងទ្រឹស្តីឧត្តមភាពធៀបជាដើម។ យោងតាមកត្តាទាំងនោះគេសង្កេតឃើញថា ទ្រឹស្តីឧត្តមភាពធៀបជាទស្សនៈចម្បងដែលលោក David Ricardo បានប្រើជាគោលក្នុងការពន្យល់ពីដំណើរការដែលជម្រុញដល់កំណើនសេដ្ឋកិច្ច[11]។ ទ្រឹស្តីនេះបង្ហាញពីសមត្ថភាពនៅក្នុងការផលិតទំនិញអ្វីមួយ ត្រង់ចំណាយឱកាសទាបជាងទំនិញរបស់ប្រទេសដទៃទៀត ដែលតម្លៃទាបនេះធ្វើឲ្យប្រទេស ដែលជាអ្នកផលិតអាចធ្វើការប្រកួតប្រជែងយ៉ាងមានប្រសិទ្ធភាពនៅក្នុងទីផ្សារ និងមានលទ្ធភាពក្នុងការបង្កើនការងារបន្ថែមនៅក្នុងស្រុក។

**១.១.២.៣. ទស្សនៈ Thomas Malthus ទៅលើកំណើនសេដ្ឋកិច្ច**

ក្រៅពីទស្សនៈរបស់សេដ្ឋវិទូក្នុងទស្សនៈក្លាស៊ីក លោក Thomas Malthus ក៏ជាបុគ្គលមួយរូបដែលពន្យល់ពីដំណើរការនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយលោកចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកំណើនប្រជាជន[12]។ លោកបានបង្ហាញថា កំណើនសេដ្ឋកិច្ចកើតឡើងស្របពេលដែលមូលធនសរុបក្នុងប្រទេសមានការកើនឡើង ហើយមូលធននៅក្នុងប្រទេសនោះកើនឡើងអាស្រ័យទៅលើបរិមាណផលិត។ ប្រសិទ្ធភាពនៃការផលិតទំនិញ និងសេវាទាំងនៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្មមានការកើនឡើង នៅពេលដែល ដី ពលកម្ម និងមូលធនត្រូវបានរៀបចំ និងប្រើប្រាស់យ៉ាងត្រឹមត្រូវ។ ទន្ទឹមនឹងការកើនឡើងមូលធនតាមរយៈកំណើននៃបរិមាណ

[9] What are the different theory of Economic Growth?, n.d

[10] http://www.wisegeek.com/shat-are-t the-different-theories-of-economic-growth.htm, n.d

[11] Hash, D. Economic Growth part III, 2015

[12] The concise Encyclopedia of Economics, 2008

ផលិត ដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ច វាអាស្រ័យទៅលើផ្នែកខាងក្រៅនៃសេដ្ឋកិច្ចមួយចំនួនដែរ ដូចជា ស្ថេរភាពនយោបាយ និងបុគ្គលម្នាក់ៗនៅក្នុងប្រទេសនោះផងដែរ។[13]

**១.១.៣. ទស្សនៈណេអូក្លាស៊ិក** (Neo-Classic) **ទៅលើកំណើនសេដ្ឋកិច្ច**

ទ្រឹស្តីណេអូក្លាស៊ិកទៅលើកំណើនសេដ្ឋកិច្ច ជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលត្រូវបានបង្កើតឡើងដោយលោក Robert Solow នៅសតវត្សទី២០ កំឡុងឆ្នាំ១៩៥០ ដល់ ១៩៦៥។ ជាដំបូងលោក Robert Solow បានធ្វើការអភិវឌ្ឍទស្សនៈក្លាស៊ិក ដោយលោកបានបន្ថែមថា ការសន្សំជាកត្តាមួយផ្សេងទៀតដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច ហើយស្របពេលជាមួយគ្នានេះកំណើននៃការសន្សំ នឹងមានការកើនឡើងក្នុងស្ថានភាពដែលការចំណាយ មានការកាត់បន្ថយ។ ក្រៅពីការផ្តល់ទស្សនៈបន្ថែមទៅលើ ទស្សនៈក្លាស៊ិក លោក Robert Solow រួមគ្នាជាមួយ លោក Paul Omerod បានបង្កើតនូវទ្រឹស្តីកំណើនសេដ្ឋកិច្ចថ្មីមួយដែលមានឈ្មោះថា ទ្រឹស្តីណេអូក្លាស៊ិក ដែលទ្រឹស្តីនេះក៏បានបន្ថែមទៅលើទស្សនៈ Adam Smith ផងដែរ[14]។ ទ្រឹស្តីនេះបង្ហាញថា ការកើនឡើងនៃកម្លាំងពលកម្មជាកត្តាមួយចម្បងនៅក្នុងកំណើនសេដ្ឋកិច្ច ហើយជាពិសេសទៅទៀតនោះ កំណើនសេដ្ឋកិច្ចនឹងរឹតតែបន្តកើនឡើង នៅក្នុងពេលដែលគុណភាពនៃកម្លាំងពលកម្មតាមរយៈការអប់រំ និងការហ្វឹកហាត់ ការកើនឡើងនៃសហគ្រិនភាពថ្មីៗ និងកំណើននៃការវិនិយោគកើនឡើង។ ទ្រឹស្តីនេះក៏បង្ហាញពីស្ថេរភាពនៃកំណើនសេដ្ឋកិច្ចដោយមានការចូលរួមពីកត្តាជម្រុញ៣គឺ កម្លាំងពលកម្ម មូលធន និងបច្ចេកវិទ្យា (Phil, M.)។ លំនឹងនៃកំណើនសេដ្ឋកិច្ចកើតមានឡើងជាបណ្តោះអាសន្ន នៅពេលដែលទំហំនៃកម្លាំងពលកម្ម មូលធន និងកម្រិតនៃបច្ចេកវិទ្យាត្រូវបានកែតម្រូវយ៉ាងសមស្រប ហើយកំណើនសេដ្ឋកិច្ចនឹងបន្តកើនឡើងពេលដែលមានការរីកចម្រើនផ្នែកបច្ចេកវិទ្យា (International Economics, nd.)។

**១.១.៤. ទស្សនៈ** Schumpeterian Growth **ទៅលើកំណើនសេដ្ឋកិច្ច**

ទ្រឹស្តី Schumpeterian Growth ជាទ្រឹស្តីបង្ហាញពីកំណើនសេដ្ឋកិច្ចមួយដែលត្រូវបានបង្កើតឡើងដោយសេដ្ឋវិទូជនជាតិអូស្ត្រាលីម្នាក់ឈ្មោះថា Joseph Schumpeter ក្នុងទសវត្សទី២០ (as cited from Hash, D. 2016)។ ក្នុងទ្រឹស្តីនេះ លោកបានធ្វើការអង្កេតមួយជំហានបន្ថែមពីលើឥទ្ធិពលនៃបច្ចេកវិទ្យា និងការបង្កើតថ្មីដែលចូលរួមក្នុងកំណើនសេដ្ឋកិច្ច ដែលទស្សនៈរបស់លោកបានកំណត់ថា ស្របពេលដែលបច្ចេកវិទ្យាមានការរីកចម្រើន ការបង្កើតគំនិតច្នៃប្រឌិត និង

[13]Lauren, F, nd

[14] http://www.wisegeek/what-are-the-different-theories-of-economic-growth.htm

ការផលិតទំនិញ និងសេវាថ្មីៗដោយរួមប្រើប្រាស់ផលប្រយោជន៍ដែលបានមកពីការរីចម្រើនខាងបច្ចេកវិទ្យាទៀតនោះ អាចជួយឲ្យមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស( Economic Growth Part III, 2015)។

## ១.២. ការវាស់វែងពីកំណើនសេដ្ឋកិច្ច

### ១.២.១. ផលិតផលក្នុងស្រុកសរុប( GDP )

ផលិតផលក្នុងស្រុកសរុប គឺជាតម្លៃទ្រព្យ និងសេវាកម្មចុងក្រោយ ដែលត្រូវបានផលិតនៅក្នុងប្រទេសមួយនៅរយៈពេលមួយដែលបានកំណត់ជាទូទៅមួយឆ្នាំ[15]។ គេមានវិធីបីយ៉ាងក្នុងការគណនាពីផលិតក្នុងស្រុកសរុបគឺ៖ ការវាស់តាមផលិតកម្ម ការវាស់តាមប្រាក់ចំណូល និងវិធីចុងក្រោយគឺការវាស់តាមប្រាក់ចំណាយ[16]។

#### ១.២.១.១. ការវាស់តាមផលិតកម្ម( Production Approach )

គេធ្វើការគណនាផលិតផលក្នុងស្រុកសរុប តាមវិធីសាស្ត្រផលិតកម្ម តាមរយៈផលបូកតម្លៃបន្ថែមដុលផលិតផលដោយសេដ្ឋកិច្ចទាំងមូល ឬជាផលដកនៃតម្លៃផលិតកម្ម ឬធាតុចូល (Input) នឹងតម្លៃទំនិញនិងសេវាទាំងអស់ ដែលត្រូវបានប្រើប្រាស់នៅក្នុងដំណើរការផលិតកម្ម (ការប្រើប្រាស់អន្តរកាល)។

#### ១.២.១.២. ការវាស់តាមប្រាស់ចំណូល( Income Approach )

គេធ្វើការគណនាផលិតផលក្នុងស្រុកសរុប តាមវិធីសាស្ត្រប្រាក់ចំណូល តាមរយៈផលបូកចំណូលនៃផលិតផលក្នុងស្រុកទាំងអស់។ ក្នុងនោះមានសមាសធាតុបីសំខាន់គឺ៖

- ប្រាក់បៀវត្សរបស់បុគ្គលិក និងចំណាយលើពលកម្មងទៀតដូចជា វិភាគទានសន្តិសុខសង្គមរបស់និយោជក និងវិភាគទាំនសន្តិសុខសង្គមរបស់និយោជិត។
- ប្រាក់ចំណេញប្រតិបត្តិការដុលរបស់សហគ្រាស (រួមមានប្រាក់ចំណេញ ថ្លៃឈ្នួល ការប្រាក់ និងរំលស់ជាដើម)។
- ចំណូលពន្ធដកការឧបត្ថម្ភធនលើផលិតផល។

#### ១.២.១.៣. ការវាស់តាមប្រាក់ចំណាយ(Expenditure Approach)

ការវាស់វែងពី GDP តាមរយៈប្រាក់ចំណាយមានន័យថា យើងធ្វើការវាស់ទៅលើការចំណាយមានធាតុផ្សំសំខាន់បួនដែលត្រូវបានគេបូកបញ្ចូលក្នុង GDPគឺ ៖ ការចំណាយប្រើប្រាស់

[15] សាស្ត្រាចារ្យម៉ម ចរិយារុធ, Principles of macroeconomics, 2011, ទំព័រទី៨

[16] បណ្ឌិត ហង់ ជួន ណារ៉ុង, ម៉ាក្រូសេដ្ឋកិច្ច, ២០០៩, ទំព័រទី៤

ការវិនិយោគ ការចំណាយសាធារណៈ និងការនាំចេញសុទ្ធ។ ដូច្នេះយើងបានសមីការដូចខាងក្រោម[17]៖

$Y = GDP = C + I + G + NX$

$C$ = ការចំណាយរបស់គ្រួសារ

$I$ = ការវិនិយោគ

$G$ = ការចំណាយសារធារណៈ

$NX = (X - M)$ ការនាំចេញសុទ្ធ

– ការចំណាយរបស់គ្រួសារ គឺជាការចំណាយរបស់គ្រួសារទៅលើទំនិញ និងសេវាកម្មក្នុងកំឡុងពេលជាក់លាក់មួយ។ ការចំណាយប្រើប្រាស់ត្រូវបានគេចែកជាបីក្រុមគឺ៖

- ទំនិញធនបានយូរ(durable goods) សំដៅលើទំនិញប្រើប្រាស់ដែលមានអាយុកាលវែងដូចជា រថយន្ត ទូរទស្សន៍ គ្រឿងសង្ហារឹមជាដើម។
- ទំនិញមិនធនបានយូរ(nondurable good) គឺជាទំនិញប្រើប្រាស់ទាំងឡាយណា ដែលអាយុកាលរបស់វាមានរយៈពេលខ្លី និងអាចជាតម្រូវការចាំបាច់សម្រាប់មនុស្សទូទៅដូចជាអាហារ សម្លៀកបំពាក់ ប្រេងឥន្ទនៈ ។ល។
- សេវាកម្ម មានដូចជា សេវាការអប់រំ សេវាថែទាំសុខភាព សេវាហិរញ្ញវត្ថុ និងការដឹកជញ្ជូនជាដើម។

– ការវិនិយោគ គឺជាចំណាយសរុបរបស់សហគ្រាសទាំងឡាយសម្រាប់ទិញរោងចក្រសម្ភារៈ និងការស្តុកថ្មីៗ និងការចំណាយគ្រួសារនានាសម្រាប់ទិញផ្ទះថ្មី។ វិនិយោគ ជាតម្លៃចល័ត(ភាគហ៊ុន សញ្ញាប័ណ្ណ...) ផលិផលសម្រាប់លក់បន្តនៃគ្រឿងបរិក្ខារ ដែលមានស្រាប់គេមិនគិតបញ្ចូលទេ។

– ការចំណាយសាធារណៈ គឺជាការចំណាយផ្សេងៗរបស់រដ្ឋាភិបាលទៅលើទំនិញ និងសេវាកម្មដែលត្រូវបានផលិតក្នុងពេលបច្ចុប្បន្ន ទាំងក្នុងស្រុក និងក្រៅប្រទេស។ ចំណាយនេះ ជាចំនួនទឹកប្រាក់សរុប ដែលស្ថាប័នគ្រប់ជាន់ថ្នាក់របស់រដ្ឋាភិបាលចំណាយចំពោះការទិញទ្រព្យសម្ភារៈ និងសេវាទាំងឡាយ។ និយមន័យនេះ មិនបានរាប់បញ្ចូលផងទេនូវការទូទាត់បង្វិលទៅឲ្យឯកជន ឬក៏ទូទាត់បង្វិលនៃអន្តររដ្ឋាភិបាល។

[17] Andrew B. Abel, Ben S. Bernanke, Dean Croushore (2000). Macroeconomics, 6th Edition. Published by Pearson Addision Wesley

ទន្ទឹមនឹងនោះ គួរកត់សម្គាល់ថា ចំណាយរដ្ឋាភិបាល ដែលផ្តោតទៅលើការវិនិយោគសាធារណៈ (ឧទា-ការវិនិយោគរបស់រដ្ឋាភិបាលទៅលើហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន សាលារៀន ឬក្នុងសកម្មភាពផ្សេងទៀត ដែលពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច)[18]។

– ការនាំចេញសុទ្ធ គឺស្មើនឹងការនាំចេញ ដកនឹងការនាំចូល។ ការនាំចេញ គឺជាទំនិញ និងសេវាកម្មដែលបានផលិតនៅក្នុងប្រទេសមួយ និងត្រូវបានទិញដោយបរទេស។ រីឯការនាំចូលសំដៅលើទំនិញ និងសេវាកម្មដែលផលិតនៅប្រទេសក្រៅ និងត្រូវបានទិញដោយប្រជាជនក្នុងប្រទេសមួយ។ ការនាំចេញសុទ្ធវិជ្ជមាននៅពេលដែលការនាំចេញមានភាពប្រសើរជាងការនាំចូល (ការនាំចេញលើសការនាំចូល) ហើយអវិជ្ជមានប្រសិនបើការនាំចូលច្រើនជាងការនាំចេញនោះ។ ការនាំចេញត្រូវបានគេបូកបន្ថែមទៅក្នុងចំណាយសរុប ព្រោះវាបង្ហាញពីការចំណាយ (ដោយបរទេស) ទៅលើទំនិញ និងសេវាកម្មចុងក្រោយដែលបានផលិតក្នុងប្រទេសមួយ។ ការនាំចូលត្រូវបានដកចេញពីការចំណាយសរុប ព្រោះការចំណាយប្រើប្រាស់ ការវិនិយោគ និងការចំណាយសាធារណៈ បានបូកបញ្ចូលទៅក្នុងទំនិញ និងសេវាកម្មដែលបាននាំចូល មានន័យថាត្រូវចំណាយទៅកាន់ប្រទេសក្រៅ។ ការដកការនាំចូលនេះ ដើម្បីធានាថាការចំណាយសរុប $C + I + G + NX$ មានឥទ្ធិពលតែទៅលើការចំណាយលើផលិតផលដែលបានផលិតនៅក្នុងប្រទេសតែប៉ុណ្ណោះ។ ជាឧទាហរណ៍ កំណើននៃការនាំចូលមានន័យថា សហរដ្ឋមេរិកកំពុងទិញរថយន្តពីជប៉ុន ជំនួសឲ្យរថយន្តអាមេរិកខ្លួនឯង។ ដូច្នេះ ការកើនឡើងការនាំចូលធ្វើឲ្យការចំណាយទៅលើផលិតកម្មក្នុងស្រុកទាបជាងមុន។

### ១.២.២. ភាពខុសគ្នានៃ ផ.ស.ស(GDP)និងកំណើនសេដ្ឋកិច្ច

ផ.ស.ស(GDP) គឺជាតម្លៃទីផ្សារនៃទំនិញ និងសេវាកម្មចុងក្រោយដែលបានផលិតក្នុងរយៈពេលជាក់លាក់មួយជាទូទៅកំឡុងពេលមួយឆ្នាំ។ ផ.ស.ស ធ្វើការវាស់វែងតែផលិតផលដែលបានផលិតក្នុងស្រុកតែប៉ុណ្ណោះ។

កំណើនសេដ្ឋកិច្ច គឺជាការកើនឡើងនៃលទ្ធភាពសេដ្ឋកិច្ចរបស់ប្រទេសមួយ ក្នុងការផលិតទំនិញ និងសេវាកម្មក្នុងកំឡុងពេលមួយ។ ម្យ៉ាងទៀត កំណើនសេដ្ឋកិច្ច គឺជាការកើនឡើងក្នុងផលិតភាពជារួមនៃសេដ្ឋកិច្ចមួយ។ គេវាស់វែងពីកំណើនសេដ្ឋកិច្ច តាមរយៈការកើនឡើង ឬ ក៏

[18] ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច, ភ្នំពេញ ២០០៤ ទំព័រ ៣៣៩

ថយចុះនៃ ផ.ស.ស ដូច្នេះគេអាចហៅបានជាកំណើន ផ.ស.ស។ គេអាចវាស់ពីកំណើនសេដ្ឋកិច្ច តាមរូបមន្តដូចខាងក្រោម៖[19]

$$Economic\ Growth\ rate = \frac{GDP\ in\ year\ 2 - GDP\ in\ year\ 1}{GDP\ in\ year\ 1} \times 100$$

### ១.២.៣. ផលិតផលជាតិសរុប

#### ១.២.៣.១. ការកំណត់ពីអត្ថន័យ (GNP)

ផលិតផលជាតិសរុប(GNP) គឺជាតម្លៃទីផ្សារនៃទំនិញ និងសេវាកម្មចុងក្រោយថ្មីៗ ដែលត្រូវបានផលិតដោយកត្តាផលិតកម្មរបស់ប្រទេសមួយក្នុងកំឡុងពេលជាលាក់មួយ[20]។ តម្លៃសរុបគណនាជារូបិយវត្ថុលើទំនិញ និងសេវា ដែលផលិតបាននៅក្នុងប្រទេសមួយនៅក្នុងរយៈពេលមួយកំណត់ (ឧទា-មួយឆ្នាំ)។ ផលិតផលជាតិសរុប ជាផលិតផលក្នុងស្រុកសរុប បូកជាមួយនឹងការប្រាក់ ប្រាក់ចំណេញ ភាគលាភ ដែលបានមកពីប្រទេសក្រៅ[21]។

#### ១.២.៣.២. ភាពខុសគ្នារវាង GDP និង GNP

ភាពផ្សេងគ្នារវាង GDP និង GNP ផ្អែកទៅលើផលិតផលដែលបានផលិតដោយមូលធន និងកម្លាំងពលកម្មដែលបានចូលរួមផលិតក្រៅប្រទេសកំណើតរបស់ខ្លួន។ ជាពិសេស GNP គឺជាតម្លៃទីផ្សារនៃទំនិញ និងសេវាកម្មចុងក្រោយដែលបានចូលរួមផលិតដោយកត្តាផលិតកម្មក្នុងស្រុក ខណៈដែល GDP សំដៅលើផលិតកម្មដែលផលិតនៅក្នុងប្រទេសមួយ។

ជាឧទាហរណ៍ នៅពេលដែលប្រទេសកម្ពុជាមានពលកម្ម និងមូលធន ដែលត្រូវបានគេហៅថា ជាកត្តាផលិតកម្ម ត្រូវបានគេប្រើប្រាស់នៅប្រទេសក្រៅ គឺមានន័យថាកម្ពុជាផលិតបាននូវទំនិញ និងរកចំណូលបានមកពីប្រទេសផ្សេងទៀតក្រៅពីប្រទេសរបស់ខ្លួន។ ផលិតផល និងចំណូលទាំងអស់នេះត្រូវបានរាប់បញ្ចូលទៅក្នុងផលិតផលជាតិសរុប(GNP) របស់ប្រទេសកម្ពុជា ប៉ុន្តែវាមិនត្រូវបានគេរាប់បញ្ចូលទៅក្នុងផលិតផលក្នុងស្រុកសរុប(GDP) របស់ប្រទេសកម្ពុជាឡើយ ដោយសារតែផលិតផល និងទំនិញទាំងនោះ គឺមិនត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជា។

---

[19] https://www.differencebetween.com/difference-between-economic-growth-and-vs-gdp

[20] Andrew B. Abel, Ben S. Bernanke, Dean Croushore (2000). Macroeconomics, 6th Edition. Published by Pearson Addision Wesley (page 31).

[21] ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច, ភ្នំពេញ ២០០៤ ទំព័រ ៣៤៧

### ១.២.៤. ភាពមិនសុក្រិតក្នុងការវាស់វែងពីកំណើនសេដ្ឋកិច្ចនៃ GDP

បញ្ហាមួយ ក្នុងការប្រើប្រាស់តម្លៃទីផ្សារដើម្បីវាស់វែងពីGDP គឺថា ទំនិញ និងសេវាកម្មមួយចំនួនមិនត្រូវបានលក់នៅក្នុងទីផ្សារជាផ្លូវការនោះទេ។ ប្រាកដណាស់ GDP គួរតែត្រូវបានគេកែតម្រូវឡើងវិញពាក់ព័ន្ធជាមួយនឹងទំនិញ និងសេវាកម្មទាំងអស់នេះ។ ទោះបីជាយ៉ាងនេះក្តី វានៅតែមានផលវិបាកនៃការរក្សាឲ្យបានក្នុងការវាស់វែងមួយដែលប្រកបដោយទំនុកចិត្តព្រោះថាទំនិញ និងសេវាកម្មមួយចំនួនមិនមានទីផ្សារ (nonmarket) គឺមិនត្រូវបានគេយកមកគណនានៅក្នុងGDP ទេ[22]។ ជាឧទាហរណ៍ ទំនិញដែលផលិតបានដោយគ្រួសារមួយចំនួនគឺមិនត្រូវបានលក់នៅលើទីផ្សារនោះទេ គឺគ្រួសារទាំងនោះផលិតបានមក ដើម្បីផ្គត់ផ្គង់តែតម្រូវការចាំបាច់ក្នុងគ្រួសាររបស់ពួកគេតែប៉ុណ្ណោះ។ រីឯ សេវាកម្មមួយចំនួនដូចជា សេវាថែទាំកុមារ និងការសម្អាតផ្ទះ គឺមិនត្រូវបានគេរាប់បញ្ចូលក្នុង GDP ឡើយព្រោះថា វាបានផលិតដោយគ្រួសារ និងមិនត្រូវបានគេដាក់លក់នៅក្នុងទីផ្សារនោះទេ ប៉ុន្តែ ប្រសិនបើសេវាកម្មទាំងអស់នេះ ត្រូវបានជួលដោយប្រើកម្លាំងពលកម្មខាងក្រៅផ្សេងទៀត នោះវានឹងមានការរួមចំណែកនៅក្នុង GDP ជាក់ជាពុំខាន។

### ១.២.៥. សមាសភាគនៃកំណើនសេដ្ឋកិច្ច

មានសមាសភាគបីយ៉ាង ដែលជាកត្តាចម្បងនៃកំណើនសេដ្ឋកិច្ចគឺ[23]៖

- ការកើនឡើងនៃទុន
- កំណើនប្រជាជន
- ការរីកចម្រើននៃបច្ចេកវិទ្យា

#### ១.២.៥.១. ការកើនឡើងនៃទុន

ការកើនឡើងនៃទុន បានមកតាមរយៈការសន្សំ ដែលជាចំណែកនៃប្រាក់ចំណូល និងវិនិយោគដើម្បីបង្កើនបរិមាណអាវត្ថុ (Output) និងចំណូលនាពេលអនាគត។ ការវិនិយោគទៅលើរោងចក្រថ្មី គ្រឿងម៉ាស៊ីន និងឧបករណ៍បរិក្ខារ បង្កើនស្តុកមូលធនរបស់ជាតិមួយ និងការពង្រីកនូវអាវត្ថុ។ ការវិនិយោគទៅលើផលិតកម្មដោយផ្ទាល់នេះ ត្រូវបានបំពេញបន្ថែមដោយការវិនិយោគដែលជាទូទៅគេហៅថា ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម ដូចជាផ្លូវថ្នល់ អគ្គិសនី ទឹកនិងអនាម័យ ទូរគមនាគមន៍ជាដើម ដែលជួយសម្រួលដល់សកម្មភាពសេដ្ឋកិច្ច។ ជាឧទាហរណ៍ កសិករម្នាក់ធ្វើការវិនិយោគ ទៅលើត្រាក់ទ័រថ្មីមួយ។ ការវិនិយោគនេះអាចនឹងបង្កើនបរិមាណអាវ

---

[22] www7.nationalacademies.org/cnstat/Nonmarket_Current.html.

[23] Michael P. Todaro and Stephen C. Smith (2000). Economic Development 8th Edition. Published by Pearson Addision Wesley (page 79).

ភុតនៃផលិតផលរបស់គាត់។ ទោះបីដូច្នេះក៏ដោយ បើគ្មានការសម្របសម្រួលណាមួយ (គ្មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់) ដើម្បីនាំយកអាវភុតដែលកើននេះ ទៅក្នុងទីផ្សារនោះ ការវិនិយោគរបស់គាត់ពិតជាមិនបានជួយអ្វី ដល់ការបង្កើនផលិតកម្មស្បៀងរបស់ជាតិបានទេ។

### ១.២.៥.២. កំណើនប្រជាជន

កំណើនប្រជាជន នាំទៅរកការកើនឡើងនៃកម្លាំងពលកម្ម ដែលត្រូវបានគេយល់ថាជាកត្តាវិជ្ជមាន ក្នុងការជម្រុញកំណើនស្នេកិច្ច។ កម្លាំងពលកម្មកាន់តែច្រើនមានន័យថា អ្នកធ្វើការផលិតកាន់តែច្រើន ហើយចំនួនប្រជាជនសរុបច្រើនបានបង្កើនសក្តានុពលនៃទីផ្សារក្នុងស្រុក។ ទោះបីជាយ៉ាងនេះក៏ដោយ មានសំណួរមួយបានលើកឡើងថា តើការកើនឡើងយ៉ាងលឿននៃការផ្គត់ផ្គង់កម្លាំងពលកម្ម នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានពលកម្មលើសជាសញ្ញាវិជ្ជមាន ឬអវិជ្ជមានទៅលើការអភិវឌ្ឍន៍? ជាក់ស្តែង វាគឺអាស្រ័យទៅលើសមត្ថភាពនៃប្រព័ន្ធសេដ្ឋកិច្ច ក្នុងការប្រើប្រាស់កម្លាំងពលកម្មបន្ថែមនេះ។ សមត្ថភាពនេះ ពាក់ព័ន្ធជាចាំបាច់ទៅនឹងអត្រា និងប្រភេទនៃការកើនឡើងនៃទុន បូករួមនិងកត្តាផ្សេងទៀតដូចជា ជំនាញនៃការគ្រប់គ្រង និងរដ្ឋបាល។

### ១.២.៥.៣. ការរីកចម្រើននៃបច្ចេកវិទ្យា

ការរីកចម្រើននៃបច្ចេកវិទ្យា ជាការប្រសើរឡើងក្នុងការធ្វើកិច្ចការអ្វីមួយ ដែលមានលក្ខណ:ប្រពៃណីដូចជា ការដាំដុះ កាត់ដេរសម្លៀកបំពាក់ ឬការសាងសង់ផ្ទះ។ ការរីកចម្រើនបច្ចេកវិទ្យាត្រូវបានបែងចែកជាបីក្រុមគឺ ការរីកចម្រើនបច្ចេកវិទ្យាមានលក្ខណ:ណឺត (Neutral) សន្សំសំចៃកម្លាំងពលកម្ម (Labor-saving) និងសន្សំសំចៃមូលធន (Capital-saving)។

- ការរីកចម្រើនបច្ចេកវិទ្យាមានលក្ខណ:ណឺត៖ កើតឡើងនៅពេលដែលកម្រិតនៃបរិមាណអាវភុតកើនឡើង ដោយសារតែការប្រើប្រាស់នូវការរួមបញ្ចូលនៃកត្តាផលិតកម្ម និងការប្រើប្រាស់បរិមាណនៃកត្តាផលិតកម្មក្នុងបរិមាណដដែល។
- ការរីកចម្រើនបច្ចេកវិទ្យាមានលក្ខណ:សន្សំសំចៃពលកម្ម គឺជាការកើនឡើងនូវគ្រឿងម៉ាស៊ីន ឧបករណ៍បរិក្ខារទំនើបៗដូចជា កុំព្យូទ័រ ត្រាក់ទ័រ...ដែលចំណាយកម្លាំងពលកម្មតិច ប៉ុន្តែទទួលបានទន្និផលខ្ពស់។
- ការរីចម្រើនបច្ចេកវិទ្យាមានលក្ខណ:សន្សំសំចៃមូលធន កើតមានឡើងដោយកម្រពីព្រោះថា ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ស្ទើរតែទាំងអស់នៅលើពិភពលោក តាមរយ:ប្រទេសអភិវឌ្ឍន៍ គឺធ្វើយ៉ាងណាសន្សំសំចៃកម្លាំងពលកម្ម មិនមែនសន្សំសំចៃមូលធននោះទេ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកត្តាទាយជួយទាន (មូលធនកម្រ) ការរីកចម្រើនបច្ចេកវិទ្យាដោយសន្សំសំចៃមូលធន គឺជាអ្វីដែលត្រូវការចាំបាច់បំផុតដូចជា ការរីកចម្រើនបានមកពីប្រសិទ្ធភាព (ថ្លៃដើមទាបជាងមុន) នៅក្នុងផលិតកម្មអតិពលកម្ម។

## ១.៣. តួនាទីសំខាន់របស់រដ្ឋាភិបាលនៅក្នុងកំណើនសេដ្ឋកិច្ច

ទោះបីជាសន្សំ និងការវិនិយោគ ដែលនាំឲ្យផលិតភាពមានការកើនឡើង នៅក្នុងខឿនសេដ្ឋកិច្ច មួយផ្នែកធំធ្វើឡើងដោយផ្នែកឯកជន ហើយដូចគ្នានេះដែរកំណើនប្រជាជនគឺជាសេចក្តីសម្រេចចិត្ត និងត្រូវបានអនុវត្តន៍ដោយក្រុមគ្រួសារក៏ដោយ ក៏តួនាទី ព្រមទាំងឥទ្ធិពលរដ្ឋាភិបាលមានសារៈសំខាន់ណាស់ នៅក្នុងការបង្កើនអត្រាកំណើនសេដ្ឋកិច្ច និងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ បញ្ហានេះ ភាគច្រើនប្រឈមមុខដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច[24]។

– ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន កំពុងជួបប្រទះនូវអស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច។ បញ្ហាទាំងនេះសុទ្ធតែជាឧបសគ្គដែលរារាំងដល់កំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាលរឹងមាំនិងមានអំណាច អាចធានាបង្កើននូវសន្តិភាព និងការអនុវត្តច្បាប់បានល្អ ព្រមទាំងមានការឯកភាពបង្រួបបង្រួមជាតិនៅក្នុងប្រទេស។ បញ្ហានេះសំខាន់ណាស់ ព្រោះវាបង្កើននូវបរិយាកាសធ្វើការ និងការខិតខំប្រឹងប្រែងដែលជាកម្លាំងជម្រុញកំណើនសេដ្ឋកិច្ច។

– ការគ្មានសមត្ថភាព ឬទុនខ្សោយផ្នែកឯកជន នៅក្នុងការអនុវត្តតួនាទីជាសហគ្រិនដែលត្រៀមខ្លួន និងមានសមត្ថភាពរៀបចំបង្កើនទុន និងទទួលយកគំនិតផ្តើមរៀបចំវិនិយោគដែលត្រូវការ ដើម្បីបង្កើនល្បឿនកំណើនសេដ្ឋកិច្ច។ សកម្មភាពរដ្ឋាភិបាលនៅក្នុងផ្នែកអាជីវកម្ម ដែលធ្វើការវិនិយោគផ្ទាល់ និងរៀបចំផលិតកម្ម គឺជាអ្នកជំនួសព្រមទាំងបំពេញសកម្មភាពសហគ្រាសឯកជនជាពិសេសទាក់ទងទៅនឹងសហគ្រាសវិនិយោគធំៗ ដែលប្រឈមមុខនឹងហានិភ័យខ្ពស់។

– ការលូតលាស់សេដ្ឋកិច្ច គឺជាលទ្ធផលនៃការបង្កើនទុន និងវិយោគដែលធ្វើឡើងជាចម្បងដោយផ្នែកឯកជន ដែលអាចបង្កើនផលិតភាពសេដ្ឋកិច្ច។ បញ្ហានេះ មិនអាចសម្រេចបានទេ នៅពេលដែលគ្មានការគាំទ្រដោយទំនិញ និងសេវាកម្មរបស់សង្គម ដូចជាអនាម័យ និងកម្មវិធីបម្រើសុខភាពជាមូលដ្ឋានរបស់ប្រជាជន ការអប់រំ ប្រព័ន្ធធារាសាស្ត្រ ផ្លូវ និងបរិស្ថាន ព្រមទាំងជាមធ្យោបាយទំនាក់ទំនងបណ្តាកម្មវិធីបណ្តុះបណ្តាលជំនាញ និងកម្មវិធីផ្សេងទៀត ដែលផ្តល់ផល

[24]ពោ ប៊ុណ្ណា, ម៉ាក្រូសេដ្ឋកិច្ចវិទ្យា ទ្រឹស្តី និងគោលនយោបាយ ឆ្នាំ២០០២ទំព័រ១៧៦, វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា

ប្រយោជន៍ដល់ប្រជាជន។ បញ្ហាទាំងអស់នេះ មិនអាចផ្តល់ដោយផ្នែកឯកជនដែលធ្វើឲ្យពួកគេបានចំណេញតាមរយៈយន្តការទីផ្សារនេះ។ ដូច្នេះ រដ្ឋាភិបាលដើរតួនាទីសំខាន់ និងត្រូវគិតគូរពីបញ្ហានេះ។

– សន្សំ-វិនិយោគរបស់ប្រជាជន (ផ្នែកឯកជន) ទាប គឺជាចំណុចកណ្តាល ឬកត្តា ដែលបណ្តាលឲ្យកើតមាននូវទុគ្រោះនៃភាពក្រីក្រ ដែលរាំងស្ទះដល់កំណើនសេដ្ឋកិច្ច។ ដូចយើងបានដឹងហើយថា បញ្ហានេះកើតឡើងដោយសារចំណូលទាប និងឥទ្ធិពលគ្រាប់តាមបណ្តាប្រទេសរីកចម្រើនក្នុងការប្រើប្រាស់ដោយក្រុមអ្នកមាន ដែលជាក់ស្តែងអាចសន្សំ។ ដូច្នេះ មានតែរដ្ឋាភិបាលទេ ដែលជាភាគីមួយអាចមានលទ្ធភាពបង្ខំប្រជាជន ឬខឿនសេដ្ឋកិច្ចឲ្យសន្សំតាមរយៈសកម្មភាព ឬគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ។ វិធីមួយក្នុងចំណោមវិធីទាំងអស់ គឺតាមរយៈការបង្កើនអត្រា និងប្រភេទពន្ធដែលបន្ទាប់មក នឹងផ្ទេរទៅគម្រោងវិនិយោគ ដែលជាអាទិភាព។ បញ្ហានៅត្រង់ថា តើមានភាពស្មោះត្រង់ និងមានប្រសិទ្ធភាពក្នុងការអនុវត្ត ឬអត់។ គោលនយោបាយផ្សេងទៀតគឺ គោលនយោបាយរូបិយវត្ថុ ដែលបង្កើនអតិផរណា និងបង្ខំឲ្យប្រជាជនសន្សំ។ រដ្ឋាភិបាលធ្វើការវិនិយោគលើគម្រោងអាទិភាព ដែលទូទាត់ដោយការបោះពុម្ពលុយ។ បញ្ហានេះ គឺជាពន្ធដែលយកពីប្រជាជន ពីព្រោះពួកគេកាន់កាប់លុយ ប្រឈមមុខនឹងការចុះតម្លៃ ដែលបណ្តាមកពីអតិផរណា។ វិធីចុងក្រោយនេះ ទោះបីជាងាយស្រួល ប៉ុន្តែវាមិនសូវជាបានការល្អទេ ដោយវាបណ្តាលឲ្យមានការងាកចេញពីទិសដៅវិនិយោគឯកជន ដែលងាកចេញពីផ្នែកវិនិយោគខាងផលិតកម្ម ហើយដែលនឹងនាំឲ្យរាំងស្ទះការលូតលាស់សេដ្ឋកិច្ច។

– ឧបសគ្គចម្បងនៅក្នុងការបង្កើនកម្រិតជីវភាពរបស់នៅរបស់ប្រជាជន គឺចំនួនប្រជាជនច្រើនពេក ហើយអត្រាកំណើនលឿនខ្លាំង។ កម្មវិធីរបស់រដ្ឋាភិបាល ត្រូវជម្រុញឲ្យកាត់បន្ថយអត្រាកំណើនប្រជាជនយ៉ាងលឿនខាងលើ តាមកម្មវិធីផែនការគ្រួសារ។ ដូចគ្នានេះដែរ រដ្ឋាភិបាលអាចអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍កសិកម្ម ឬតំបន់ជនបទ ដែលអាចទប់ស្កាត់ការផ្លាស់ទីលំនៅរបស់ប្រជាជនពីជនបទទៅទីក្រុង និងមូលហេតុដែលនាំឲ្យមានបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ច។

– រដ្ឋាភិបាលអាចលើកទឹកចិត្ត និងស្មារតី ដើម្បីជម្រុញគោលដៅកំណើនសេដ្ឋកិច្ចឲ្យលឿន។ បញ្ហានេះ មិនត្រឹមតែត្រូវការអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ (បង្កើនសមត្ថភាពផលិតរបស់ប្រជាជន ដូចជាធនធានធម្មជាតិ និងធនធានមនុស្ស ទុន និងបច្ចេកវិទ្យា) ប៉ុណ្ណោះទេ គឺត្រូវផ្អែកផងដែរទៅលើកត្តាតម្រូវការ ទាំងតម្រូវការក្នុងស្រុក និងតម្រូវការក្រៅប្រទេស។ នៅពេលគ្មានការបង្កើនតម្រូវការ នាំឲ្យការកើនឡើងនូវសក្តានុពលផលិតកម្មមិនអាចផ្តល់ជាលទ្ធផលជាក់ស្តែងទេ។ បដាពាក្យ

ស្លោក សំណូមពរឬការផ្សព្វផ្សាយឲ្យប្រើប្រាស់ផលិតផលក្នុងស្រុក ព្រមទាំងលើកទឹកចិត្ត ដែលផ្តល់ឲ្យសហគ្រាសដោយរដ្ឋាភិបាល គឺជាសកម្មភាពដើម្បីបង្កើនតម្រូវការ ដែលមានប្រយោជន៍ដើម្បីធានាដល់កំណើនសេដ្ឋកិច្ច។

# ជំពូកទី២

# ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ១៩៩៥ ដល់ឆ្នាំ ២០១៧

## ២.១. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ១៩៩៥-២០១៧

### ២.១.១. ដំណាក់ការនៃកំណើនសេដ្ឋកិច្ច

ចាប់តាំងពីឆ្នាំ១៩៨៩ ប្រទេសកម្ពុជាបានអនុវត្តការកែទម្រង់ជាច្រើន ដើម្បីផ្លាស់ប្តូរពីផែនការប្រមូលផ្តុំមកជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចទីផ្សារវិញ (មាត្រា៥៦ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ)[25]។ ទាំងនេះរួមបញ្ចូលទាំងការអនុវត្តកម្មសិទ្ធិឯកជនទៅលើទ្រព្យសម្បត្តិ សេរីភាវូបនីយកម្មថ្លៃ និងពាណិជ្ជកម្មយ៉ាងលឿន ការធ្វើឲ្យរូបិយប័ណ្ណអាចដោះដូរបាន ការបើកទូលាយទីផ្សារក្នុងស្រុកដល់ធុរកិច្ចឯកជន ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនរដ្ឋ ការលុបបំបាត់ភាពផ្តាច់មុខក្នុងឧស្សាហកម្ម និងសេវាកម្ម និងកំណែទម្រង់បទដ្ឋានគណនេយ្យ ប្រព័ន្ធពន្ធដារ ប្រព័ន្ធច្បាប់ និងវិស័យហិរញ្ញវត្ថុ។

ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាអាចចែកចេញជាដំណាក់កាលបីខុសៗគ្នា[26]៖

- ដំណាក់កាលស្តារនិងនិតិសម្បទាន ក្នុងឆ្នាំ១៩៨៩-១៩៩៨
- ដំណាក់កាលស្ថាបនាឡើងវិញ ក្នុងឆ្នាំ១៩៩៩-២០០៣
- ដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤-២០០៨

**ដំណាក់កាលស្តារនិងនីតិសម្បទាន ក្នុងឆ្នាំ១៩៨៩-១៩៩៨៖** ការកកើតដំបូងនៃសេដ្ឋកិច្ចទីផ្សារត្រូវបានចាប់ផ្តើមបង្កើតឡើង ដោយការទទួលស្គាល់កម្មសិទ្ធិឯកជន ឯកជនភាវូបនីយកម្មនៃក្រុមហ៊ុនរដ្ឋ និងបដិសម្ភូហាភាវូបយនីកម្មកសិកម្ម ពោលគឺដើម្បីត្រួសត្រាយផ្លូវសម្រាប់ការផ្សះផ្សារ និងបង្រួបបង្រួមជាតិ និងរៀបចំការបោះឆ្នោតសកលនៅក្នុងឆ្នាំ១៩៩៣។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងអនុវត្តកំណែទម្រង់ទីផ្សារបានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដោយសារអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ដែលបណ្តាលមកពីកត្តាមួយចំនួនដូចខាងក្រោមនេះ (ធនាគារពិភពលោក ឆ្នាំ១៩៩២)៖

- សេរីភាវូបនីយកម្មសេដ្ឋកិច្ច ដែលចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៨៩ ធ្វើឲ្យរាំងស្ទះដល់ការប្រមូលចំណូល និងធ្វើឲ្យថវិកាជាតិបាត់តុល្យភាព។ ឯកជនភាវូនីយកម្មនិងកំណែទម្រង់សហគ្រាសរដ្ឋ និងសេរីភាវូបនីយកម្មតម្លៃនិងពាណិជ្ជកម្ម បានកាត់បន្ថយចំណូលពុំមែន

[25] រដ្ឋធម្មនុញ្ញទាំងឡាយនៃកម្ពុជា ខែ កញ្ញា ឆ្នាំ២០១១

[26] បណ្ឌិត ហង់ ជួន ណារ៉ុង "សេដ្ឋកិច្ចកម្ពុជា", ឆ្នាំ២០១៥ ទំព័រ៥៣

សារពើពន្ធ ដែលធ្លាប់តែជាប្រភពយ៉ាងសំខាន់សម្រាប់ថវិកាជាតិ។ ការខាតបង់ចំណូលនេះមិនអាចប៉ះប៉ូវបានវិញ ដោយចំណូលសារពើពន្ធ ដែលប្រមូលបានពីវិស័យឯកជនដែលកំពុងងើបឡើងនោះទេ។ ចំណូលថវិកាពីសហគ្រាសសាធារណៈនៅក្នុងចំណូលសរុបនៃថវិកាចរន្ត បានធ្លាក់ចុះពី៣៦% នៃចំណាយសរុបក្នុងឆ្នាំ១៩៨៩ ដល់ ២២% ក្នុងឆ្នាំ១៩៩១។ ការអនុវត្តពន្ធថ្មីចូលវិភាគទានបានតិចតួចប៉ុណ្ណោះដល់ថវិកា។ ចំណូលមិនមែនពន្ធបានធ្លាក់ចុះពី៥.៥% នៃចំណាយថវិកា ក្នុងឆ្នាំ១៩៨៩ រហូតដល់ក្រោម១% ក្នុងឆ្នាំ១៩៩១។ ប៉ុន្តែការលុបចោលនូវការលើលែងពន្ធគយ នាំឲ្យបង្កើនចំណូលពន្ធដារពី៨.៥% នៃចំណាយថវិកា ក្នុងឆ្នាំ១៩៨៩ ដល់ ៣៧% ក្នុងឆ្នាំ១៩៩១។

- ចំពោះខាងផ្នែកចំណាយថវិកា ការលុបចោលការត្រួតពិនិត្យថ្លៃនៃទំនិញបានធ្វើឲ្យថ្លៃនៃទំនិញក្នុងមួយឯកតា ដែលផ្គត់ផ្គង់សម្រាប់ចំណាយប្រតិបត្តិការ និងការវិយោគបានកើនឡើងខ្ពស់។ គោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីជៀសវាងការកាត់បន្ថយប្រាក់បៀវត្សរ៍ និងចំណាយយោធា បានដាក់សម្ពាធលើចំណាយវិនិយោគសាធារណៈ ចំណាយប្រតិបត្តិការ និងចំណាយថែទាំ។ ចំណែកនៃចំណាយទាំងនេះក្នុងថវិកាបានធ្លាក់ចុះពី៤១% ក្នុងឆ្នាំ១៩៨៩ ដល់១៦% ក្នុងឆ្នាំ១៩៩១។
- ការលុបចោលជំនួយឥណទាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការទូទាត់ឆ្នាំ១៩៨៦-១៩៩០ រវាងកម្ពុជា និងសហភាពសូវៀត។ ជំនួយជាទំនិញប្រើប្រាស់ដែលទទួលបានក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងមានចំណែកស្មើនឹង ១៥% នៃចំណាយថវិកាក្នុងឆ្នាំ១៩៨៩។ ជំនួយមនុស្សធម៌មានចំនួនត្រឹមតែ ២០-៣០ លានដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះក្នុងមួយឆ្នាំ ក្នុងឆ្នាំ១៩៩១-១៩៩២។
- ស្ថិតក្នុងកាលៈទេសៈបែបនេះ រដ្ឋាភិបាលពឹងផ្អែកលើការបោះផ្សាយក្រដាសប្រាក់ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា។ ការធ្វើហិរញ្ញប្បទានដោយបោះផ្សាយក្រដាសប្រាក់មានចំណែកជាងពាក់កណ្តាលនៃឱនភាពថវិកាក្នុងឆ្នាំ១៩៩១ ហើយកង្វះខាតសាច់ប្រាក់ស្មើនឹង២០% នៃថវិកាដែលសេសសល់។ ការបើកប្រាក់បៀវត្សរ៍ក៏មិនបានទៀងទាត់។ ការធ្វើហិរញ្ញប្បទានដោយបោះផ្សាយក្រដាសប្រាក់ បណ្តាលឲ្យមានអតិផរណាខ្ពស់ដែលមានអត្រាមធ្យម៧០% ក្នុងឆ្នាំ១៩៨៩ និង១៥៧% ក្នុងឆ្នាំ១៩៩០ និង១២១% ក្នុងឆ្នាំ១៩៩១។ បញ្ហាទាំងនេះ បណ្តាលឲ្យសាធារណៈជនលែងមានការជឿទុកចិត្តមកលើរូបិយវត្ថុជាតិ ដែលជាហេតុធ្វើឲ្យមានដុល្លារូបនីយកម្មខ្ពស់។

ការបង្កើតរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៣ បានឈានទៅបញ្ចប់ទណ្ឌកម្មសេដ្ឋកិច្ច ដែលដាក់មកលើកម្ពុជាតាំងពីឆ្នាំ១៩៧៩មកនោះ និងនាំឲ្យមានការហូរចូលនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេស និងជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ការស្តារនីតិសម្បទានសេដ្ឋកិច្ច។ ក្នុងកំឡុងឆ្នាំ ១៩៩៣-១៩៩៨ប្រទេសកម្ពុជាមិនទាន់មានសន្តិភាពពេញលេញនៅឡើយទេ។ អណត្តិដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជាមិនអាចផ្តល់អាទិភាពពេញលេញលើការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្របានឡើយ ដោយសារតែរាជរដ្ឋាភិបាលត្រូវ ប្រយុទ្ធគ្នាជាមួយកងកម្លាំងរបស់ខ្មែរក្រហម ដែលមាននៅពាសពេញផ្ទៃប្រទេស។ ចំណាយការពារជាតិ និងសន្តិសុខ មានចំនួន៦.៣% នៃផលិតផលក្នុងស្រុកសរុប(GDP) ក្នុងឆ្នាំ១៩៩៤ ចំណែកឯចំណាយលើវិស័យសង្គមមានតែ២.១% ប៉ុណ្ណោះ។ ប៉ុន្តែពេលនោះ ក៏នៅមានការយកចិត្តទុកដាក់ដើម្បីអនុវត្តកំណែទម្រង់ជំនាន់ទីមួយផងដែរ។ អតិផរណាត្រូវបានគ្រប់គ្រងបាន ហើយធ្លាក់ចុះពី១២១% នៅឆ្នាំ១៩៩១ មកត្រឹម -0.៧% ក្នុងឆ្នាំ១៩៩៣។ ប្រព័ន្ធថវិកាថ្មីមួយដែលផ្អែកលើមូលដ្ឋានបារាំងត្រូវបានឲ្យអនុវត្ត ហើយក្របខ័ណ្ឌគតិយុត្តិសម្រាប់សហគ្រាសសាធារណៈត្រូវបង្កើតឡើង។

បន្ទាប់ពីការដាក់ឲ្យអនុវត្តនូវគោលនយោបាយ "ឈ្នះ-ឈ្នះ" របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន អង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហម ត្រូវបានរំលាយចោលក្នុងឆ្នាំ ១៩៩៨។ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី១ បានរៀបចំមូលដ្ឋានគ្រឹះសម្រាប់សន្តិភាព សន្តិសុខ និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ទោះបីជាមានបញ្ហាប្រឈមខ្លះក៏ដោយ កំណើនសេដ្ឋកិច្ចក្នុងកំឡុងឆ្នាំ១៩៩៤-១៩៩៨ សម្រេចបាន៦.៣% ជាមធ្យម។ កំណើនក្នុងរយៈពេលនេះត្រូវបានផ្តល់ហិរញ្ញប្បទានភាគច្រើន ពីការប្រើប្រាស់ធនធានធម្មជាតិហួសកម្រិត ជំនួយអភិឌ្ឍន៍ផ្លូវការ (ODA) និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេស ទៅក្នុងវិស័យហិរញ្ញវត្ថុ។ វិស័យដែលលេញធ្លោជាងគេគឺព្រៃឈើ កៅស៊ូ សេវាសាធារណៈ រដ្ឋបាលសាធារណៈ និងធនាគារ។ តម្លៃបន្ថែមផ្នែកព្រៃឈើបានកើនឡើងជាមធ្យម១៧.២% ក្នុងមួយឆ្នាំ ដោយផលិតផលឈើ ក្រដាស និងការបោះពុម្ពផ្សាយបានកើនឡើង២២.៩% ក្នុងមួយឆ្នាំ។ ការផលិតកៅស៊ូបានកើនឡើង២១.៩%។ ក្នុងកំឡុងឆ្នាំ១៩៩៤-១៩៩៨ ភាគច្រើននៃជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានយកមកប្រើប្រាស់ ដើម្បីស្តារឡើងវិញនូវសមត្ថភាពទាញយកថាមពលអគ្គិសនី និងការផ្គត់ផ្គង់ទឹក។ អគ្គិសនី ឧស្ម័ន និងទឹកដែលជាអនុវិស័យនៃការផលិតបានកើនឡើងនៅអត្រាមធ្យមប្រចាំឆ្នាំ១៤.៩%។ រដ្ឋបាលសាធារណៈបានកើនឡើងចំនួន ២០.៨% ហើយវិស័យហិរញ្ញវត្ថុបានកើនឡើង ៣៨.៥%។

**ដំណាក់កាលស្តាបនាឡើងវិញក្នុងឆ្នាំ១៩៩៩-២០០៣៖** ប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការអនុវត្ត *យុទ្ធសាស្ត្រត្រីកោណ* ដែលបានអនុម័តដោយរដ្ឋាភិបាលនីតិកាលទី២(ឆ្នាំ១៩៩៩-២០០៣)។ ស្ថេរភាពនយោបាយត្រូវបានស្តារឡើងវិញ និងស្ថាប័នប្រជាធិបតេយ្យត្រូវបានបង្កើតឡើង។ ដំណាក់កាលនេះបានបង្កើតកាលានុវត្តភាព ដែលមិនធ្លាប់មានសម្រាប់កំណែទម្រង់សេដ្ឋកិច្ចនិងវឌ្ឍនភាពសង្គម។ កម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ខ្លួនឡើងវិញ បន្ទាប់ពីព្រឹត្តិការណ៍ប្រយុទ្ធគ្នានៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ ហើយកម្ពុជាបានទទួលមកវិញនូវអសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិក្នុងខែធ្នូឆ្នាំ១៩៩៨ និងបានចូលជាសមាជិកផ្លូវការរបស់អាស៊ាននៅក្នុងខែមេសាឆ្នាំ១៩៩៩។ កម្ពុជាចាប់ផ្តើមធ្វើកំណែទម្រង់ទ្រង់ទ្រាយធំ ដោយផ្តោតទៅលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិស័យធនាគារនិងហិរញ្ញវត្ថុ និងការស្តារនីតិសម្បទា និងស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលជាបណ្តាញផ្លូវជាតិ។ កំណែទម្រង់សេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលអនុវត្តក្នុងឆ្នាំ១៩៩៩-២០០៣ ជាពិសេសការពង្រឹងកំណែទម្រង់ទីផ្សារទៅតាមទ្រឹស្តីសេរីភាវូបនីយកម្មសេដ្ឋកិច្ច ក្នុងគោលដៅធានាការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចខ្ពស់។ អភិក្រមសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនេះ សង្កត់ធ្ងន់លើកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ចយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចដោយផ្អែកលើការនាំចេញ និងគុណភាពនៃស្ថាប័ន ដូចឃើញមាននៅតាមបណ្តាប្រទេសមួយចំនួននៅអាស៊ីបូព៌ា ជាពិសេសការគោរពវិន័យថវិកាដ៏ម៉ឹងម៉ាត់ ការពង្រឹងប្រព័ន្ធតុលាការ ផលិតភាពពលកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការរក្សាអត្រាប្តូរប្រាក់ឲ្យមានលក្ខណៈប្រកួតប្រជែង ការធ្វើឲ្យមានការទាក់ទាញដល់វិនិយោគិនក្រៅប្រទេស ការលើកម្ពស់ការនាំចេញ និងសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក។

កំណើនសេដ្ឋកិច្ចនៅកំឡុងឆ្នាំ១៩៩៩-២០០៣ សម្រេចបានជាមធ្យម៨.៨%។ ទោះបីជាជំនួយអភិវឌ្ឍន៍ផ្លូវការបន្តផ្គត់ផ្គង់ដល់កំណើនយ៉ាងណាក្តី ការវិនិយោគផ្ទាល់ក្រៅប្រទេស ជាពិសេសក្នុងផ្នែកកាត់ដេរនិងទេសចរណ៍ គឺជាកូនសោរសម្រាប់ជំរុញកំណើន។ វិស័យដែលលេចធ្លោរជាងគេមានស្រូវអង្ករ និងផលិតកម្មដំណាំរួមផ្សំ សេវាសាធារណៈ សំណង់ ទេសចរណ៍ទូរគមនាគមន៍ ការដឹកជញ្ជូន និងអចលនទ្រព្យ។ ការធ្លាក់ចុះនៃតម្លៃបន្ថែមដែលបណ្តាលមកពីផ្នែករុក្ខាប្រមាញ់ ត្រូវប៉ះប៉ូវមកវិញបានដោយសារលក្ខណៈល្អប្រសើរខាងផលិតកម្មស្រូវនិងដំណាំរួមផ្សំ ដែលកើនឡើងជាមធ្យម៦.៥% ក្នុងមួយឆ្នាំ។ វិស័យវាយនភ័ណ្ឌបានកើនឡើងចំនួន៣៥.១% ក្នុងមួយឆ្នាំ។ ការបន្តស្តារនីតិសម្បទាខាងផ្នែកថាមពលនិងទឹក ធ្វើឲ្យអនុវិស័យអគ្គិសនី

ឧស្ម័ននិងទឹកកើនឡើងជាមធ្យម១០.២% ក្នុងមួយឆ្នាំ។ វិស័យសំណង់ក្លាយជាសសរទ្រូងនៃកំណើន ដោយកើនឡើងជាមធ្យម២០.១%។ សន្តិភាពដែលបានបង្កើតឲ្យមានការកើនឡើងនេះជួយដល់ការអភិវឌ្ឍយ៉ាងឆាប់រហ័សខាងទេសចរណ៍ ដោយវិស័យនេះកើនឡើងជាមធ្យម១៣.៦%ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ អនុវស័យទូរស័ព្ទចល័តក៏មានការអភិវឌ្ឍខ្លាំងផងដែរ។ ចំណែកឯវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ បានកើនឡើងជាមធ្យម១២.១% ក្នុងមួយឆ្នាំ។ ផ្នែកអចលនវត្ថុក៏កើនឡើងយ៉ាងឆាប់រហ័សដោយកើនដល់១២.១% នៅដើមដំបូងពេលមានការរីកចម្រើនខ្លាំងក្នុងផ្នែកអចលនវត្ថុ។

**ដំណាក់កាល់ហក់ឡើងនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៣-២០០៨៖** រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីអនុវត្តកំណែទម្រង់ជំនាន់ទី២ ដូចដែលមានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ជាពិសេសការអនុវត្តដំណាក់កាលទី១ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបន្តវិនិយោគក្នុងការស្តាបនាផ្លូវថ្នល់នៅតាមបណ្តាខេត្តនិងទីជនបទ។ កំណើនសេដ្ឋកិច្ចក្នុងកំឡុងឆ្នាំ២០០៤-២០០៨ សម្រេចបានជាមធ្យម១០.៣%។ ប្រការនេះ គឺជាលើទីមួយហើយដែលប្រទេសកម្ពុជាសម្រេចបានកំណើនលេខពីរខ្ទង់ ដែលកំណើននេះបានមកពីហិរញ្ញប្បទានវិស័យធនាគារ ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស និងលំហូរការវិនិយោគផ្ទាល់ពីក្រៅប្រទេស។ វិស័យដែលលេចធ្លោរជាងគេមានផ្នែកស្រូវអង្ករ និងដំណាំរួមផ្សំ (កំណើនប្រចាំឆ្នាំជាមធ្យម៩.៧%) អាជីវកម្មរ៉ែ ១៨.២% វាយនភ័ណ្ឌ ១៦.១% សេវាសាធារណៈ ១៦.៧% សំណង់ ១៥.៥% ទេសចរណ៍ ១៧.៤% ទូរគមនាគមន៍និងដឹកជញ្ជូន ៨.៣% ហិរញ្ញវត្ថុ ២១.៦% និងអចលនវត្ថុ ១២.៤%។

### ២.១.២. ការប្រាស្រ័យទាក់ទងនៃសេដ្ឋកិច្ចកម្ពុជា និងសេដ្ឋកិច្ចសកល

ក្នុងឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានវាយតម្លៃថាមានលក្ខណៈល្អប្រសើរ និងមានសន្ទុះខ្លាំងជាងឆ្នាំមុនៗ ហើយក៏ជាឆ្នាំទីមួយក្រោយវិបត្តិហិរញ្ញវត្ថុសកល ដែលស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់បានបង្ហាញសញ្ញាវិជ្ជមាននៅលើវិថីថ្មីនៃកំណើន ប្រកបដោយភាពរឹងមាំសម្រាប់រយៈពេលមធ្យមទៅមុខ។ ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចសកល ត្រូវបានប៉ាន់ស្មានថាមានកំណើន ៣.៧% នៅឆ្នាំ២០១៧ និង ៣,៩% នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលគាំទ្រដោយការកើនឡើងនៃសកម្មភាពវិនិយោគ ពាណិជ្ជកម្ម ក៏ដូចជាទំនុកចិត្តក្នុងការធ្វើធុរកិច្ច និងការប្រើប្រាស់របស់ប្រទេសក្នុងតំបន់អាស៊ី សហភាពអឺរ៉ុប និងអាមេរិក និងភាពរឹងមាំនៃសេដ្ឋកិច្ចចិន។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចសកលក៏ប្រឈមនឹងភាពមិនច្បាស់លាស់មួយចំនួន ពាក់ព័ន្ធនឹងគោល

នយោបាយសេដ្ឋកិច្ច គោលនយោបាយពាណិជ្ជកម្ម និងស្ថានភាពហិរញ្ញវត្ថុនៃបណ្តាប្រទេសធំៗ ដែលបង្កជាហានិភ័យដល់លំហូរទំនិញ លំហូរទុនវិនិយោគ និងប្រតិបត្តិការហិរញ្ញវត្ថុសកល។

ទោះបីជាសេដ្ឋកិច្ចពិភពលោក និងតំបន់មានភាពប្រសើរឡើងដែលផ្តល់នូវបច្ច័យជាវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាជារួមក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យមួយចំនួនផងដែរ រួមមាន៖ ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៃប្រទេសអភិវឌ្ឍន៍ ភាពមិនប្រាកដប្រជានៃផលប៉ះពាល់ពីការចាក់ចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក កំណើនឆាប់រហ័សនៃឥណទានក្នុងប្រទេសចិន ការបន្តនិន្នាការនៃគោលនយោបាយគាំពារនិយម និងបញ្ហាដែលពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ ភេរវកម្ម និងសន្តិសុខជាសកល។ ទន្ទឹមនឹងនេះ កម្ពុជាក៏ជួបនូវបញ្ហាប្រឈម និងហានិភ័យក្នុងស្រុកមួយចំនួន រួមមាន៖

- ថ្លៃអគ្គិសនីដែលនៅមានកម្រិតខ្ពស់ និងការផ្គត់ផ្គង់នៅមិនទាន់មានស្ថេរភាព
- ភាពនៅទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក
- ផលិតភាពពលកម្មទាប និងកង្វះពលកម្មជំនាញ
- នីតិវិធីស្មុគស្មាញ និងកម្រៃសេវាក្រៅផ្លូវការខ្ពស់សម្រាប់ធ្វើធុរកិច្ច
- កម្រិតខ្ពស់នៃថ្លៃម្ហូបអាហារនៅកម្ពុជា និង
- កំណើនឆាប់រហ័សនៃឥណទានធនាគារក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ។

សម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខ កម្ពុជានឹងបោះជំហានទៅដំណាក់កាលថ្មីមួយទៀត ដែលវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាកាន់តែដើរតួនាទីសំខាន់ ក្នុងយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ ក្នុងបរិការណ៍ដែលភាពប្រកួតប្រជែងក្នុងតំបន់ និងពិភពលោក កាន់តែស្រួចស្រាល់។ ដើម្បីបន្តសម្រេចបានកំណើនរឹងមាំក្នុងរង្វង់ ៧.០% ប្រកបដោយចីរភាព បរិយាប័ន្ន និងធន់នឹងវិបត្តិ កម្ពុជាចាំបាច់ត្រូវអនុវត្តគោលនយោបាយ និងវិធានការគន្លឹះមុតស្រួចមួយចំនួនប្រកបដោយឆន្ទៈនយោបាយខ្ពស់ សំដៅដោះស្រាយបញ្ហាប្រឈម និងបញ្ចៀសនូវហានិភ័យទាំងឡាយជាយថាហេតុ និងបន្តកែទម្រង់តាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ក្រោមគោលការណ៍ "**បន្តរក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី**"[27]។

[27] ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩

### ២.១.៣. កំណើនផលិតផលក្នុងស្រុកសរុប

យោងតាមការវាយតម្លៃរបស់ធនាគារពិភពលោកនៅឆ្នាំ២០១៥ ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ជាប្រទេសឯកត្តករមួយ សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង។ ក្នុងរយៈពេល ២ទសវត្សចុងក្រោយនេះ អត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំមានកម្រិតប្រមាណ ៧.៧% ហើយអត្រាកំណើនដ៏គួរជាទីមោទនៈនេះ ត្រូវបានរំពឹងថានឹងរក្សាសន្ទុះបន្តទៀតសម្រាប់រយៈពេលមធ្យមខាងមុខ។ នៅឆ្នាំ២០១៥ ទោះបីសេដ្ឋកិច្ចសកលលោកមិនទាន់រឹងមាំក្តី ក៏កម្ពុជាអាចរក្សាបានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% កម្រិតអតិផរណាទាបប្រមាណ ១.២% និងអត្រាប្តូរប្រាក់មានស្ថេរភាពក្នុងរង្វង់ ៤,០៥០ រៀលក្នុង ១ដុល្លារអាមេរិក។ ឱនភាពថវិកាជាតិបានធ្លាក់ចុះជាលំដាប់មកត្រឹមជិត ៣% ក្នុងឆ្នាំ២០១៥ តាមរយៈការខិតខំប្រឹងប្រែងអនុវត្តកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស អនុវត្តយុទ្ធសាស្ត្រកៀងគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ក៏ដូចជាការបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយឱនភាពគណនីចរន្តបានបន្តកាត់បន្ថយជាបន្តបន្ទាប់។[28]

ក្រាហ្វិកទី១៖ ផ.ស.ស ប្រចាំឆ្នាំតាមថ្លៃបច្ចុប្បន្ន គិតជាលានដុល្លារ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ(ឆ្នាំ២០១៦), ការព្យាករណ៍របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១៦-២០១៧)*

[28] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥

* ការគណនាដោយយក (*GDP of* 2016 × *GDP growth rate of* 2017) + *GDP of* 2016

តាមក្រាហ្វិកទី១ ផ.ស.ស ក្នុងប្រទេសកម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ក្នុងកម្រិតមួយគួរឲ្យគត់សម្គាល់។ នៅក្នុងឆ្នាំ២០០០ ផ.ស.ស ក្នុងប្រទេសមានប្រមាណតែជាង ៧,៦៨៩ ដុល្លារ តែប៉ុណ្ណោះ ដែលស្ថិតក្នុងកម្រិតមួយទាបដែលអាចនិយាយបានថា ជាប្រទេសមួយដែលមានប្រាក់ចំណូលកម្រិតទាប និងរហូតមកដល់ឆ្នាំ២០០៨ ផ.ស.ស ក្នុងប្រទេសមានការកើនឡើងរហូតដល់ទៅប្រមាណជា ១០,៣៣៧លានដុល្លារ និងនៅឆ្នាំ២០០៩ មានចំនួនប្រហាក់ប្រហែលនិងឆ្នាំ២០០៨ ដែរ មានប្រមាណជា ១០,៤០០លានដុល្លារ ស្ថិតក្នុងអត្រាកំណើនត្រឹមតែ0,១% (សូមមើលក្នុងក្រាហ្វិកទី២) ដោយសារតែសេដ្ឋកិច្ចកម្ពុជាបានទទួលរងឥទ្ធិពលពីវិបត្តិហិរញ្ញវត្ថុពិភពលោក នៅក្នុងឆ្នាំ២០០៨។ក្រោយពីវិបត្តិហិរញ្ញវត្ថុពិភពលោកត្រូវបានបញ្ចប់ កម្ពុជាបានស្តារនូវសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ដោយសម្រេចបាន ផ.ស.ស ប្រមាណជាង ២១,៣៩៧លានដុល្លារ នៅក្នុងឆ្នាំ២០១៧។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ២០១៧ មានភាពល្អប្រសើរ ដោយសេដ្ឋកិច្ចបន្តសម្រេចបានកំណើនប្រមាណ ៦.៩% ដែលគាំទ្រដោយកំណើនរឹងមាំនៃវិស័យសំណង់ ការបន្តកំណើននៃវិស័យកាត់ដេរ និងវិស័យកសិកម្ម និងការងើបឡើងខ្លាំងនៃវិស័យទេសចរណ៍ និងវិស័យលក់ដុំ-រាយ។ ទោះជាយ៉ាងនេះក្តី វិស័យកម្មន្តសាលនៅកម្ពុជាដែលផ្តោតលើផលិតកម្មតម្លៃបន្ថែមទាប និងកំណើនយឺតនៃវិស័យកាត់ដេរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បង្ហាញពីភាពចាំបាច់និងបន្ទាន់ក្នុងការកែទម្រង់រចនាសម្ព័ន្ធ និងពិពិធកម្មសេដ្ឋកិច្ច ទៅរកវិស័យកាត់ដេរដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យសក្តានុពលផ្សេងទៀត ដើម្បីបន្តធានាចីរភាពកំណើនក្នុងរយៈពេលមធ្យម និងវែង។ ក្នុងឆ្នាំ២០១៨ និង២០១៩ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនក្នុងរង្វង់ប្រមាណ ៧.០% ដែលទ្រទ្រង់ដោយមូលដ្ឋានកំណើនស្រដៀងទៅនឹងឆ្នាំ ២០១៧[29]។

[29] ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩

ក្រាហ្វិកទី២៖ កំណើនផ.ស.ស ប្រចាំឆ្នាំ គិតជាភាគរយ




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១០-២០១៦), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១៨), IMF DataMapper (April 2018)*

### ២.១.៤. កំណើន ផ.ស.ស ជាមធ្យមសម្រាប់មនុស្សម្នាក់

ជាលទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចល្អប្រសើរ អត្រាភាពក្រីក្រនៅកម្ពុជា ត្រូវបានកាត់បន្ថយគួរឲ្យគត់សម្គាល់ ដោយសម្រេចបានគោលដៅអភិវឌ្ឍន៍សហវត្សក្នុងការកាត់បន្ថយភាពក្រីក្របានប្រមាណ ៤% ក្នុងមួយឆ្នាំ ដែលធ្វើឲ្យអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងលឿនពី ៥៣% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣.៥% ក្នុងឆ្នាំ២០១៤។ ផលិតផលក្នុងស្រុកសរុបគិតជាមធ្យមសម្រាប់មនុស្សម្នាក់បានកើនពី៤៨៧ ដុល្លារនៅឆ្នាំ២០០៥ ដល់ប្រមាណ ១,២១៥ ដុល្លារនៅឆ្នាំ២០១៥[30]។

សម្រាប់រយៈពេល ៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧.០% ប្រកបដោយបរិយាប័ន្ន និងសមធម៌។ កម្ពុជាថែមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីឋានៈប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ជាផ្លូវការក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវចាត់ទុកថាជា "ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី" ក្នុងឆ្នាំ២០១៦។

30 ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥

ក្រាហ្វិកទី៣៖ កំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារ)




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០០០-២០១៦), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ឆ្នាំ២០១៧)*

កំណើនដ៏គួរឲ្យស្ញប់ស្ញែងនេះ បានបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារពិភពលោកដែលបានបង្ហាញថា ភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាស្ថិតក្នុងអត្រា 0.៣% និងភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ២០១៧។ ទន្ទឹមនេះ ប្រាក់ចំណូលរបស់ប្រជាជនក៏មានការកើនឡើងផងដែរ ដោយផ.ស.ស ក្នុងមនុស្សម្នាក់កើនពី ១,០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១,៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ដូចបានបង្ហាញនៅក្នុងក្រាហ្វិកទី៣ខាងលើ និងត្រូវបានរំពឹងថានឹងទទួលបាន ១,៥៦៣ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៨[31]។

## ២.២. ចលករនៃកំណើនសេដ្ឋកិច្ច

### ២.២.១. ការចំណាយប្រើប្រាស់របស់គ្រួសារ

នៅក្នុងឆ្នាំ២០១៦ ការចំណាយប្រើប្រាស់របស់គ្រួសារក្នុងប្រទេសកម្ពុជាគឺ ប្រមាណជាង ១៥,២៣៦ លានដុល្លារ។ បើគិតពីចន្លោះឆ្នាំ១៩៩៧ និងឆ្នាំ២០១៦ ការចំណាយប្រើប្រាស់របស់គ្រួសារបានកើនពី ៣,១១២ លានដុល្លារ មកដល់ចំនួនប្រមាណជា ១៥,២៣៦ លានដុល្លារ ដែលជាការកើនឡើងនៃអត្រាបម្រែបម្រួលប្រចាំឆ្នាំអតិបរមារហូតដល់ទៅ ២១.៨១% នៅក្នុងឆ្នាំ២០០៨ និងបន្ទាប់មកបានធ្លាក់ចុះមកត្រឹម ៩.៩១% នៅក្នុងឆ្នាំ២០១៦។ (សូមមើលក្រាហ្វិកទី៤ ខាងក្រោម សម្រាប់ព័ត៌មានបន្ថែម)

[31] ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩

ក្រាហ្វិកទី៤៖ ការចំណាប្រើប្រាស់របស់គ្រួសារ (C) គិតជាដុល្លារ




*ប្រភព៖ DataBank, World Bank Group 2016*

អត្រាបម្រែបម្រួលនៃការប្រើប្រាស់របស់គ្រួសារនៅក្នុងប្រទេសកម្ពុជា មានការកើនឡើងខ្ពស់នៅក្នុងឆ្នាំ២០០៨ ដែលមានរហូតដល់ទៅចំនួន ២១.៨១% ដែលជាអត្រាកំណើនខ្ពស់បំផុតបើធៀបទៅនឹងឆ្នាំដ៏ទៃទៀត។ ដោយឡែក នៅក្នុងឆ្នាំ២០០៩ អត្រាបម្រែបម្រួលនេះមាននិន្នាការធ្លាក់ចុះយ៉ាងគំហុករហូតដល់ -៣.៦៧% នៅក្នុងឆ្នាំ២០០៩ (ដូចមានបង្ហាញក្នុងក្រាហ្វិកទី៥ ខាងក្រោម) និងងើបឡើងវិញនៅក្នុងឆ្នាំ២០១០ ប្រមាណជា១៥.៣៦% និងឆ្នាំ២០១១ មានចំនួន១៦.៣២%។ ក្រោយមកចាប់ពីឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០១៦ មានការប្រែប្រួលកើនឡើង និងថយចុះបន្តិចបន្តួច ដោយមានចំនួន ៩.៩១% ក្នុងឆ្នាំ២០១៦។

ក្រាហ្វិកទី៥៖ អត្រាបម្រែបម្រួលនៃការចំណាយប្រើប្រាស់របស់គ្រួសារ(គិតជា%)




*ប្រភព៖ DataBank, World Bank Group 2016*

### ២.២.២. ការវិនិយោគ (I)

ការវិនិយោគ នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាកត្តាមួយដ៏សំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ គិតចាំពីឆ្នាំ២០០៥ រហូតដល់ ឆ្នាំ២០១៦ ការវិនិយោគមានការកើនឡើងគួរឲ្យគត់សម្គាល់ ដោយកើនពីចំនួនជាង ១,៣៥៦ លានដុល្លារ ដល់ចំនួនប្រមាណជា ៥,៨៧៦ លានដុល្លារ។

ក្រាហ្វិកទី៦៖ ការវិនិយោគសរុប (គិតជាដុល្លារ)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៧*

ទន្ទឹមនឹងនេះ ការកើនឡើងនៃការវិនិយោគនៅប្រទេសកម្ពុជាមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយឡែក ការវិនិយោគមានការធ្លាក់ចុះមកត្រឹមចំនួនជាង ៤,៩៨០ លានដុល្លារ ក្នុងឆ្នាំ២០១៤ ដែលថយចុះពីចំនួនជាង ៥,០៤៣ លានដុល្លារ ក្នុងឆ្នាំ២០១៣ ដោយមានការប្រែប្រួលអវិជ្ជមាន ១.២៦% (មើលក្នុងក្រាហ្វិកទី៧)។ ការធ្លាក់ចុះ មួយផ្នែកធំអាចបណ្តាលមកពីនៅក្នុងឆ្នាំ២០១៤ គឺជាឆ្នាំដែលស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជាមានភាពក្តៅគគុក ក្រោយការបោះឆ្នោត ឆ្នាំ២០១៣ ដែលជាហេតុធ្វើឲ្យវិនិយោគិនទាំងក្នុង និងក្រៅប្រទេសមានការរារែកចំពោះការបណ្តាក់ទុន។

ក្រាហ្វិកទី៧៖ អត្រាបម្រែបម្រួលនៃការវិនិយោគសរុប (គិតជា%)




*ប្រភព៖ DataBank, World Bank Group 2016*

### ២.២.២.១. ការវិនិយោគផ្ទាល់ពីបរទេស (FDI)

ការវិនិយោគផ្ទាល់ពីបរទេស ដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ជាពិសេសការជម្រុញកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន និងការកាត់បន្ថយភាពក្រីក្រ។ ស្ថិតក្នុងលក្ខខណ្ឌសេដ្ឋកិច្ចបើកចំហរ កម្ពុជាបានទទួល និងរំពឹងថាមានការទាក់ទាញការហូរចូលការវិនិយោគផ្ទាល់ពីបរទេសប្រមាណជា ១០% នៃ ផ.ស.ស ក្នុងមួយឆ្នាំ ជាពិសេសនៅចន្លោះឆ្នាំ ២០១៣ និង ២០១៨។

ផ្អែកតាមទិន្នន័យ ត្រីមាសទី៣ ឆ្នាំ២០១៧ ឃើញថា ការវិនិយោគផ្ទាល់ពីបរទេសមានការកើនឡើងចំនួន ២,០៧៧ លានដុល្លារ ឬ ប្រហែល ២៨.៣% បើធៀបនឹងឆ្នាំ២០១៦ មានចំនួនតែ ១,៦៣០ លានដុល្លារ ក្នុងកំឡុងពេលដូចគ្នា (ប្រហែល ២០.៧%) ការកើនឡើងដ៏ច្រើននេះដោយសារតែការវិនិយោគលើសកម្មភាពហិរញ្ញវត្ថុ (រួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ដែលបន្តកើនឡើងខ្ពស់មានចំនួន ៣៣.% ការវិនិយោគផ្ទាល់ពីបរទេសសម្រាប់រយៈពេល ៣ត្រីមាសដំបូងក្នុងឆ្នាំ២០១៧។ ការវិនិយោគផ្ទាល់ពីបរទេស ទៅលើផលិតកម្មក៏នៅតែមានកំណើនខ្លាំងផងដែរ ដែលមានចំណែកធំទីពីរ (១១%) នៃការវិនិយោគផ្ទាល់ពីបរទេស(Q3-2017) និងការវិនិយោគធំបន្ទាប់ទៅលើកន្លែងស្នាក់នៅ (សូមមើលតារាងទី១)[32]។

[32] Cambodia Macroeconomic Report Assessment 2017, Ministry of Economic and Finance

ក្រាហ្វិកទី៨៖ **Value and Growth of FDI Inflow as of Q3-2017 (US million)**




Source: NBC, 2017

តារាងទី១៖ **Share of FDI Inflow as of Q3-2017**

| Share of FDI inflow as of Q1-2017 | 2013 | 2014 | 2015 | 2016 | 2017 |
|---|---|---|---|---|---|
| **Agriculture** | 15.3% | 16.9% | 14.6% | 10.3% | **8.5%** |
| **Manufacturing** | 26.6% | 30.5% | 26.6% | 16.6% | **11.1%** |
| **Financial Activities** | 17.5% | 19.1% | 30.3% | 28.2% | **33.0%** |
| **Acommodation** | 6.0% | 8.1% | 9.7% | 11.1% | **9.4%** |
| **Other** | 34.6% | 25.5% | 18.9% | 33.7% | **-37.9%** |

**Source: NBC, 2017**

### ២.២.២.២. ឧស្សនៈពាក់ព័ន្ធនឹងការវិនិយោគ

បញ្ហាប្រឈមនៅបន្តមានដើម្បីបង្កើតបរិយាកាសអំណោយផលដល់ការវិនិយោគ តាមរយៈការពង្រឹងប្រព័ន្ធតុលាការនិងអភិបាលកិច្ចល្អ ព្រមទាំងសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីផ្តល់សេវាអតិបរមាសម្រាប់វិស័យឯកជន។ ការអភិវឌ្ឍន៍ធនធានមនុស្សក៏ត្រូវបញ្ចូលក្នុងក្របខ័ណ្ឌនេះផងដែរ។ ឧទាហរណ៍ដ៏ស័ក្តិសម គឺបង្កើតគ្រឹះស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ខ្លួននៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលកំពុងបណ្តុះបណ្តាលនិយោជិតផ្នែកការិយាល័យជាច្រើននាក់ ដោយមានការជួយឧបត្ថម្ភគាំទ្រពីម្ចាស់ជំនួយជាច្រើន និងវិស័យឯកជន។

មានទស្សនៈពីរពាក់ព័ន្ធនឹងការលើកទឹកចិត្តដល់ការវិនិយោគ ដែលបានផ្តល់ឲ្យដល់វិនិយោគិន[33]៖

- ទស្សនៈទី១៖ ប្រទេសកម្ពុជាពុំមានចំណុចទាក់ទាញណាមួយដល់វិនិយោគិនក្រៅពីការលើកទឹកចិត្តផ្នែកពន្ធទេ។ បរិយាកាសទូទៅដូចជាស្ថេរភាពនយោបាយ សន្តិសុខចំពោះរូបរាងកាយ សណ្តាប់ធ្នាប់សង្គម ក្របខ័ណ្ឌច្បាប់ និងស្ថាប័នរចនាសម្ព័ន្ធ (ទឹក អគ្គិសនី ផ្លូវ) ធនធានមនុស្ស និងទីផ្សារខាងក្រៅពុំមានលក្ខណៈអំណោយផលច្រើនដូចនៅប្រទេសជិតខាងទេ។ មិនតែប៉ុណ្ណោះ ប្រទេសអាស៊ានទាំងអស់បានចាត់វិធានការច្បាស់លាស់រួមទាំងផ្តល់ការលើកទឹកចិត្តខាងផ្នែកពន្ធដើម្បីទាក់ទាញវិនិយោគ។ ដូច្នេះប្រសិនបើគ្មានការលើកទឹកចិត្តខាងផ្នែកពន្ធសម្រាប់ការវិនិយោគទេ ប្រទេសកម្ពុជានឹងមិនអាចទាក់ទាញវិនិយោគផ្ទាល់ពីប្រទេសក្រៅបានទេ។
- ទស្សនៈទី២៖ កិច្ចខិតខំប្រមូលថវិកានៅព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតទាបនៅឡើយគឺមានតែ១៣% នៃ ផ.ស.ស ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងមធ្យមភាគក្នុងតំបន់ដែលមានពី២០% ទៅ២៥% នៃផ.ស.ស។ ទោះបីជាប្រទេសក្នុងតំបន់បានចាត់វិធានការច្បាស់លាស់ដើម្បីទាក់ទាញវិនិយោគ ក៏ច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈសេរីជាងបើប្រៀបធៀប នឹងប្រទេសនៅក្នុងតំបន់។ គេមិនអាចទាក់ទាញការវិនិយោគបានទេ បើគ្រាន់តែមានការលើទឹកចិត្តពន្ធ ប៉ុន្តែគ្មានបរិយាកាសអំណោយផលជាទូទៅ ដូចជាស្ថេរភាពនយោបាយ សន្តិសុខចំពោះរូបរាងកាយ សណ្តាប់ធ្នាប់សង្គម ក្របខ័ណ្ឌច្បាប់ និងស្ថាប័នរចនាសម្ព័ន្ធ (ទឹក អគ្គិសនី ផ្លូវ) ធនធានមនុស្សនិងទីផ្សារខាងក្រៅ។ រាជរដ្ឋាភិបាលគប្បីចាត់វិធានការដើម្បីកែលម្អបរិយាកាសទូទៅសម្រាប់ការវិនិយោគ និងមិនគប្បីលើកលែងពន្ធចំណូល ដែលកំពុងត្រូវការខ្លាំងបំផុត ដោយសារតែចង់លើកទឹកចិត្តដល់ការវិនិយោគនោះទេ។ ដូច្នេះ រដ្ឋាភិបាលគប្បីចាត់វិធានការពង្រឹងចំណូល តាមរយៈការរឹតបន្តឹង និងការធ្វើវិចារណកម្មលើកទឹកចិត្ត ដើម្បីប្រមូលធនធានបន្ថែមយកមកជួយពង្រឹងស្ថាប័នរដ្ឋាភិបាល បង្កើតការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការស្រាវជ្រាវទីផ្សារ។ លើសពីនេះទៅទៀត ប្រសិនបើវិនិយោគិនទទួលបានការអនុគ្រោះពន្ធនៅកម្ពុជា ពួកគេនឹងត្រូវមានកាតព្វកិច្ចបង់ពន្ធទាំងនេះនៅប្រទេសរបស់ខ្លួនពួកគេជាស្វ័យប្រវត្តិ។ បើធ្វើដូច្នេះវាមិន

[33] បណ្ឌិត ហង់ ជួន ណារ៉ុង "សេដ្ឋកិច្ចកម្ពុជា", ឆ្នាំ២០១៥ ទំព័រ៥៣

ខុសអ្វីពីការបង្វិលជំនួយបញ្ច្រាសទៅវិញនោះទេ ឧទាហរណ៍ធនធានហិរញ្ញវត្ថុពីកម្ពុជានឹងហូរទៅក្រៅទៅបង្កើនចំណូលពន្ធនៃប្រទេសអភិវឌ្ឍន៍ទាំងនោះទៅវិញ។ ជាលទ្ធផលគេត្រូវដាក់ចេញភ្លាមៗនូវវិធានការដើម្បីរឹតបន្តឹងការលើទឹកចិត្តពន្ធនេះ គឺដើម្បីការបង្ការការបង្វិលជំនួយបរទេសបញ្ច្រាសទៅវិញនេះឯង ត្បិតកម្ពុជាជាប្រទេសក្រីក្រ តែបែរជាមានកាតព្វកិច្ចក្នុងការផ្តល់ជំនួយថវិកាទៅជួយឧបត្ថម្ភដល់ប្រទេសអភិវឌ្ឍន៍ទៅវិញ។

### ២.២.៣. ការចំណាយសាធារណៈ

នៅក្នុងឆ្នាំ២០១៦ កន្លងទៅ ការចំណាយសាធារណៈរបស់ប្រទេសកម្ពុជាមានចំនួនប្រមាណជា ១,០៤២ លានដុល្លារ។ នៅចន្លោះឆ្នាំ២០០៥ និងឆ្នាំ២០១៦ ការចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាលបានកើនឡើងពីចំនួនជាង ២៥៦លានដុល្លារ ដល់ចំនួនប្រមាណជា ១,០៤២ លានដុល្លារដោយមានការកើនឡើងនូវការចំណាយជារៀងរាល់ឆ្នាំ។

ក្រាហ្វិកទី៩៖ ការចំណាយសាធារណៈ (G) គិតជាដុល្លារ




*ប្រភព៖ DataBank, World  Bank Group 2016*

ក្នុងការចំណាយសាធារណៈរបស់រដ្ឋាភិបាល ពីឆ្នាំ២០០៦ រហូតដល់ ឆ្នាំ២០១៦ ឃើញថាមានអត្រាកើនឡើងខ្ពស់នៅក្នុងឆ្នាំ២០០៧ ដែលមានរហូតដល់ទៅចំនួន ២៩.០០%។ ប៉ុន្តែ អត្រាបម្រែបម្រួលនេះបានធ្លាក់ចុះមកយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០០៩ មានចំនួនត្រឹមតែ ៩.៩០% ដែលអត្រានេះមាននិន្នាការធ្លាក់ជាលំដាប់ជារៀងរាល់ឆ្នាំ (សូមមើលក្រាហ្វិកទី១០) ដោយឃើញថា នៅក្នុងឆ្នាំ២០១៦ មានការប្រែប្រួលកើនឡើងបន្តិចបន្តួចត្រឹមតែចំនួន ២.០៣% តែប៉ុណ្ណោះ ដោយសារ

សេដ្ឋកិច្ចប្រទេសកម្ពុជាមានភាពល្អប្រសើរជាងមុន ដូច្នេះហើយការចំណាយរបស់រដ្ឋត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំ។

ក្រាហ្វិកទី១០៖ អត្រាបម្រែបម្រួលនៃការចំណាយសាធារណៈ (គិតជា%)




*ប្រភព៖ DataBank, World Bank Group 2016*

### ២.២.៤. ការនាំចេញសុទ្ធ

#### ២.២.៤.១. ការនាំចេញ

ការនាំចេញនៅក្នុងប្រទេសកម្ពុជា គិតចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៦ មានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១៦ មានទឹកប្រាក់ចំនួន ១២,២៦៦ លានដុល្លារ។ នៅចន្លោះឆ្នាំ២០០៥ ដល់ឆ្នាំ២០១៦ បានកើនឡើងពីចំនួនប្រមាណជាង ៤,០៣២ លានដុល្លារ រហូតដល់ចំនួនជាង ១២,២៦៦ លានដុល្លារ (ដូចមានបង្ហាញក្នុងក្រាហ្វិកទី១១ ខាងក្រោម)។

ក្រាហ្វិកទី១១៖ ការនាំចេញ (Export) គិតជាដុល្លារ




*ប្រភព៖ DataBank, World Bank Group 2016*

ការនាំចេញរបស់ប្រទេសកម្ពុជាមានអត្រាបម្រែបម្រួលខ្ពស់នៅក្នុងឆ្នាំ២០០៦ ដោយកម្ពុជាទទួលបានការអនុគ្រោះក្នុងការនាំចេញបណ្តាប្រទេសដូចជា សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលជាការអំណោយផលដល់ការនាំចេញផ្នែកសម្លៀកបំពាក់ និងវាយនភ័ណ្ឌ។ ទន្ទឹមនឹងនេះ ការនាំចេញរបស់ប្រទេសកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០០៩ (-២៤.៥៤%) ដោយសារតែពិភពលោកជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៨ ដែលវាជះឥទ្ធិពលដល់ការប្រើប្រាស់ជាអន្តរជាតិ (សូមមើលក្នុងក្រាហ្វិកទី១២)។

ក្រាហ្វិកទី១២៖ អត្រាបម្រែបម្រួលនៃការនាំចេញ (គិតជា%)




*ប្រភព៖ DataBank, World Bank Group 2016*

ការនាំចេញទំនិញសរុបរបស់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០១៧ ត្រូវបានរំពឹងថានឹងរក្សាបានការកើនឡើងរហូតដល់ ១៧.៥% ដែលការកើនឡើងទាំងអស់នេះ ដោយសារតែការកើនឡើងនូវអត្រានៃការនាំចេញខ្ពស់នៃផលិតផលមិនមែនកាត់ដេរ និងកំណើននៃការនាំចេញផលិតផលកាត់ដេរបន្តិចបន្តួច។ នៅក្នុងរយៈពេល ១១ខែ ដំបូងទិន្នន័យនៃការនាំចេញបានបង្ហាញពីការកើនឡើងយ៉ាងសំខាន់នូវការនាំចេញផលិតផលមិនមែនកាត់ដេរ និងមិនមែនជាមាស ដូចជាគ្រឿងអគ្គិសនី កង់ ជ័រកៅស៊ូ និងស្រូវ អង្ករ ជាដើម ប្រមាណជា ២០.២% ក្នុងឆ្នាំ២០១៧ បើធៀបនឹងឆ្នាំ២០១៦ មានត្រឹមតែ ៦.២% សម្រាប់កំឡុងពេលដូចគ្នា។ ជាមួយគ្នានេះ ការនាំចេញវិស័យកាត់ដេរមានការកើនឡើងអត្រានាំចេញតិចតួច ៧.២% ក្នុងឆ្នាំ២០១៧ ដែលធ្លាក់ចុះពី ៨.៤% នៅក្នុងឆ្នាំ២០១៦។ ការធ្លាក់ចុះនេះអាចបណ្តាលមកពីការធ្លាក់ចុះក្នុងការនាំចេញទៅកាន់ដៃគូពាណិជ្ជកម្មសំខាន់ៗ ដូចជា សហភាពអឺរ៉ុប និងជប៉ុន។ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជានៅតែស្ថិតនៅក្រោមសម្ពាធដោយសារតែការកើនឡើងប្រាក់ឈ្នួលអប្បបរមា ភាពខ្សោយក្នុងការប្រកួតប្រជែងរបស់កម្ពុជា ជាមួយប្រទេសវៀតណាម ភូមា និងប៉ង់ក្លាដេស[34]។

**តារាងទី២៖ Growth of Export Compositions and Garment Export Destinations**

| | 2012 | 2013 | 2014 | 2015 | 2016 | 2016(11M) | 2017(11M) |
|---|---|---|---|---|---|---|---|
| **Commodity Groups Export (Growth in percent)** | | | | | | | |
| **Garment** | 7.3 | 17.8 | 10.7 | 14.5 | 9.1 | 8.4 | 7.2 |
| **Others (exel. gold)** | 47.2 | 61.8 | 31.8 | 14.2 | 6.2 | 6.2 | 20.2 |
| **Garment Export by destinations (Growth in percent)** | | | | | | | |
| **EU** | 18.3 | 26.0 | 22.0 | 20.8 | 16.1 | 15.8 | 8.7 |
| **US** | -4.7 | 6.0 | -5.4 | 2.3 | -8.5 | -10.1 | 3.9 |
| **Japan** | 19.0 | 59.3 | 37.5 | 36.8 | 25.4 | 26.5 | 5.0 |
| **ASEAN** | 100.3 | 70.6 | 38.3 | 24.1 | -4.8 | -4.7 | 7.2 |
| **Others** | 17.0 | 19.5 | 12.4 | 14.2 | 15.3 | 14.8 | 8.7 |
| **Commodity Groups Export (Share in percent)** | | | | | | | |
| **Garment** | 82.0 | 77.1 | 73.5 | 73.7 | 73.1 | 73.1 | 72.3 |
| **Others (exel. gold)** | 17.7 | 22.9 | 26.0 | 25.9 | 25.0 | 24.9 | 27.7 |
| **Exports by destinations (Share in percent)** | | | | | | | |
| **EU** | 32.1 | 33.4 | 34.1 | 37.9 | 38.8 | 38.6 | 38.7 |
| **US** | 36.7 | 31.4 | 26.7 | 23.9 | 20.9 | 20.8 | 21.6 |
| **Japan** | 3.5 | 4.8 | 5.7 | 6.8 | 8.2 | 8.3 | 7.6 |
| **ASEAN** | 7.2 | 9.3 | 11.7 | 11.1 | 10.3 | 10.4 | 9.7 |

[34] Cambodia Macroeconomic Report Assessment 2017, Ministry of Economic and Finance

| | | | | | | | |
|---|---|---|---|---|---|---|---|
| **Others** | 20.5 | 21.1 | 21.8 | 20.2 | 21.9 | 21.9 | 22.4 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១៧)*

### ២.២.៤.១. ការនាំចូល

ប្រទេសកម្ពុជា ជាប្រទេសមួយដែលភាគច្រើនមានការនាំចូលច្រើនជាងការនាំចេញ ដោយសារតែការផ្គត់ផ្គង់ក្នុងស្រុក មិនអាចបំពេញតម្រូវការក្នុងស្រុកបាន។ ការនាំចូល របស់ប្រទេសកម្ពុជាមានរហូតដល់ទៅចំនួនប្រមាណជាង ១៣,១៤៤ លានដុល្លារ។ បើគិតពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៦ មានការកើនឡើងពីចំនួនប្រមាណជាង ៤,៥៧៨ លានដុល្លារ ដល់ ១៣,១៤៤ លានដុល្លារ។ ការនាំចូលនេះ ទៀតសោត មានការធ្លាក់ចុះនៅក្នុងកំឡុងឆ្នាំ២០០៩ អាចបណ្តាលមកពីការកើនឡើងថ្លៃនៃទំនិញ និងសេវាកម្មជារួម ក្រោយពេលដែលពិភពលោកបានជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៨។ ដូចមានបង្ហាញក្នុងក្រាហ្វិកទី១៥ ការនាំចូលរបស់ប្រទេសកម្ពុជាមាននិន្នាការធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់ -១៧.១០% នៅក្នុងឆ្នាំ២០០៩។ ប៉ុន្តែ វាមានការកើនឡើងវិញផងដែរ ក្នុងឆ្នាំក្រោយៗបន្តបន្ទាប់។

ក្រាហ្វិកទី១៣៖ ការនាំចូល (Import) គិតជាដុល្លារ




*ប្រភព៖ DataBank, World Bank Group 2016*

ក្រាហ្វិកទី១៨៖ អត្រាបម្រែបម្រួលនៃការនាំចូល (គិតជា%)




ការនាំចូលក្នុងឆ្នាំ២០១៧ ត្រូវបានរំពឹងទុកថានឹងកើនចំនួន ១២.៥% កើនពីចំនួន៦.១% នៅឆ្នាំមុន ដោយសារតែកំណើនខ្ពស់នៃការនាំចូលទំនិញប្រើប្រាស់ (អាហារ, ភេសជ្ជៈ, ឱសថ និង បារី) រថយន្ត និងផលិតផលផ្សេងៗទៀត និងកំណើននៃការនាំចូលសម្ភារៈសំណង់ និងសម្ភារៈកាត់ដេរ បើទោះបីជាមានការធ្លាក់ចុះការនាំចូលប្រេងឥន្ធនៈក៏ដោយ។ ក្នុងឆ្នាំ២០១៧ (១១ខែដំបូង) ទំនិញប្រើប្រាស់បានបង្ហាញថា មានការកើនឡើងខ្ពស់ប្រហែលជា ១៩.៨% បើប្រៀបធៀបនឹងឆ្នាំ២០១៦ មានចំនួន ៩.១% ខណៈដែលការនាំចូលសម្ភារៈសំណង់ឃើញថា មានកំណើនទាបប្រមាណ ១១.៤% បើប្រៀបធៀបនឹងឆ្នាំ២០១៦ មានចំនួន ១៦.១%។ ការនាំចូល សម្ភារៈកាត់ដេរឃើញថាមានការធ្លាក់ចុះពី ៨.១% ក្នុងឆ្នាំ២០១៦ មកត្រឹម ៥.៥% ក្នុងឆ្នាំ២០១៧ (១១ខែ) ជាការបង្ហាញពីសកម្មភាពយឺតយ៉ាវនៅក្នុងវិស័យនេះ ដោយសារតែភាពខ្សោយក្នុងការប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងគូប្រកួតប្រជែង ការកើនឡើងប្រាក់ឈ្នួលអប្បបរមាលឿនពេក ភាពមិនច្បាស់លាស់ក្នុងការដឹកជញ្ជូនផលិតផលទាន់ពេលវេលា និងសម្ពាធដោយសារតែការបោះឆ្នោតឆ្នាំ២០១៨[35]។

តារាងទី៣៖ **Value of Import and its Compositions (Annual Growth, percent)**

| **Imported Commodity** | 2012 | 2013 | 2014 | 2015 | 2016 | 2016(11M) | 2017(11M) |
|---|---|---|---|---|---|---|---|
| **Consumtion Goods** | 21.8 | 10.7 | 32.3 | 25.6 | 10.4 | 9.1 | 19.8 |
| **Construction materials** | 35.4 | 15.3 | 36.1 | 22.9 | 16.4 | 16.1 | 11.4 |

[35] Cambodia Macroeconomic Report Assessment 2017, Ministry of Economic and Finance

| | | | | | | | |
|---|---|---|---|---|---|---|---|
| **Garment materials** | 21.9 | 19.8 | 7.6 | 17.5 | 7.2 | 8.1 | 5.5 |
| *o.w: Garment materials (Tax Exemption)* | *22.0* | *17.6* | *8.3* | *17.8* | *7.4* | *8.3* | *5.1* |
| **Vehicles** | 36.1 | 2.1 | 24.5 | 33.2 | -0.5 | 3.9 | 8.9 |
| **Petroleum products** | 12.6 | 5.7 | 5.9 | 10.7 | 9.9 | 9.5 | -30.2 |
| **Others** | 11.8 | 24.5 | 24.4 | 6.1 | 1.9 | 1.2 | 26.9 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៧*

ប្រទេសកម្ពុជា ជាប្រទេសដែលភាគច្រើនផ្អែកទៅលើការនាំចូល ដើម្បីបំពេញតម្រូវការក្នុងស្រុក ដែលមានន័យថា ជាប្រទេសដែលមានការនាំចូលខ្ពស់ជាងការនាំចេញ។ ចំណែកឯ ការនាំចេញវិញភាគច្រើនជាផលិតផល សម្លៀកបំពាក់ និងវាយនភ័ណ្ឌតែប៉ុណ្ណោះ។ បើទោះបីជា កម្ពុជាមានឱន ភាពពាណិជ្ជកម្មយ៉ាងណាក៏ដោយ ក៏កម្ពុជានៅតែអាចទទួលបានផលប្រយោជន៍ពីការធ្វើពាណិជ្ជកម្មអន្តរជាតិដែរ ព្រោះថាអ្វីដែលខ្វះខាត និងភាពគ្មានឯកទេសកម្មទៅលើផលិតផលណាមួយ ក៏កម្ពុជា នៅតែអាចបំពេញសេចក្តីត្រូវការរបស់ក្នុងប្រើប្រាស់ក្នុងស្រុកបាន។ (សូមមើលក្រាហ្វិកខាងក្រោម)

ក្រាហ្វិកទី១៥៖ ការនាំចេញសុទ្ធរបស់កម្ពុជា (NX) គិតជាដុល្លារ




*ប្រភព៖ DataBank, World Bank Group 2016*

## ២.៣. វិបត្តិសេដ្ឋកិច្ចក្នុងការរាំងស្ទះដល់កំណើនសេដ្ឋកិច្ចកម្ពុជា

### ២.៣.១. វិបត្តិហិរញ្ញវត្ថុអាស៊ី (១៩៩៧-១៩៩៨)

វិបត្តិហិរញ្ញវត្ថុ នៅអាស៊ីបានផ្ទុះឡើងនៅក្នុងប្រទេសថៃ ហើយបានរាលដាលដល់បណ្តាប្រទេសផ្សេងទៀតដូចជា ប្រទេសម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី និងកូរ៉េខាងត្បូង។ មិនតែ

ប៉ុណ្ណោះ វាបានរាតត្បាតដល់ប្រទេសផ្សេងៗជាច្រើនទៀតក្នុងពិភពលោក ដោយវាបានអូសបន្លាយរហូតដល់ឆ្នាំ១៩៩៨។ ប្រទេសកម្ពុជា ត្រូវបានហ៊ុមព័ទ្ធដោយប្រទេសជាច្រើនដែលបានទទួលរងនូវផលប៉ះពាល់ដោយសារតែវិបត្តិនេះ។ ប្រទេសជិតខាងរបស់កម្ពុជា ជាពិសេសថៃ ម៉ាឡេស៊ី និងសឹង្ហបុរី គឺជាដៃគូពាណិជ្ជកម្ម និងវិនិយោគធំបំផុតកាលពី ៥ឆ្នាំមុនពេលមានវិបត្តិហិរញ្ញវត្ថុកើតឡើង។ ដូច្នេះ វិបត្តិនៅអាស៊ីបានផ្លាស់ប្តូរបរិយាកាសខាងក្រៅជុំវិញសេដ្ឋកិច្ចកម្ពុជា[36]។

សេដ្ឋកិច្ចបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងប្រទេសជាច្រើនដែលនៅជាប់ប្រទេសកម្ពុជា ពីចុងទសវត្សឆ្នាំ១៩៨០ ដល់ពាក់កណ្តាលទសវត្សឆ្នាំ១៩៩៧ ដែលជាកត្តាមួយជម្រុញឲ្យសេដ្ឋកិច្ចកម្ពុជារីកចម្រើនបន្ទាប់ពីកម្ពុជាបានផ្លាស់ប្តូរងាកទៅរកសេដ្ឋកិច្ចទីផ្សារ ការអភិវឌ្ឍ និងការស្ថាបនាឡើងវិញ។ ប្រទេសថៃ និងសឹង្ហបុរី បានស្រូបយកចំណែកនៃការនាំចេញដ៏ធំរបស់កម្ពុជាចាប់តាំងពីការបង្កើតរដ្ឋាភិបាលឆ្នាំ១៩៩៣មក។ ការវិនិយោគផ្ទាល់បរទេស (FDI) ពីប្រទេសម៉ាឡេស៊ី សឹង្ហបុរី និងប្រទេសអាស៊ីដ៏ទៃទៀតក៏បានជួយបំពេញនូវការខ្វះខាតការសន្សំក្នុងស្រុក ការវិនិយោគ និងធនធានមនុស្សនៅកម្ពុជាផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បរិយាកាសអនុគ្រោះពីខាងក្រៅនេះបានផ្លាស់ប្តូរបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ីបានផ្ទុះឡើង។ ការព្រួយបារម្ភ ត្រូវបានបង្ហាញថាតើវិបត្តិបានជះឥទ្ធិពលដល់សេដ្ឋកិច្ចកម្ពុជា និងថាតើមានផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាកម្រិតណា ហើយ ៣០%នៃប្រជាជនទាំងនោះរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ការអភិវឌ្ឍសង្គម ជាពិសេសសុខភាព និងការអប់រំត្រូវបានទទួលស្គាល់ថាជាបញ្ហាចម្បងនៅក្នុងប្រទេសកម្ពុជា។

មិនមែនតែវិបត្តិហិរញ្ញវត្ថុនៅអាស៊ីទេដែលមានផលប៉ះពាល់ ប៉ុន្តែនៅមានបញ្ហាផ្សេងទៀតដែលមានឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា។ ដូចជាករណី ការប្រយុទ្ធគ្នានៅថ្ងៃទី៥ និងទី៦ ខែកក្កដាឆ្នាំ១៩៩៧។ ការប្រយុទ្ធគ្នានេះកើតឡើងដោយគណបក្សនយោបាយសំខាន់ៗចំនួនពីរ និងបានផ្លាស់ប្តូរលក្ខខណ្ឌសកម្មភាពក្នុងស្រុករបស់ប្រទេសកម្ពុជា។ ទំនុកចិត្តនៅក្នុងស្ថេរភាពនយោបាយត្រូវបានបាត់បង់ សុវត្ថិភាពប្រជាជន និងសហគ្រាសក្នុងប្រទេសកម្ពុជាត្រូវបានគម្រាមគំហែង និងបរិយាកាសនយោបាយក្នុងពេលអនាគតមានភាពមិនប្រាកដប្រជា។ សហគមន៍អន្តរជាតិ បានឆ្លើយតបនឹងការប្រយុទ្ធគ្នាកាលពីខែកក្កដា ដោយបញ្ឈប់ ឬព្យួរជំនួយបរទេសដល់កម្ពុ

[36] Chan Sophal, Toshiyasu Katog, Long Vou Piseth, So Sovannarith, Tia Savora, Hong Chuon Naron, Kao Kim Hourn & Chea VuthnaImpact of the Asian Financial Crisis on the SEATEs: The Cambodian Perspective, Cambodia Development Resource Institute, 1999

ជា។ ភ្លាមៗ បន្ទាប់ពីការប្រយុទ្ធ សមាគមន៍អាស៊ានបានសម្រេចចិត្តពន្យាពេលក្នុងការដាក់ប្រទេសកម្ពុជាជាសមាជិក ដែលតាមកាលកំណត់ត្រូវបានគេដាក់បញ្ចូលនៅចុងខែកក្កដា ឆ្នាំ ១៩៩៧។ សេដ្ឋកិច្ចកម្ពុជាបានកើនឡើងចំនួនត្រឹមតែ៥.៦% ប៉ុណ្ណោះនៅឆ្នាំ ១៩៩៧ ដែលមានចំនួនតិចជាងកំណើនជាមធ្យម ៦%នៅចន្លោះឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៦។

### ២.៣.២. វិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ ២០០៨

វិបត្តិហិរញ្ញវត្ថុពិភពលោក បានផ្ទុះឡើងនៅក្នុងសហរដ្ឋអាមេរិក ដែលជះឥទ្ធិពលដល់ប្រទេសជាច្រើននៅលើសកលលោក ។ វិបត្តិហិរញ្ញវត្ថុនេះ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើសេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកលើសេដ្ឋកិច្ចពិភពលោក។ កត្តាសំខាន់នៃកំណើនសេដ្ឋកិច្ចខ្ពស់នៅក្នុងទសវត្សកន្លងមក គឺសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ ដែលវិស័យទាំងនេះបានប្រឈមនឹងការថយចុះបន្ទាប់ពីមានវិបត្តិ។ ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតគឺ នៅក្នុងឧស្សាហកម្មកាត់ដេរដែលបាននាំចេញចំនួន ២.២ពាន់លានដុល្លារក្នុងឆ្នាំ២០០៨ ស្មើនឹង ៦៥% នៃការនាំចេញសរុប។ ក្នុងរយៈពេល ៦ខែក្រោយពីមានវិបត្តិនេះ កម្មករ ៥១,០០០នាក់ ត្រូវបានបញ្ឈប់ ដែលភាគច្រើននៃកម្មករ ៣៥០,០០០នាក់ នៅក្នុងវិស័យឧស្សាហកម្មឈានមុខនេះ។ វិស័យទេសចរណ៍ បានចុះបញ្ជីការធ្លាក់ចុះនៅឆ្នាំ២០០៨ ហើយបានចង្អុលបង្ហាញថាវានឹងធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩។ តាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ការធ្លាក់ចុះ ៥% នៃវិស័យនេះដោយលើកឡើងពីតម្រូវការពិភពលោកតិចតួច។ វិស័យសំណង់ក៏ត្រូវបានកំណត់ថានឹងថយចុះផងដែរដោយសារវិនិយោគិនបរទេសនៅក្នុងវិស័យអចលនទ្រព្យកំពុងត្រូវបានពន្យាពេល ឬផ្អាកគម្រោងធំៗរបស់ខ្លួន ដោយសារតែការកក្រើកនៃឥណទានផ្ទះ។ វិបត្តិហិរញ្ញវត្ថុបានផ្ទុះឡើងនៅក្នុងទីផ្សារដីធ្លី និងអចលនទ្រព្យ ដែលត្រូវបានគេអះអាងថាមានភាពអាប់អួរពីភាពរីកចម្រើននៃពិភពលោកក្នុងប៉ុន្មានឆ្នាំចុងក្រោយនោះ។ ទាំងនេះបានកាត់បន្ថយសកម្មភាពវិស័យសំណង់ និងតម្រូវការជាទូទៅ។ វិស័យកសិកម្មត្រូវបានគេរំពឹងថានឹងមានការកើនឡើងយ៉ាងខ្លាំងដើម្បីកាត់បន្ថយការធ្លាក់ចុះនូវវិស័យដ៏ទៃទៀតនៅក្នុងសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ ដំណាំមួយចំនួនប្រឈមនឹងតម្លៃទាប និងគ្មានទីផ្សារដោយសារស្ថានភាពពិភពលោកប្រែប្រួល ដែលមានន័យថា ចំណូលតិចនិងស្ថានភាពលំបាកសម្រាប់កសិករ ជាពិសេសអ្នកដែលខ្ចីប្រាក់សម្រាប់ពង្រឹងផលិតកម្ម ដើម្បីឆ្លើយតបទៅនឹងតម្លៃកើនឡើងនៅពាក់កណ្តាលឆ្នាំ២០០៨។

រដ្ឋាភិបាលកម្ពុជាបានចាត់វិធានការគោលនយោបាយជាច្រើនដូចជា ការបន្ថយគោលនយោបាយរូបិយវត្ថុ និងការឧបត្ថម្ភធនក្នុងវិស័យកសិកម្ម។ ផែនការបណ្តុះបណ្តាលត្រូវបាន

គ្រោងសម្រាប់កម្មករដែលបានបញ្ឈប់។ វិធានការពន្ធនៅក្នុងពេលនោះរួមបញ្ចូលទាំងការព្យួរពន្ធលើប្រាក់ចំណេញមុន ១% និងការបន្ថយពន្ធលើប្រាក់ចំណេញសម្រាប់រោងចក្រកាត់ដេរមួយចំនួន។ ថវិកាពង្រីកបន្ថែមត្រូវបានកំណត់សម្រាប់ឆ្នាំ២០០៩ ដើម្បីជាសកម្មភាពមួយ និងដើម្បីបំពេញផែនការដើម្បីបង្កើនការចំណាយលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងកម្មវិធីសង្គម[37]។

## ២.៤. គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការជម្រុញកំណើនសេដ្ឋកិច្ច

ដើម្បីបន្តជម្រុញកំណើនសេដ្ឋកិច្ចរឹងមាំ រាជរដ្ឋាភិបាលត្រូវសម្រេចឲ្យខាងតែបាននូវលទ្ធផលជាក់ស្តែង ក្នុងការអនុវត្តគោលនយោបាយគន្លឹះជាក់លាក់ និងមុតស្រួចចំនួនបី រួមមាន៖ ១. បន្តធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច, ២. ជម្រុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងធន់វិបត្តិ និង ៣. ពន្លឿនការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័ន។

វិធានការគោលនយោបាយតាមផ្នែកគន្លឹះធំៗទាំងបីនេះ រួមមាន៖

១. បន្តធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈ៖

- ពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ
- គ្រប់គ្រងកំណើនឥណទានក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ ឲ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម
- បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតសម្រាប់វិស័យឯកជន ដូចជា៖ ការអភិវឌ្ឍ ទីផ្សារសញ្ញាប័ណ្ណ និងទីផ្សាររូបិយប័ណ្ណ និងការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម
- បន្តការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ និងខិតខំជម្រុញការអភិវឌ្ឍលំនៅស្ថានដែលមានតម្លៃសមរម្យស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល និង
- បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។

[37] https://www.odi.org/publications/3307-global-financial-crisis-cambodia

២. ជម្រុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាបប័ន្ន និងធន់នឹងវិបត្តិ តាមរយៈ៖

- ការបង្កើនសមត្ថភាពប្រកួតប្រជែងកម្ពុជា៖ (i)- កាត់បន្ថយថ្លៃឡូជីស្ទីក, (ii)- កាត់បន្ថយថ្លៃអគ្គិសនីបន្ថែមទៀត និងធានាស្ថេរភាពនៃការផ្គត់ផ្គង់, (iii)- អនុវត្តឲ្យមានប្រសិទ្ធិភាពនូវផែនការមេភស្តុភារកម្ម, (iv)- បន្តធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ ទាំងលើការកំណត់ថ្លៃ និងការបញ្ចេញទំនិញ, (v)- កាត់បន្ថយ និងឈានទៅលុបបំបាត់ចំណាយក្រៅផ្លូវការនៅគ្រប់ស្ថាប័ន ជាពិសេស ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្ម, (vi)- កែទម្រង់សមត្ថកិច្ចស្ថាប័ននៅមាត់ច្រក, (vii)- ជម្រុញការកែទម្រង់ប្រព័ន្ធពន្ធ ដោយឈរលើគោលការណ៍ដែលអនុគ្រោះដល់កំណើន និងធានាយុត្តិធម៌ សមធម៌ សេវាល្អ អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព, (viii)- ជម្រុញការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល, និង (ix)- អនុវត្តឲ្យមានប្រសិទ្ធិភាពនូវគោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ។
- ការជម្រុញការធ្វើពិពិធកម្មសេដ្ឋកិច្ច៖ (i)- បន្ទ្រពង្រឹងក្បាលម៉ាស៊ីនកំណើនដែលមានស្រាប់ដោយអនុវត្តឲ្យមានប្រសិទ្ធិភាពនូវ "គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥" ជាពិសេសទៅលើការរៀបចំផែនការមេក្នុងការប្រែក្លាយខេត្តព្រះសីហនុឲ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគម្រូពហុបំណង និងរៀបចំ និងចាប់ផ្តើមអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រទំនើបកម្មវិស័យកាត់ដេរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏នឹងអនុវត្តគោលនយោបាយថ្មីៗមួយចំនួន ដូចជា ផែនការមេសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនិងការធ្វើពិពិធកម្មវិស័យទេសចរណ៍, (ii)- កំណត់ឲ្យបាននូវក្បាលម៉ាស៊ីនកំណើនថ្មីដែលមានសក្តានុពលខ្ពស់ផ្សេងទៀត, (iii)- ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម, (iv)- មូលនិធិគម្រោងអភិវឌ្ឍសហគ្រិនភាពកម្ពុជា (Cambodia Entrepreneurship Development Project Fund), (v)- បង្កើតឧស្សាហកម្មថ្មីដែលដឹកមុខដោយរាជរដ្ឋាភិបាល ដោយមានការសហការជាមួយវិស័យឯកជន ដើម្បីបង្កើនការចូលរួមកាន់តែខ្លាំងជាងមុនក្នុងការអភិវឌ្ឍជាតិ, (vi)- រៀបចំខ្លួនដើម្បីទាញយកឲ្យអស់ពីលទ្ធភាពនូវអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល, និង (vii)- ខិតខំទ្វេរដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស

ដើម្បីបំពេញបន្ថែមការវិនិយោគក្នុងស្រុក តាម រយៈការបញ្ចប់វិសោធនកម្មច្បាប់ស្តីពីវិនិយោគ អនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងធ្វើទំនើបកម្មប្រព័ន្ធពន្ធដារ។ល។

៣. ពន្លឿនការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈ៖

- ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងកំណែទម្រង់វិស័យសាធារណៈ ដូចជាវិស័យកងទ័ព និងសន្តិសុខ តុលាការ និងយុត្តិធម៌ រដ្ឋាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ហិរញ្ញវត្ថុសាធារណៈវិស័យហិរញ្ញវត្ថុ និងធនាគារ និងវិស័យសំខាន់ៗផ្សេងៗទៀត
- កាត់បន្ថយការចំណាយលើការធ្វើធុរកិច្ច ដោយពិនិត្យជាចាំបាច់លើបញ្ញាបទប្បញ្ញត្តិ នីតិវិធីនៃការអនុវត្ត គុណភាព និងចំណាយលើសេវាសាធារណៈ ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកកម្ពុជាឲ្យមានប្រសិទ្ធភាព និង
- ពង្រឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ទាំងជំនាញកម្រិតទាបមធ្យម និងខ្ពស់សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

### ២.៤.១. **វិធានការផ្នែកចំណូល**

#### ២.៤.១.១. **ចំណូលពន្ធដារ**

វិធានការគន្លឹះជាក់លាក់ សម្រាប់ការអនុវត្តក្នុងទិសដៅរក្សាកំណើនចំណូលពន្ធ និងឆ្លើយតប

នឹងបញ្ហាប្រឈម រួមមាន៖

- *បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា តាមរយៈ៖*
  - បន្តការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់ចុះបញ្ជីពន្ធដារ ដែលបានរកឃើញដោយការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ
  - លើកទឹកចិត្តឲ្យអ្នកជាប់ពន្ធចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច E-registration

- បន្តផ្តល់សេវាជូនអ្នកជាប់ពន្ធធំ មធ្យម និងតូច តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ
- បន្តចេញវិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពពន្ធ (Tax Compliance Award Certificate) ចំពោះអ្នកជាប់ពន្ធដែលមានអនុលោមភាពពន្ធខ្ពស់
- ពង្រឹងការពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center) និងការជជែកផ្ទាល់ជាមួយពន្ធដារ (Live Chat) និងបញ្ជូរនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ
- រៀបចំសៀវភៅណែនាំស្តីពីគោលការណ៍នៃកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា
- រៀបចំដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment)
- រៀបចំបញ្ជូរទទួលលិខិតប្រកាសពន្ធដោយស្វ័យប្រវត្តិ តាមគោលដៅអ្នកជាប់ពន្ធសំខាន់ៗ
- បន្តពង្រឹងការវិភាគហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ ដោយកំណត់វិស័យដែលមានកម្រិតហានិភ័យខ្ពស់ ដូចជា វិស័យនាំចេញ-នាំចូលវិស័យសំណង់ វិស័យដឹកជញ្ជូន និងវិស័យដែលមានសក្តានុពលផ្សេងទៀតដល់កំណើនសេដ្ឋកិច្ច ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- បន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស
- ជម្រុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម
- បន្តការបង្កើនការពិនិត្យផ្ទៀងផ្ទាត់ និងការប្រមូលផ្តុំព័ត៌មាន រួមមានការផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម និងប្រភេទពន្ធផ្សេងៗ ដើម្បីកសាងកម្មវិធីសវនកម្ម និងការកំណត់ពន្ធឡើងវិញ និង
- អនុវត្តវិធានការពាក់ព័ន្ធដែលនឹងត្រូវដាក់ចេញ នៅក្នុងក្របខណ្ឌគោលលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើនសេដ្ឋកិច្ច និងធានាយុត្តិធម៌ សមធម៌ សេវាល្អអភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។

- *បន្តពង្រឹងមុខងារ តាមរយៈ៖*
  - ដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សរយៈពេល ០៥ ឆ្នាំ (២០១៩-២០២៣) និងផែនការប្រតិបត្តិការធនធានមនុស្សឆ្នាំ២០១៩
  - បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយអភិវឌ្ឍកម្មវិធីគ្រប់គ្រងការប្រមូលពន្ធតាមបច្ចេកវិទ្យាព័ត៌មាន
  - បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍស្ថានភាពសេដ្ឋកិច្ច-សង្គម រួមមាន៖ រៀបចំកែសម្រួលតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងតម្លៃជាមូលដ្ឋាននៃការគិតពន្ធលើអចលនទ្រព្យ រៀបចំកែសម្រួលប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា រៀបចំប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយាន្តជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៩ និងសិក្សាភាពខ្វះចន្លោះនៃច្បាប់ស្តីពីសារពើពន្ធ និង
  - រៀបចំបង្កើតវិធីសាស្ត្រតាមដាន វិភាគ វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារថ្នាក់ជាតិ ក្នុងតំបន់ និងសកលលោក។

### ២.៤.១.២. ចំណូលគយ និងរដ្ឋាករ

ក្នុងទិសដៅបន្តរក្សាកំណើនចំណូល និងឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់អគ្គនាយកដ្ឋាន

គយ និងរដ្ឋាករកម្ពុជា វិធានការគន្លឹះគ្រោងនឹងដាក់ឲ្យអនុវត្តឆ្នាំ២០១៩ រួមមាន៖

- *ពង្រឹងរដ្ឋបាលគយ តាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ, ការងារបច្ចេកទេសគយ, ការអនុវត្តច្បាប់លើទំនិញនាំចូលល្មើសកម្មសិទ្ធបញ្ញា, ការងារបង្ការនិងបង្រ្កាបអំពើរត់គេចពន្ធ, និងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖*
  - ពង្រឹងយន្តការគ្រប់គ្រងការអនុវត្តនីតិវិធីគយ តាមរយៈ៖ (១)- ការកត់ត្រា និងជម្រះបញ្ជីទំនិញនាំចូល, កិច្ចសហការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរកំពង់ផែ ដើម្បីកំណត់មុខសញ្ញាហានិភ័យមុនពេលទំនិញមកដល់, (២)- ការពង្រឹងបន្ថែមលើការគ្រប់គ្រងអាជីវកម្មលក់ទំនិញរួចពន្ធ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និង (៣)- ការដាកចេញនូវវិធានការដាក់លាក់ក្នុងការទារបំណុលពន្ធ និងអាករ
  - បង្កើនប្រសិទ្ធភាពលើការងារតម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត តាមរយៈ៖ (១)- ការពិនិត្យឡើងវិញនូវការធ្វើមជ្ឈការ និងវិមជ្ឈការការងារ

ផ្សៀងផ្ទាត់តម្លៃគិតពន្ធគយទៅអង្គភាពគយទៅអង្គភាពពន្ធគយនិ ងរដ្ឋាករមូលដ្ឋាន ឲ្យកាន់តែប្រសើរសមស្របតាមវិវត្តសភាពការណ៍, (២)- ការកែសម្រួលនីតិវិធីផ្សៀងផ្ទាត់តម្លៃគិតពន្ធគយ ការចាសត់ថ្នាក់ទំនិញ និងវិធានដើមកំណើត, (៣)- ការកែលម្អប្រព័ន្ធទិន្នន័យគ្រប់គ្រងតាមមធ្យោបាយអេឡិចត្រូនិច, និង (៤)- ការតាមដាន និងវាយតម្លៃអនុលោមភាពការងារទាំងនេះ ឲ្យបានខ្ជាប់ខ្ជួន

- កសាងនីតិវិធី យន្តការចាំបាច់ និងបទប្បញ្ញត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បីៈ (១)- បង្កើនប្រសិទ្ធភាពការងារបង្ក្រាបការជួញដូរទំនិញល្មើសកម្មសិទ្ធបញ្ញា, (២)- អភិវឌ្ឍប្រព័ន្ធកត់ត្រាការចុះបញ្ជីទំនិញដែលជាកម្មវត្ថុការពារកម្មសិទ្ធបញ្ញា, និង (៣)- បង្កើតយន្តការផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋបាលគយជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយម្ចាស់កម្មសិទ្ធ
- ពង្រឹងប្រសិទ្ធភាពយន្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសទាំងនៅដើមទី កណ្តាលទី និងចុង តាមរយៈ ការងារស្រាវជ្រាវ ស៊ើបអង្កេត ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយឆ្លងដែន ចរាចរណ៍សាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុខុសច្បាប់ និងការនាំចូលពុំស្របច្បាប់ និង/ឬហាមឃាត់ផ្សេងទៀត
- បង្កើនកិច្ចសហប្រតិបត្តិការ ការធ្វើសមាហរណកម្ម និងសុខដុមណីយកម្មកិច្ចការគយទាំងនៅក្នុងកម្រិតតំបន់ និងសកលលោកដើម្បីៈ (១)- ធានាប្រសិទ្ធភាពនៃការផ្លាស់ប្តូរព័ត៌មានស្ថិតិពាណិជ្ជកម្ម, (២)- បង្ការ និងបង្ក្រាបបទល្មើសឆ្លងកាត់ព្រំដែន និងបទល្មើសគេចពន្ធ, (៣)- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការអនុវត្តពន្ធអនុគ្រោះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានជាមួយដៃគូ, និង (៤)- ចែករំលែកចំណេះដឹងបទពិសោធន៍, និង
- អនុវត្តវិធានការពាក់ព័ន្ធនឹងផ្នែកគយ ដែលនឹងត្រូវដាក់ចេញនៅក្នុងក្របខ័ណ្ឌកែទម្រង់ប្រព័ន្ធពន្ធ ឆ្នាំ ២០១៩-២០២៣។

- *បន្តពង្រឹងមុខងារគាំទ្រ តាមរយៈៈ*
  - ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការអនុវត្តយន្តការសហប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត ការវាយតម្លៃធុរជន ការពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងហានិភ័យ ការកែសម្រួលសមាសភាព និងការពង្រីកគ្រប់ភាពដណ្តប់នៃប្រតិបត្តិការសវនកម្មគយ

ក្រោយពេលបញ្ចេញទំនិញ និងការផ្លាស់ប្តូរព័ត៌មានទាំងផ្ទៃក្នុងអង្គភាពគយ និង ជាមួយស្ថាប័នពាក់ព័ន្ធ

- ពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាត្រួតពិនិត្យក្នុងការងារគយ តាម រយៈ៖ (១)- ការបន្តពង្រីកវិសាលភាពគ្របដណ្តប់នៃការអនុវត្តប្រព័ន្ធស្វ័តប្រវត្តិកម្ម ទិន្នន័យគយ (អាស៊ីគូដា), (២)- ការកែលម្អ និងបន្ថែមមុខងារគាំទ្រនីតិវិធីគយផ្សេងៗ ដល់ប្រព័ន្ធ, និង (៣)- ការតភ្ជាប់រវាងអាស៊ីគូដាជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេង ទៀត
- បន្តរៀបចំអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិសម្រាប់ "ដំណាក់កាលទី២" គឺគ្រោងតភ្ជាប់ ទៅស្ថាប័នពាក់ព័ន្ធនិងការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតក្នុងទម្រង់អេឡិចត្រូនិច ប្រើប្រាស់សម្រាប់ការបញ្ចេញទំនិញពីគយ បន្ទាប់ពីការចូលរួមបញ្ជូន និងទទួល វិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញក្នុងទម្រង់អេឡិចត្រូនិច (e-FORM D)។ ក្នុងដំណាក់ កាលទី២នេះ ក្រសួងស្ថាប័នដែលអាចតភ្ជាប់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ រួមមាន៖ ក្រសួងសុខាភិបាល, ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និងតំបន់សេដ្ឋកិច្ចពិសេស, ក្រសួងកិ សិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់ម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ តាមរ យៈការបង្កើតមជ្ឈមណ្ឌលទទួលរូបភាពម៉ាស៊ីនស្កេន និងបន្តការគាំទ្រចាំបាច់ផ្សេងទៀត
- ជំរុញវិសាលភាពនៃការអនុវត្តនីតិវិធីឆ្លងកាត់គយ តាមរយៈការចូលរួមក្នុងសមាស ភាពក្រុមការងារថ្នាក់ជាតិ និងយន្តការគាំទ្រចាំបាច់នានា និង
- ពង្រឹងអភិបាលកិច្ចអង្គភាពគយ និងអភិវឌ្ឍស្ថាប័ន តាមរយៈការបណ្តុះបណ្តាល និង កែលម្អយន្តការវាយតម្លៃ, យន្តការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់មន្ត្រីគយ និងបុគ្គលពាក់ព័ន្ធ។

### ២.៤.១.៣. ចំណូលមិនមែនសារពើពន្ធ

ក្នុងទិសទៅបន្តកំណើន និងពង្រឹងប្រភពចំណូលសក្តានុពល បន្ថែមលើវឌ្ឍភាពសម្រេច បាន

កន្លងមក ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹកើតមានឡើងក្នុងឆ្នាំ២០១៩ វិធានការគន្លឹះប្រចាំគ្រាដែលចាំបាច់ត្រូវអនុវត្តបន្ត រួមមាន៖

- បង្កើនប្រសិទ្ធភាពរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការតាមដាន, កត់ត្រា និងប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងរឹងទារបំណុលឲ្យទាន់ពេល ជាមួយយន្តការមានស្រាប់
- បន្តពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ឲ្យកាន់តែមានប្រសិទ្ធភាព, តម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវ, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ចតាមរយៈការអនុវត្តបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជាធរមាន
- បន្តជំរុញ និងលើកទឹកចិត្តឲ្យក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីសម្រេចបានការធ្វើទំនើបកម្មនៃការកត់ត្រា, ការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និងទាន់ពេលវេលា
- បន្តជំរុញការគ្រប់គ្រងសាច់ប្រាក់របស់ក្រសួង-ស្ថាប័ន តាមរយៈប្រព័ន្ធធនាគារក្នុងការបង់ចំណូលចូលថវិកាជាតិ។ ក្រសួង-ស្ថាប័នត្រូវសិក្សាបន្ថែមលើសេវាប្រកួតប្រជែងរបស់បណ្តាធនាគារដៃគូដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការបង់ចំណូល
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឲ្យមានភាពងាយស្រួល និងតម្លាភាព
- ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យប្រេង-ឧស្ម័ន ដើម្បីការកៀរគរចំណូលពីវស័យនេះ
- ពង្រឹង និងពន្លឿនការអនុវត្តយន្តការដែលបានព្រមព្រៀង និងឯកភាព រួមមាន កម្រៃអាកាសចរស៊ីវិល (CAF), ការបង់កម្រៃលេខទូរគមនាគមន៍, ការបង់កម្រៃពីប្រេ្យកង់ព្រមទាំងពន្លឿនការងាររៀបចំកែប្រែកម្រៃអាជ្ញាប័ណ្ណឡើងវិញឲ្យបានគ្រប់ជ្រុងជ្រោយ

- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដោយសហការជាមួយបណ្ដាស្ថាប័ននានា
- បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍របស់រាជរដ្ឋាភិបាល
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមការកាន់កាប់របស់ក្រសួង-ស្ថាប័នសាមី ជាពិសេសការធ្វើបច្ចុប្បន្នភាពកិច្ចសន្យា, កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្បទាននានា ឲ្យសមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត
- ស្នើគ្រប់ក្រសួង-ស្ថាប័នបន្តកិច្ចសហការល្អ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈការផ្ដល់ទិន្នន័យ, កិច្ចព្រមព្រៀង, កិច្ចសន្យា និងឯកសារពាក់ព័ន្ធនានា ដើម្បីបន្តពង្រឹងយន្តការប្រមូលចំណូលឲ្យអស់លទ្ធភាព និងប្រកបដោយប្រសិទ្ធភាព
- ស្នើអាជ្ញាធរសវនកម្មជាតិពង្រឹងការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រ- សួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹង និងពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត ដើម្បីកៀរគរចំណូលឲ្យអស់លទ្ធភាព
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់ និង
- អនុវត្តវិធានការផ្សេងទៀត ពាក់ព័ន្ធនឹងផ្នែកចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបានដាក់ចេញ នៅក្នុងឯកសារយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣

### ២.៤.២. វិធានការផ្នែកចំណាយ

ដោយឈរលើមូលដ្ឋាននៃការអនុវត្តចំណាយសាធារណៈកន្លងមក និងក្នុងក្របខ័ណ្ឌនៃគោល

នយោបាយពង្រឹងការគ្រប់គ្រងថវិកា, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និងគោលការណ៍ជាក់លាក់មួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ២០១៩ ដូចខាងក្រោម៖

- បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលតាមរយៈការបង្កើនប្រសិទ្ធភាពនៃៈ (១)- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, (២)- ការរៀបចំថវិកា, (៣)- ការវិភាជថវិកា, និង (៤)- ការអនុវត្តថវិកា
- ពង្រឹងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅបង្កើនគុណ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា
- បន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តចាស់ និងថ្មី
- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធឡូជីស្ទីកនិងដឹកជញ្ជូន, និងកសិកម្ម
- គាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០១៥
- បន្តគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០១៥ និងទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគសាធារណៈលើការពង្រីកនិងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន
- បន្តការរឹតត្បិតចំណាយមិនចាំបាច់ ដើម្បីជំរុញការអនុវត្តគោលនយោបាយធំៗ និងកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល
- ធានាប្រសិទ្ធផាពនៃការវិភាជ និងប្រើប្រាស់ថវិកាសម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- បន្តបង្កើនការវិនិយោគសាធារណៈដើម្បីជំរុញការធ្វើពិពិធកម្ម, ការបង្កើនផលិតភាព និងភាពប្រកួតប្រជែងក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព តាមរយៈការធ្វើវិចារណនកម្មគោលនយោបាយចំណាយ
- បន្តជំរុញអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើនការងារនៅទីជនបទ ដែលគាំទ្រដោយវិស័យជំនាញ, ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជន នៅទីជនបទ
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃនៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត និងចំណាយមូលធន
- ពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តៈ (១)- កែសម្រួលនីតិវិធីចំណាយ, (២)- ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់, (៣)- ការពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (៤)- ការត្រួតពិនិត្យការអនុវត្តថវិកាត្រីមាស និងឆមាស, (៥)- ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និង (៦)- ការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត
- បន្តគិតគូឲ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោនយោបាយគន្លឹះដែលបានគ្រោង រួមមានៈ
    - ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈ (១)- ការរៀបចំអនុក្រឹត្យស្តីពីគោលការណ៍ណែនាំរួមសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈ, (២)- ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍, និង (៣)- ការរៀបចចំបទដ្ឋានគតិយុត្ត

សម្រប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

- ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឲ្យបានទូលំទូលាយជាងមុន តាមរយៈ៖ ការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងទីផ្សារមូលបត្រ និង
- ពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាន និងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី៖ (១)- ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, (២)- វិស័យធនាគរ និងហិរញ្ញវត្ថុ, និង (៣)- ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២.៥. ទស្សនៈវិស័យទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា

ក្នុងឆ្នាំ២០១៨ និង២០១៩ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនក្នុងរង្វង់ប្រមាណ ៧.0% ដែលទ្រទ្រង់ដោយមូលដ្ឋានកំណើនស្រដៀងទៅនឹងឆ្នាំ២០១៧[38]។ ផ្អែកលើនិន្នាការខាងលើសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ត្រូវបានព្យាករណ៍ដូចខាងក្រោម៖

(១)- វិស័យកសិកម្មនឹងបន្តសម្រេចបានកំណើនយឺតក្នុងរង្វង់ ១,៨% ក្នុងឆ្នាំ២០១៨ និង ២០១៩។ អនុវិស័យដំណាំត្រូវបានរំពឹងទុកថានឹងមានកំណើនប្រមាណ ២,២% ក្នុងឆ្នាំទាំងពីរ ដោយកត្តាអាកាសធាតុអំណោយផល ភាពប្រសើរឡើងនៃថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ។ ម្យ៉ាងទៀត កម្រិតខ្ពស់នៃថ្លៃកៅស៊ូលើទីផ្សារអន្តរជាតិ គួបផ្សំនឹងកំណើនខ្ពស់នៃផ្ទៃដីចៀរជ័រកៅស៊ូ នឹងលើកទឹកចិត្តឲ្យកសិករខ្នាតតូច និងក្រុមហ៊ុនឯកជនបង្កើនផលិតកម្មកៅស៊ូសម្រាប់នាំចេញ។ អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនល្អប្រសើរផងដែរ ដែលត្រូវបានជំរុញដោយបន្តកំណើនខ្ពស់នៃវារីវប្បកម្ម នៅពេលដែលមាននិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ ការចិញ្ចឹមសត្វក៏ត្រូវបានព្យាករណ៍ថា នឹងមានកំណើនល្អដោយសារការបន្តកំណើននៃការចិញ្ចឹមគោ និងមាន់ធម្មជាតិបែបពាណិជ្ជកម្ម និងកំណើនផលិតកម្មជ្រូកដោយសារតែការងើបឡើងវិញនៃថ្លៃជ្រូករស់។ *ទោះបីជាយ៉ាងនេះក្តី វិស័យកសិកម្មបន្តជួបបញ្ហា*

[38] ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩

*ប្រឈមជាច្រើន ដូចជា កំណើនផលិតភាពទាប កង្វះការវិនិយោគលើការកែច្នៃកសិផល ពាណិជ្ជូបនីកម្មកសិកម្ម និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។*

(២)- វិស័យឧស្សាកម្មនឹងបន្តរក្សាកំណើនរឹងមាំ ក្នុងអត្រាប្រចាំឆ្នាំរង្វង់ ១០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យសំណង់ និងការបន្តកំណើននៃវិស័យកាត់ដេរ ស្របនឹងសន្ទុះកំណើនខ្ពស់នៃវិស័យកម្មន្តសាលមិនមែនកាត់ដេរទាំងសម្រប់នាំចេញ និងបម្រើទីផ្សារក្នុងស្រុក។ ក្នុងនោះៈ

- ការរីកចម្រើននៃវិស័យសំណង់ ជាមួយនឹងអត្រាកំណើនប្រមាណ ១៦,៧% ក្នុងឆ្នាំ២០១៨ និង១៦,៩% ក្នុងឆ្នាំ២០១៩ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការងាកទៅរកប្រភេទគម្រោងសំណង់ថ្លៃទាប និងមធ្យម ដែលជួយប៉ះប៉ូវដល់កំណើនយឺតនៃប្រភេទសំណង់ថ្លៃខ្ពស់។ ភាពរឹងមាំនៃវិស័យនេះ ត្រូវបានបន្តគាំទ្រដោយការអនុវត្តគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានតម្លៃសមរម្យ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងភាពជឿជាក់ចំពោះការវិនិយោគ ដោយសារភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចកម្ពុជា ទោះជាមានឥរិយាបទប្រុងប្រយ័ត្នពីសំណាក់វិនិយោគិនមួយចំនួនក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោតក៏ដោយ។

- វិស័យកាត់ដេររក្សាបានកំណើនក្នុងរង្វង់ ៥,០% ក្នុងឆ្នាំ២០១៨ និង២០១៩ ដោយសារស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាមានភាពប្រសើរឡើងជាងការរំពឹងទុក។ *ទោះជាយ៉ាងនេះក្តី វិស័យអាចនេះបន្តប្រឈមនឹងសម្ពាធថ្លៃដើមផលិតកម្មដែលប៉ះពាល់ដល់ភាពប្រកួតប្រជែង កំណើនបៀវត្សលឿនជាងផលិតភាព ភាពមិនច្បាស់លាស់នៃការបញ្ជាទិញ និងការប្រកួតប្រជែងកាន់តែខ្លាំងជាមុនពីបណ្តាប្រទេសផ្សេងទៀត ដែលនាំចេញផលិតផលកាត់ដេរដូចកម្ពុជា។*

-វិស័យឧស្សាហកម្មផ្សេងទៀតត្រូវបានរំពឹងថានៅរក្សាបាននូវកំណើនល្អដែលក្នុងរង្វង់ ១១,៩% ក្នុងឆ្នាំ២០១៨ និង ១២,២% ក្នុងឆ្នាំ២០១៩ ដោយសារការពង្រីកការវិនិយោគដែលមានស្រាប់ និងការ វិនិយោគថ្មី ក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរដែលជាជន្ទល់កំណើនមួយដ៏រឹងមាំ រួមមានៈ ការផលិតម្ហូបអាហារ និងភេសជ្ជៈ គ្រឿងបង្គុំអេឡិចត្រូនិច គ្រឿងបន្លាស់ គ្រឿងសង្ហារឹម កង់ និងស៊ីម៉ង់ត៍ជាដើម។

(៣)- វិស័យសេវាកម្មត្រូវបានព្យាករណ៍ថានឹងមានកំណើនខ្ពស់ ក្នុងរង្វង់ប្រមាណ ៧.០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃកំណើនល្អប្រសើរនៃវិស័យទេសចរណ៍ លក់ដុំ-រាយ អចលនទ្រព្យ និងវិស័យដឹកជញ្ជូន និងទូរគមនាគមន៍។ ក្នុងនោះៈ

- វិស័យទេសចរណ៍ត្រូវបានរំពឹងថាបន្តងើបឡើង ក្នុងអត្រាកំណើន ៩,៥% ក្នុងឆ្នាំ២០១៨ និង ៩,៧% ក្នុងឆ្នាំ២០១៩ ដោយសារកំណើនខ្ពស់នៃភ្ញៀវទេសចរអន្តរជាតិ ជាពិសេសទេសចរពីតំបន់អាស៊ី ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ ការលើកទឹកចិត្តឲ្យមានការបើកជើងហោះហើរត្រង់ និងការដាក់ចេញនូវគោលនយោបាយនានា ក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរបន្ថែម។ *ទោះជាយ៉ាងនេះក្តី ការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍ ព្រមទាំងការទាក់ទាញភ្ញៀវចំណាយខ្ពស់ នៅតែជាប្រការចាំបាច់ និងបន្ទាន់សំដៅធានាចីរភាពកំណើននៃវិស័យនេះ ដើម្បីបន្តតួនាទីជាជន្ទល់សំខាន់មួយសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។*

- វិស័យលក់ដុំ-រាយ ត្រូវបានព្យាករណ៍ថានឹងមានកំណើនរឹងមាំក្នុងអត្រា ៧,២% ក្នុងឆ្នាំ២០១៨ និង ៧,៩% ក្នុងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងនូវការប្រើប្រាស់ក្នុងស្រុក។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់ក្នុងស្រុកត្រូវបានវាយតម្លៃថាមានសន្ទុះខ្លាំងហើយនិន្នាការនេះនឹងនៅតែបន្តដោយសារកំណើនប្រជាជនដែលមានចំណូលមធ្យម និងការផ្លាស់ប្តូរឥរិយាបថនៃការចាយវាយ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនហាងលក់ដុំ-រាយ និងបណ្តាភោជនីយដ្ឋាន និងហាងភេសជ្ជៈអន្តរជាតិជាច្រើន។ លើសពីនេះ ការបង្កើនចំណាយរបស់រដ្ឋាភិបាលលើបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើន សមត្ថភាពចំណាយក្នុងស្រុកផងដែរ។

- វិស័យអចលនទ្រព្យត្រូវបានរំពឹងថានឹងនៅតែមានកំណើនរឹងមាំ ក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលមាននិន្នាការស្របទៅនឹងវិស័យសំណង់។ កំណើននេះនឹងត្រូវទ្រទ្រង់ដោយការកើនឡើងនៃសកម្មភាពទិញ-លក់សំណង់អគារពាណិជ្ជកម្ម និងលំនៅដ្ឋានដែលមានតម្លៃទាប និងមធ្យម ដែលប៉ះប៉ូវដល់ការថមថយនៃប្រតិបត្តិការទិញ-លក់ និងជួលលំនៅស្ថានថ្លៃខ្ពស់ ដោយសារកំណើនខ្លាំងនៃការផ្គត់ផ្គង់ធៀបនឹងតម្រូវការ។

តារាងទី៤៖ កំណើនសេដ្ឋកិច្ចតាមវិស័យ

| | ២០១៧ ប៉ាន់ស្មាន | ២០១៨ ព្យាករណ៍ | ២០១៩ ព្យាករណ៍ |
|---|---|---|---|
| កំណើន ផសស | ៧,០% | ៧,០% | ៧,១% |
| កសិកម្ម | ១,៦% | ១,៨% | ១,៨% |
| ដំណាំ | ២,០% | ២,២% | ២,២% |
| ការចិញ្ចឹមសត្វ | ០,៨% | ១,២% | ១,៤% |
| នេសាទ | ១,៥% | ១,៨% | ២,១% |

| | | | |
|---|---|---|---|
| ព្រៃឈើ | -០,៣% | -០,៧% | -១,២% |
| ឧស្សាហកម្ម | ៩,៩% | ៩,៦% | ១០,០% |
| កាត់ដេរ | ៥,៤% | ៥,០% | ៥,១% |
| សំណង់ | ១៧,៦% | ១៦,៧% | ១៦,៩% |
| ឧស្សាហកម្មផ្សេងទៀត | ១២,៥% | ១១,៩% | ១២,២% |
| សេវាកម្ម | ៧,១% | ៧,០% | ៧,០% |
| ទេសចរណ៍ | ៤,៨% | ៤,៥% | ៤,៧% |
| លក់ដុំ-រាយ | ៦,៩% | ៧,២% | ៧,៣% |
| ដឹកជញ្ជូន និងគមនាគមន៍ | ៧,៩% | ៧,៣% | ៧,៥% |
| អចលនទ្រព្យ | ៩,២% | ៨,៤% | ៨,៥% |

*ប្រភព៖ ការប៉ាន់ស្មាន និងព្យាករណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែកុម្ភៈ ឆ្នាំ២០១៨*

- វិស័យដឹកជញ្ជូន និងទូរគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តកំណើនក្នុងអត្រា ៧,៣% ក្នុងឆ្នាំ២០១៨ និង ៧,៥% ក្នុងឆ្នាំ២០១៩។ កំណើននៃវិស័យនេះនឹងត្រូវបានជម្រុញដោយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗដូចជា៖ ការបើកផ្លូវរថភ្លើងថ្មី (ភ្នំពេញ-ប៉ោយប៉ែត) ការពង្រីកព្រលានយន្តហោះ និងកំពង់ផែនានា និងការធ្វើឲ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធឡជីស្ទីក ដែលនឹងជួយប៉ះប៉ូវដល់កំណើនយឺតនៃការនាំចេញផលិតផលកាត់ដេរ។ សម្រាប់ផ្លូវគមនាគមន៍ ផែនការវិនិយោគថ្មីលើបច្ចេកវិទ្យា 5G និងការពង្រីកវិសាលភាពគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល និងជួយជម្រុញទីផ្សារអ៊ីនធឺណេតឲ្យមានសន្ទុះខ្លាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ *វិស័យនេះក៏បានជួបប្រទះបញ្ហាប្រឈមទៅលើកង្វះខាតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ព្រមទាំងភាពមានកម្រិតនៃជំនាញនិងវិជ្ជាជីវៈក្នុងវិស័យឡជីស្ទីក។*

# ជំពូកទី៣

# ការវិភាគពីកំណើនសេដ្ឋកិច្ចកម្ពុជា

## ៣.១. លទ្ធផលនៃការស្រាវជ្រាវ

ដោយសារតែទិន្នន័យទាក់ទងនឹងអថេរទាំងបួនខាងលើ នៅមានកម្រិត និងមិនមានគ្រប់គ្រាន់ដល់ឆ្នាំ២០១៧ ដូច្នេះទិន្នន័យត្រូវបានយកត្រឹមតែនៅឆ្នាំ២០១៦ ដើម្បីយកមកធ្វើការវិភាគ។ យើងមានសមីការព្យាករណ៍៖

$$\text{GDP} = \text{C}_0 + \beta_1 C + \beta_2 I + \beta_3 G + \beta_4 NX$$

$C_0$: ចំនួនថេរ

$C$: ការចំណាយប្រើប្រាស់

$I$: ការវិនិយោគ

$G$: ការចំណាយសាធារណៈ

$NX$: ការនាំចេញសុទ្ធ

តារាងទី៥៖ ទិន្នន័យសម្រាប់វិភាគពីឆ្នាំ១៩៩៥ -២០១៦ គិតជាភាគរយ

| Years | GDP | C | I | G | NX |
|---|---|---|---|---|---|
| 1995 | 9.9 | 4.7 | 21.0 | -23.2 | 8.24 |
| 1996 | 5.9 | 6.2 | 10.83 | 25.2 | -17.38 |
| 1997 | 4.0 | -4.5 | -20.74 | 2.0 | 30.32 |
| 1998 | 4.7 | 7.5 | 3.26 | -7.4 | -1.34 |
| 1999 | 12.7 | 3.6 | 7.43 | 16.8 | 12.01 |
| 2000 | 10.7 | 2.7 | 0.03 | 12.4 | 6.58 |
| 2001 | 7.4 | 0.2 | 13.35 | 8.9 | 7.14 |
| 2002 | 6.6 | 6.6 | 13.64 | 9.9 | -4.17 |
| 2003 | 8.5 | 6.1 | 7.07 | 4.8 | -1.86 |
| 2004 | 10.3 | 10.4 | 11.08 | -6.7 | 8.26 |
| 2005 | 13.3 | 10.5 | 36.04 | 2.9 | 0.93 |
| 2006 | 10.8 | 5.3 | 21.96 | -4.9 | 3.23 |
| 2007 | 10.2 | 2.3 | 39.02 | 82.1 | -1.91 |
| 2008 | 6.7 | 11.1 | 7.85 | 5.0 | -6.95 |
| 2009 | 0.1 | -1.7 | 6.44 | 21.7 | 0.3 |
| 2010 | 6.0 | 7.1 | 19.47 | 12.5 | 3.74 |
| 2011 | 7.1 | 8.7 | 8.99 | 7.8 | 2.53 |
| 2012 | 7.3 | 2.9 | 26.03 | 5.7 | -2.44 |
| 2013 | 7.4 | 4.0 | 16.37 | 5.2 | -1.09 |
| 2014 | 7.1 | 2.8 | -1.26 | 2.4 | 1.14 |
| 2015 | 7.0 | 4.2 | 4.71 | 4.4 | 0.7 |
| 2016 | 7.0 | 5.1 | 12.7 | 5.7 | 0.004 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, DataBank, World Bank 2016*

ក្រោយពីបានធ្វើការប្រមូលទិន្នន័យ និងបន្ទាប់ពីបានធ្វើការវិភាគតាម Regression ក្នុងកម្មវិធី SPSS ហើយនោះ យើងបានសមីការដូចខាងក្រោមនេះ (សូមមើលក្នុងឧបសម្ព័ន្ធទី១)

$$\text{GDP} = 3.882 + 0.391C + 0.119I + 0.014G + 0.2NX$$

$$SE{:}\quad 1.2 \qquad 0.18 \qquad 0.05 \qquad 0.03 \qquad 0.07$$

$$n = 22, \qquad R^2 = 0.489$$

## ៣.២. ការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ

– Consumption: ផលិតផលក្នុងស្រុកសរុប (GDP) និងការប្រើប្រាស់ត្រូវបានផ្សារភ្ជាប់នៅក្នុងន័យថាទោះបីជាផលិតផលក្នុងស្រុកសរុបត្រូវបានគណនាដោយប្រើវិធានការជាច្រើនក៏ដោយក៏ការប្រើប្រាស់គឺជាសមាសធាតុសំខាន់បំផុតតែមួយគត់។ ព័ត៌មានលំអិតផ្សេងទៀតដែលត្រូវបានប្រើដើម្បីគណនាផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយរួមមានការចំណាយរបស់រដ្ឋាភិបាល និងការនាំចេញសុទ្ធ។ ការប្រើប្រាស់ជាធម្មតាមានជាង ៥០ ភាគរយនៃការគណនាផលិតផលក្នុងស្រុកសរុបនៃប្រទេសភាគច្រើន។ នៅប្រទេសខ្លះការប្រើប្រាស់មានជាង ៧០ ភាគរយនៃការគណនាផលិតផលក្នុងស្រុកសរុប[39]។ តាមសមីការខាងលើឃើញថា អថេរចំណាយប្រើប្រាស់(C) មានមេគុណស្មើនឹង 0.391។ តាមរយៈមេគុណនេះបង្ហាញឲ្យឃើញថា ការចំណាយប្រើប្រាស់ទៅលើទំនិញ និងសេវាកម្ម ក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ការកើនឡើងក្នុងការប្រើប្រាស់មានន័យថា វាធ្វើឲ្យកើនឡើងក្នុងការផលិតទំនិញ និងសេវាកម្មបន្ថែមទៀតដើម្បីបំពេញតម្រូវការក្នុងស្រុក។

–Investment: ផ្អែកតាមសមីការខាងលើមេគុណ នៃអថេរវិនិយោគពិតជាមានទំនាក់ជាមួយនឹងកំណើនសេដ្ឋកិច្ចឃើញថាមេគុណនៃអថេរនេះស្មើនឹង ០.១១៩ បើគិតចាប់ពីឆ្នាំ១៩៩៥-២០១៦។ ការវិនិយោគបានចូលរួមយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានការកើនឡើងនូវកំណើន GDP ។ ព្រោះថា កាលណាមានការវិនិយោគកាន់តែច្រើន នាំឲ្យមានកំណើនការងារនៅក្នុងស្រុកដែលបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋ តាមរយៈការវិនិយោគទៅលើវិស័យឧស្សាហាកម្ម រោងចក្រកាត់ដេរ សេវាកម្ម និងសំណង់ជាដើម។ ដោយផ្អែកទៅលើសមីការចំណូលសរុប $GDP = Y = C + S$ (Keynesian Theory) ដែល $S = I$ មានន័យថា កាលណាការសន្សំក្នុងស្រុកកើនឡើងនាំឲ្យការវិនិយោគកើនឡើងបន្ថែមទៀតទៅលើវិស័យផ្សេងៗក្នុងសកម្មភាពសេដ្ឋកិច្ច ស្របពេលជាមួយគ្នានោះវាធ្វើឲ្យកើនឡើងនូវកម្រិត GDP។

[39] http://www.wisegeek.com

–Government Expenditure: ផ្អែកតាមសមីការព្យាករណ៍ខាងលើ បានបង្ហាញឲ្យឃើញថា ការចំណាយរបស់រដ្ឋាភិបាលមិនសូវមានឥទ្ធិពលដល់កំណើន GDP ទេ(Daniel Mitchell)[40]។ (John Maynard Keynes) បានឡើងថា ទោះជាយ៉ាងនេះក្តី ការចំណាយសាធារណៈ នៅតែដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់ អាចចូលរួមក្នុងការកាត់បន្ថយភាពអត់ការងារធ្វើ ឬជួយជំរុញដល់កំណើនផលិតផលក្នុងស្រុកសរុប[41]។ អាចនិយាយបានម៉្យាងទៀតថា វាបានចូលរួមធ្វើឲ្យមានកំណើនដោយប្រយោលដល់វិស័យសេដ្ឋកិច្ច។ ព្រោះថា ការចំណាយ G របស់រដ្ឋាភិបាលបានជួយសម្រួលដល់វិស័យឯកជន តាមរយៈការចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពានជាដើម និងរដ្ឋាភិបាលអាចទទួលបានមកវិញពីការចំណាយទាំងនេះដោយប្រយោលតាមរយៈការប្រមូលពន្ធ (Thomas Stratmann & Gabriel Lucjan Okolski)។

–Net Export: តាមតារាងឧបសម្ព័ន្ធទី២ បានបង្ហាញឲ្យឃើញថា ប្រទេសកម្ពុជាមានការនាំចូលច្រើនជាងការនាំចេញបើគិតចាប់ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ២០១៦ អាចនិយាយបានថាជាប្រទេសដែលមានឱនភាពពាណិជ្ជកម្ម។ ករណីខ្លះឱនភាពពាណិជ្ជកម្ម ពិតជាអាចជួយជំរុញកំណើនផលិតផលក្នុងស្រុក[42]។ ដោយឡែក មេគុណអថេរនៃការនាំចេញសុទ្ធមានសញ្ញាវិជ្ជមានគឺ ០.២ មានន័យថាវាមានទំនាក់ទំនងជាវិជ្ជមាននឹងកំណើននៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា។ បើទោះបីជាវាមានឱនភាពពាណិជ្ជកម្មយ៉ាងណាក៏ដោយ តែកម្ពុជានៅតែចាំបាច់ក្នុងការនាំចូលទំនិញនិងសេវាដែលខ្លួនត្រូវការ ដើម្បីបំពេញតម្រូវការក្នុងស្រុកចំពោះផលិតផលណាដែលខ្លួនគ្មានឯកទេសកម្ម ដើម្បីទាញយកផលចំណេញពីការធ្វើពាណិជ្ជកម្មអន្តរជាតិ និងធ្វើការនាំចេញតែផលិតផលណាដែលខ្លួនមានឯកទេសកម្មក្នុងការផលិតដែលមានចំណាយឱកាសទាបទៅលើទំនិញទាំងនោះ (David Ricardo, Comparative Advantange)។

ក្នុងសមីការខាងលើ យើងអាចគណនាភាពយឺតនៃអនុគមន៍ $Y = GDP$ ធៀបនឹងការវិនិយោគ I ។ តាមសមីការនេះយើងអាចសរសេរបាន $Y' = (GDP)' = 0.119$

$$e = \frac{\Delta GDP\%}{\Delta I\%} = (GDP)' \times \frac{I_0}{GDP_{t_0}}$$

ដោយ $I_0 = 12.7\%$ , $GDP_{t_0} = 7\%$

---

[40] https://www.heritage.org/budget-and-spending/report/the-impact-government-spending-economic-growth

[41] https://www.mercatus.org/publication/does-government-spending-affect-economic-growth

[42] Theory 2- Trade deficits promote GDP growth; https://www.ukessays.com/essays/economics/corelation-between-gdp-growth-and-trade-deficits-economics-essay.php

$=> e = 0.119 \times \frac{12.7}{7} = 0.22\%$ មានន័យថា នៅពេលដែលការវិនិយោគកើនឡើងចំនួន ១% នោះវានឹងធ្វើឲ្យមានកំណើន GDP ចំនួន ០.២២% (ដោយផ្អែកលើតួលេខឆ្នាំ២០១៦)។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាលើប្រធានបទខាងលើ ឃើញថាប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំង ចាប់ពីពេលដែលកម្ពុជាបានផ្លាស់ប្តូរការគ្រប់គ្រងសេដ្ឋកិច្ចផែនការ ដែលភាគច្រើនការវិនិយោគសំខាន់ៗគឺជាកម្មសិទ្ធិរបស់រដ្ឋ មកជាសេដ្ឋកិច្ចទីផ្សារ ឯកជនភាវូបនីយកម្មដោយទទួលស្គាល់កម្មសិទ្ធឯកជន និងភាគច្រើននៅក្នុងសកម្មភាពសេដ្ឋកិច្ចត្រូវបានគ្រប់គ្រងដោយវិស័យឯកជន។ បច្ចុប្បន្ននេះ វិស័យឯកជនបានដើរតួនាទីជាកតាលីករដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដោយមានការចូលរួមវិនិយោគស្ទើរគ្រប់វិស័យតាមរយៈវិស័យនេះ។ ក្នុងរយៈពេល ២២ ឆ្នាំ នៃដំណើរការសេដ្ឋកិច្ចរបស់កម្ពុជាឃើញថាមានការប្រាស្រ័យទាក់ទងយ៉ាងខ្លាំង ទាក់ទិនទៅនឹងការចំណាយប្រើប្រាស់។ រីឯ ការវិនិយោគវិញក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការជួយជំរុញដល់កំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈការវិនិយោគក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស។ ចំណែកឯ ការនាំចេញសុទ្ធ (NX) បានជួយសម្រួលដល់ការប្រើប្រាស់ទំនិញ និងសេវាកម្មសម្រាប់ប្រទេសកម្ពុជាសម្រាប់កំឡុងពេលកន្លងមកនេះ ត្បិតតែកម្ពុជាមានឱនភាពពាណិជ្ជកម្មយ៉ាងណាក៏ដោយ។ ប៉ុន្តែ វាបានបង្ហាញសញ្ញាវិជ្ជមានថា កម្ពុជានៅតែទទួលបានផលចំណេញពីការធ្វើពាណិជ្ជកម្មអន្តរជាតិ ព្រោះវាបានបំពេញតម្រូវការក្នុងស្រុក។ ដូចដែរបានបកស្រាយខាងដើម អថេរទាំងបីខាងលើសុទ្ធតែ ជាចលករក្នុងការជំរុញកំណើនផលិតផលក្នុងស្រុសរុបរបស់ប្រទេសកម្ពុជាយើង។ ប៉ុន្តែ បើក្រឡេកទៅមើលអថេរចំណាយ សាធារ-ណៈវិញ យើងសង្កេតឃើញថា វាបានចូលរួមក្នុងការជំរុញកំណើនផលិតផលក្នុងស្រុកសរុបដោយប្រយោល ដែលបានទ្រទ្រង់ដល់វិស័យផ្សេងៗក្នុងប្រតិបត្តិការសេដ្ឋកិច្ច។

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ឯកភាពទឹកដី, ឯកភាពជាតិ, ស្ថិរភាពនយោបាយរឹងមាំ, ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ, នីតិរដ្ឋ, និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាស្របទៅតាម **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣** ដើម្បីបន្តកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ចាប់តាំងពីឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឲ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅគ្រប់ផ្នែក និងគ្រប់វិស័យ រួមមានទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ, វិមជ្ឈការនិងវិសហវជ្ឈការ, ការគ្រប់គ្រងទីផ្សារការងារ និងការកែលម្អគុណភាពសេវាសាធារណៈ ដែលការកែទម្រង់ទាំងនេះបាន

និងកំពុងចាប់ផ្តើមបង្កើតចេញជាលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់។ នេះជាសក្ខីភាពនៃការអភិវឌ្ឍឥតឈប់ឈររបស់កម្ពុជា ដោយផ្តើមចេញពីបាតដៃទទេរនៅក្នុងដំណើរដ៏វែងឆ្ងាយឆ្លងកាត់ការបត់បែន និងការលំបាករាប់មិនអស់ ដែលទទួលបាននូវការសាទរ, ការទទួលស្គាល់ និងសហប្រតិបត្តិការពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើភាព និងស្មើសិទ្ធិ ជាពិសេសបានធ្វើឲ្យកម្ពុជាទទួលបាននូវឯករាជ្យភាពសេដ្ឋកិច្ចនិងភាពជាម្ចាស់កាន់តែប្រសើរ នៅក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីមួយទៀត គឺជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ លទ្ធផលប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយត្រូវបានស្ថាប័នអន្តរជាតិនានាវាយតម្លៃថា ជាសមិទ្ធផលមួយដែលមិនធ្លាប់មានពីមុនមកក្នុងបណ្តាប្រទេសក្នុងតំបន់ និងបណ្តាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា។ ចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥.០៦% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៣ ដល់ ១៩.៦៤%នៃ ផ.ស.ស ក្នុងឆ្នាំ២០១៧ពោលគឺកើនឡើងជិត ២ ដង ឬប្រមាណ ៤.៥៨ ពិន្ទុភាគរយនៃ ផ.ស.ស។ ទន្ទឹមនេះ ថវិកាចំណាយបានកើនប្រមាណ ១.៨ ដង ហើយការវិភាជន៍ថវិកាត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ។

ជារួម ផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧.០% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ទោះជាយ៉ាងនេះក្តី កម្ពុជានឹងត្រូវបន្តប្រឈមនឹងហានិភ័យដែលបណ្តាលមកពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួនដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ដើម្បីសម្រេចបានលទ្ធផលខាងលើ រដ្ឋាភិបាលត្រូវខិតខំបន្តការងារកែទម្រង់ និងអនុវត្តវិធានការអាទិភាពទាំងឡាយឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ព្រមទាំងបង្កើនចំណាយវិនិយោគសាធារណៈ ក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ចឈានទៅបង្កើនតម្លៃន្ថែមលើវិស័យសក្តានុពលនាំមុខដែលមានស្រាប់ផង និងបង្កើតជន្ទល់កំណើនថ្មី និងមានសក្តានុពលខ្ពស់ ព្រមទាំងត្រៀមខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធានាឲ្យបាននូវចីរភាពកំណើនក្នុងរយៈពេលមធ្យម និងវែង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលចាំបាច់ត្រៀមលក្ខណៈរួចជាស្រេចក្នុងការបង្ការ បញ្ចៀស ឬបន្ធូរបន្ថយសម្ពាធហានិភ័យដែលអាចនឹងកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញនិងអនុវត្តវិធានការគោលនយោបាយ

ដែលឆ្លើយតបទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការតាមដាន និងវាយតម្លៃឲ្យកាន់តែយកចិត្តទុកដាក់ ក្នុងគោលដៅបង្កើនភាពធន់នឹងវិបត្តិ និងធានាបានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។

# ឯកសារយោង


- បណ្ឌិត ហង់ ជួន ណារ៉ុន, សេដ្ឋកិច្ចកម្ពុជា, ឆ្នាំ២០១៥
- បណ្ឌិត ហង់ ជួន ណារ៉ុន, ម៉ាក្រូសេដ្ឋកិច្ច, ឆ្នាំ២០០៩
- ផែនការស្តារសេដ្ឋកិច្ច សង្គមកិច្ច ១៩៩៤-១៩៩៥
- ឯក ស្រីឡែន និង សូ លីណា "ការចូលរួមចំណែកវិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ចជាតិ"(ឆ្នាំ២០១៧) សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- ហេង សម្បត្តិ និង អេន សុជាតិ "វិស័យសំណង់បុរីក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា" (ឆ្នាំ២០១៦), សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- គណនេយ្យជាតិកម្ពុជា ឆ្នាំ១៩៩៣-២០០៩, វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ
- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៩
- ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពី សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៨, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥
- ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច, ភ្នំពេញ ២០០៤
- ពោ ប៊ុណ្ណា, ម៉ាក្រូសេដ្ឋកិច្ចវិទ្យា ទ្រឹស្តី និងគោលនយោបាយ ឆ្នាំ២០០២, វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា
- សាស្រ្តាចារ្យម៉ម ចរិយាវុធ, Principles of macroeconomics, 2011 សាកលវិទ្យាល័យភូមិន្ទនីតិ សាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- រដ្ឋធម្មនុញ្ញទាំងឡាយនៃកម្ពុជា ខែ កញ្ញា ឆ្នាំ២០១១
- Andrew B. Abel, Ben S. Bernanke, Dean Croushore (2000). Macroeconomics, 6th Edition. Published by Pearson Addison Wesley
- General Department of Policy, Cambodia Macroeconomic Report Assessment 2017, January 2018
- Cambodia Macroeconomic Progress A Journey of 2025 years , October o5th, 2016

- Michael P. Todaro and Stephen C. Smith (2000). Economic Development 8th Edition. Published by Pearson Addision Wesley
- http://www.investopedia.com/terms/c/classicaleconomics.asp
- htt://www.wisegeek.com/what-are-the-different-theories-of-economic-growth.htm, n.d
- WiseGREEK,n.d
- What are the different theory of Economic Growth?, n.
- htt://www.wisegeek.com/shat-are-t the-different-theories-of-economic-growth.htm, n.d
- Hash, D. Economic Growth part III, 2015
- The concise Encyclopedia of Economics, 2008
- Lauren, F, nd
- htt://www.wisegeek/what-are-the-different-theories-of-economic-growth.htm
- https://www.differencebetween.com/difference-between-economic-growth-and-vs-gdp
- www7.nationalacademies.org/cnstat/Nonmarket_Current.html
- http://www.wisegeek.com
- https://www.ssag.sk/studovna/files/RELATIONSHIP-BETWEEN-GDP.pdf
- Theory 2- Trade deficits promote GDP growth; https://www.ukessays.com/essays/economics/corelation-between-gdp-growth-and-trade-deficits-economics-essay.php
- http://usa-wethepeople.com/2011/02/y-c-i-g-nx-and-the-gdp-bull-crap-numbers/
- https://data.worldbank.org/country/cambodia
- https://www.heritage.org/budget-and-spending/report/the-impact-government-spending-economic-growth

**ឧបសម្ព័ន្ធទី១៖** តារាងវិភាគ ANOVA

| Variables Entered/Removed[a] | | | |
|---|---|---|---|
| Model | Variables Entered | Variables Removed | Method |
| 1 | Net Export, Government, Investment, Consumption[b] | . | Enter |
| a. Dependent Variable: GDP | | | |
| b. All requested variables entered. | | | |

| Model Summary | | | | |
|---|---|---|---|---|
| Model | R | R Square | Adjusted R Square | Std. Error of the Estimate |
| 1 | 0.698[a] | 0.488 | 0.367 | 2.35727 |
| a. Predictors: (Constant), Net Export, Government, Investment,Consumption | | | | |

| ANOVA[a] | | | | | | |
|---|---|---|---|---|---|---|
| Model | | Sum of Squares | Df | Mean Square | F | Sig. |
| 1 | Regression | 89.911 | 4 | 22.478 | 4.045 | 0.017[b] |
| | Residual | 94.464 | 17 | 5.557 | | |
| | Total | 184.375 | 21 | | | |
| a. Dependent Variable: GDP | | | | | | |
| b. Predictors: (Constant), Net Export, Government, Investment, Consumption | | | | | | |

| Coefficients[a] | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Model | | Unstandardized Coefficients | | Standardized Coefficients | t | Sig. | 95.0% Confidence Interval for B | |
| | | B | Std. Error | Beta | | | Lower Bound | Upper Bound |
| 1 | (Constant) | 3.882 | 1.205 | | 3.220 | 0.005 | 1.338 | 6.425 |
| | Consumption | 0.391 | 0.184 | 0.506 | 2.126 | 0.048 | 0.003 | 0.779 |
| | Investment | 0.119 | 0.050 | 0.510 | 2.369 | 0.030 | 0.013 | 0.225 |
| | Government | 0.014 | 0.033 | 0.092 | 0.428 | 0.674 | -0.056 | 0.084 |
| | Net Export | 0.200 | 0.076 | 0.590 | 2.629 | 0.018 | 0.039 | 0.360 |
| a. Dependent Variable: GDP | | | | | | | | |

**ឧបសម្ព័ន្ធទី២៖** តារាងបង្ហាញពី ផ.ស.ស និងចលករនៃសេដ្ឋកិច្ចពីឆ្នាំ១៩៩៥-២០១៦ គិតជាដុល្លារ

| **Year** | **GDP** | **C** | **I** | **G** | **NX** |
|---|---|---|---|---|---|
| 1995 | 3,441,205,693 | 3,263,141,349 | 790,650,906 | 201,012,323 | -529,889,412 |
| 1996 | 3,506,695,720 | 3,436,888,621 | 876,254,337 | 201,629,503 | -646,408,625 |
| 1997 | 3,443,413,389 | 3,110,171,378 | 694,477,899 | 187,689,984 | -402,905,995 |
| 1998 | 3,120,425,503 | 2,983,841,994 | 717,112,677 | 149920660.3 | -410,123,185 |
| 1999 | 3,517,242,477 | 3,159,655,987 | 770,369,775 | 173862739.9 | -460,354,835 |
| 2000 | 3,654,031,716 | 3,245,072,215 | 750,216,093 | 191208095.5 | -435,453,285 |
| 2001 | 3,984,000,517 | 3,376,819,401 | 850,393,626 | 210989551.5 | -345,053,598 |
| 2002 | 4,284,028,483 | 3,686,869,384 | 966,176,649 | 233138881.8 | -301,355,027 |
| 2003 | 4,658,246,918 | 3,987,329,421 | 897,915,533 | 245041900 | -467,682,005 |
| 2004 | 5,337,833,248 | 4,642,494,046 | 997,423,497 | 239329980.3 | -389,641,936 |
| 2005 | 6,293,046,162 | 5,413,595,484 | 1,356,845,323 | 256133507.5 | -545,136,103 |
| 2006 | 7,274,595,707 | 5,889,665,439 | 1,654,837,612 | 251725418.2 | -540,354,296 |
| 2007 | 8,639,235,842 | 6,751,403,627 | 2,300,503,986 | 495102732.5 | -657,982,411 |
| 2008 | 10,351,914,093 | 8,223,980,975 | 2,481,148,445 | 583281932.1 | -231,236,707 |
| 2009 | 10,401,851,851 | 7,922,060,792 | 2,641,030,185 | 641014688.7 | -696,606,648 |
| 2010 | 11,242,275,199 | 9,139,053,168 | 3,155,331,541 | 713286629.4 | -611,372,087 |
| 2011 | 12,829,541,141 | 10,630,521,219 | 3,438,965,980 | 772263732.7 | -695,403,685 |
| 2012 | 14,038,383,450 | 11,255,397,039 | 4,334,004,693 | 812641475.8 | -677,130,205 |
| 2013 | 15,449,630,419 | 11,974,883,292 | 5,043,524,604 | 854707313.3 | -802,608,810 |
| 2014 | 16,777,820,333 | 12,952,994,860 | 4,980,081,288 | 917631261.4 | -735,797,437 |
| 2015 | 18,049,954,289 | 13,863,294,021 | 5,214,874,774 | 974332893.1 | -799,111,092 |
| 2016 | 20,016,747,754 | 15,236,698,991 | 5,876,907,839 | 1042868646 | -878,130,544 |

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, DataBank, World Bank 2016*

**ឧបសម្ព័ន្ធទី៣៖ The Keynesian Controversy.**

The Economics of government spending is not limited to cost-benefit analysis. There is also the Keynesian debate. In the 1930s, John Maynard Keynes argued that government spending-particularly increases in government spending-boosted growth by injecting purchasing power into the economy. According to Keynes, government could reverse economic downturns by borrowing money from the private sector and then returning the money to the private sector through various spending programs.

This "pump priming" concept did not necessarily mean that government should be big. Instead, Keynesian theory asserted that government spending-especially deficit spending-could provide short-term stimulus to help end a recession or depression. The Keynesians even argued that policymakers should be prepared to reduce government spending once the economy recovered in order to prevent Inflation, which they believed would result from too much economic growth. They even postulated that there was a tradeoff between Inflation and unemployment (the Phillips Curve) and that government officials should increase or decrease government spending to steer the economy between too much of one or too much of the other.

Keynesian economics was very influential for several decades and dominated public policy from the 1930s-1970s. The theory has since fallen out of favor, but it still influences policy discussions, particularly on whether or not changes in government spending have transitory economic effects. For instance, some lawmakers use Keynesian analysis to argue that higher or lower levels of government spending will stimulate or dampen economic growth.

The Theory: Economics of Government Spending

Economic theory does not automatically generate strong conclusions about the impact of government outlays on economic performance. Indeed, almost every economist would agree that there are circumstances in which lower levels of government spending would enhance economic growth and other circumstances in which higher levels of government spending would be desirable.